# مدرسة اهل البيت

صلوات الله عليهم

# សាលា
# អាស្ហ់លុល-បៃត៍

## សៀវភៅសិក្សា ប្រវត្តិសាស្ត្រ (تَارِيْخ)
## ថ្នាក់ទី ៧ (អាយុ ១១-១២ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ សេចក្តីប្រកាសភាតរភាព ........ ៥
មេរៀនទី ២ អាពាហ៍ពិពាហ៍របស់ព្រះនាងហ្វាទីម៉ាស្ហ៍ سلام الله عليها ........ ១០
មេរៀនទី ៣ ការផ្លាស់ប្តូរគិប្ឡាត់ ........ ១៣
មេរៀនទី ៤ សមរភូមិបាដ្ឋារ ........ ១៧
មេរៀនទី ៥ កុស្ហ៍វ៉ាស្ហ៍ទាំងបី ........ ២២
មេរៀនទី ៦ សមរភូមិ អ៊ូហ៊្វដ្ឋ - ភាគ ១ ........ ២៧
មេរៀនទី ៧ សមរភូមិ អ៊ូហ៊្វដ្ឋ - ភាគ ២ ........ ៣១
មេរៀនទី ៨ អ្នកផ្សាយសាសនាអ៊ីស្លាម ........ ៣៥
មេរៀនទី ៩ សមរភូមិ អាស្ហ៍ស៊ាប់ ........ ៣៩
មេរៀនទី ១០ សម្បថរីដ្ឋវ៉ាន ........ ៤៤
មេរៀនទី ១១ ការសូមអញ្ជើញបរទេសមកកាន់អ៊ីស្លាម ........ ៤៩
មេរៀនទី ១២ សមរភូមិ ខ៊ុយ៉បារ - ភាគ ១ ........ ៥៤
មេរៀនទី ១៣ សមរភូមិ ខ៊ុយ៉បារ - ភាគ ២ ........ ៥៨
មេរៀនទី ១៤ រឿងហ្វាដ្ឋាក់ ........ ៦៣
មេរៀនទី ១៥ អ៊ុមរ៉ោះត៍កន្លង ........ ៦៩
មេរៀនទី ១៦ សមរភូមិមុតាស្ហ៍ ........ ៧៤
មេរៀនទី ១៧ សមរភូមិ ស្ហាត់ អាល់-សាឡាស៊ីល ........ ៧៩
មេរៀនទី ១៨ ព្រះសាស្តា ស៊ាការីយ៉ា عليه السلام និងព្រះសាស្តា យ៉ាស៊ុយ៉ា عليه السلام ........ ៨៤
មេរៀនទី ១៩ ព្រះសាស្តា ដ្ឋាវ៉ុដ្ឋ عليه السلام ........ ៨៩
មេរៀនទី ២០ ព្រះសាស្តា ស៊ូឡៃម៉ាន عليه السلام ........ ៩៤

**មេរៀនទី ១**

# សេចក្តីប្រកាសភាតរភាព

ពេលបានទៅដល់ម៉ាឌីណាស់ ព្រះសាស្តាមូហាំម៉ាដ់ﷺប្រឈមនឹងឧបសគ្គថ្មីមួយ ។ ជាគ្រាដំបូងបង្អស់ ពួកមុស្លីមត្រូវប្រជុំគ្នា ដូច្នេះត្រូវរកមធ្យោបាយរៀបចំដើម្បីដឹកនាំរដ្ឋមុស្លីមនេះ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺប្រឈមនឹងបញ្ហាសំខាន់បី គឺ៖

១. គ្រោះថ្នាក់វាយប្រហារពីសំណាក់គូរ៉យស្ហ៍ម៉ាក់កាស់ និងពួកគោរពរូបព្រះឯទៀតនៃដែនដីអារ៉ាប៊ី ។

២. វត្តមានរបស់ពួកយ៉ាហ៊ូឌីម៉ាឌីណាស់ដែលរស់នៅខាងក្នុង និងខាងក្រៅស្រុកដែលមានទ្រព្យសម្បត្តិច្រើន ។

៣. វិវាទរវាងបណ្តាអ្នកគាំទ្រព្រះអង្គﷺ ។



ព្រះអង្គﷺដោះស្រាយ បញ្ហាទាក់ទងនឹងពួកមុស្លីមមុនគេ ។ ពួកមុស្លីមដែលបានភៀសខ្លួនជាមួយព្រះអង្គﷺ ពីម៉ាក់កាស់ (ពួកមូហាជីរីន) និងពួកមុស្លីមក្នុងស្រុកដែលរស់នៅឯម៉ាឌីណាស់ បានធាត់ធំនៅក្នុងបរិយាកាសខុសគ្នា ជនទាំងពីរក្រុមនេះមានការអប់រំ និងគំនិតខុសគ្នាឆ្ងាយ ។ ម្យ៉ាងទៀត ប្រជាជាតិអៅស៍ (اَلْأَوْس) និងប្រជាជាតិខុស្រ៉ជ៍ (اَلْخَزْرَج) ដែលរួមជាក្រុមអាន់ស្វារ៍នោះធ្លាប់ជាសត្រូវហុតឈាមនឹងគ្នា ច្បាំងគ្នាតាំងពីលើសពី ១០០ ឆ្នាំមកហើយ ។

ប្រការដំបូងបង្អស់ដែលព្រះសាស្តាមូហាំម៉ាដ់ﷺបានធ្វើគឺ ផ្សះផ្សាប្រជាជាតិអៅស៍និងប្រជាជាតិខុស្រ៉ជ៍ ។ ព្រះអង្គﷺបានបង្រួបបង្រួមពួកគេដោយផ្អែកលើ

ជំនឿតែមួយរបស់ក្រុមទាំងពីរ គឺសាសនាអ៊ីស្លាម ដោយសូមឲ្យពួកគេបំភ្លេចចោលនូវទំនាស់ចាស់ ។

បន្ទាប់មក ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ផ្តោតអារម្មណ៍ទៅលើបញ្ហាពួកមូហាជីរីន ។ បុគ្គលក្លាហានទាំងនេះបានលះបង់ចោលទ្រព្យសម្បត្តិនិងដីធ្លីនៅឯម៉ាក់កាស្ស៊ូដើម្បីតាមព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ។ តាមព្រះរាជបញ្ជារបស់អល់ឡោះហ្ស៍ عز وجل ព្រះសាស្តា ﷺ បានចងសម្ព័ន្ធភាតរភាពរវាងពួកមូហាជីរីននិងពួកអាន់ស្វារ៍ ។ ព្រះអង្គ ﷺ បានផ្គួបមូហាជៀរម្នាក់ជាមួយអាន់ស្វារ៍ម្នាក់ ហើយបានប្រកាសថាអ្នកទាំងពីរជាបងប្អូនគ្នា ។ ពួកអាន់ស្វារ៍ដែលមានចិត្តទូលាយបានប្រគល់ទ្រព្យខ្លួនចំនួនពាក់កណ្តាលឲ្យទៅបងប្អូនថ្មីរបស់ខ្លួន ដើម្បីនឹងឲ្យពួកគេអាចរស់នៅបានស្រួលនៅម៉ាឌីណាស្ស៊ូ ។

ក្រោយពីបានផ្គួបពួកគេទាំងអស់គ្នាហើយ នៅសល់តែអ៊ីម៉ាំអាលី صلوات الله عليه والسلام ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام សួរព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ថាអ្នកណាជាបងប្អូនព្រះអង្គ صلوات الله عليه والسلام ។ ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ មានព្រះវចនៈថា៖ "អាលី صلوات الله عليه والسلام អើយ អ្នក صلوات الله عليه والسلام ជាបងប្អូនខ្ញុំ ﷺ ក្នុងលោកនេះនិងលោកមុខដែរ ។"

អាស្រ័យវិធីដ៏ងាយស្រួលនេះ ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ធ្វើឲ្យឯកភាពមុស្លីមរឹងមាំ អាស្រ័យឯកភាពនេះព្រះអង្គ ﷺ អាចផ្តោតអាម្មណ៍ទៅលើបញ្ហាពីរទៀតបាន ។ ដើម្បីផ្តល់សន្តិសុខដល់ប្រជារាស្ត្រម៉ាឌីណាស្ស៊ូទាំងអស់គ្នា ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ បានធ្វើកិច្ចព្រមព្រៀងសន្តិភាពរវាងពួកមុស្លីម និងពួកយ៉ាហ៊្វូឌី ។ ខ្លឹមសារនៃកិច្ចព្រមព្រៀងនេះជាការបោះជំហានដ៏សំខាន់មួយ សម្រាប់ពួកអារ៉ាប់ដែលគ្មានគោលសីលធម៌ ។

ជាលើកដំបូងបង្អស់ ពួកអារ៉ាប់ត្រូវរាប់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញដែលគ្រោងគោលការណ៍សន្តិភាព គោលការណ៍សណ្តាប់ធ្នាប់និងគោលការណ៍តុលាការ ។ សូមលើកយកកិច្ចព្រមព្រៀងនេះមកជូនដោយសង្ខេប គឺ៖

"ដោយនូវព្រះនាមអល់ឡោះហ្ស៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។

១. អ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះរួមជាប្រជាជាតិតែមួយ ។ បើ

មុស្លីមណាសម្លាប់អ្នកណាដោយអចេតនា ឬជាចំណាប់ខ្មាំង ត្រូវបង់ថ្លៃលោះខ្លួនឬថ្លៃសងជម្ងឺចិត្តបើចាំបាច់ ។ មុស្លីមទាំងឡាយត្រូវជួយអ្នកនោះដោយចំណាយថវិកា ។

២. បុគ្គលយ៉ាហ៊ូឌីណាមួយដែលចូលសាសនាអ៊ីស្លាមត្រូវទទួលបាន នូវការឧបត្ថម្ភពីពួកមូហាជីរីននិងពួកអាន់ស្វរ៍ ។ បុគ្គលនោះមិនខុសពីមុស្លីមឯទៀតទេ គេនឹងមិនសង្កត់សង្កិនបុគ្គលនោះទេ មិនចាត់ទុកបុគ្គលនោះជាសត្រូវទេ ។

៣. មុស្លីមជាក្រុមៗត្រូវទៅបំពេញជីហាដ់ (សង្គ្រាមសាសនា) ផ្លាស់គ្នា ដើម្បីនឹងឲ្យមានការហូរឈាមស្មើគ្នាដើម្បីអល់ឡោះហ៍ عَزَّ وَجَلَّ ។

៤. បើមុស្លីមណាសម្លាប់មុស្លីមម្នាក់ទៀត ដោយគ្មានមូលហេតុត្រឹមត្រូវ ហើយត្រូវបានដឹងស្របតាមច្បាប់ថាអ្នកនោះជាឃាតករពិតមែន អ្នកនោះត្រូវទទួលទោសប្រហារជីវិត លើកលែងតែបណ្ដាទាយាទរបស់អ្នកត្រូវសម្លាប់នោះព្រមលើកលែងទោសឲ្យអ្នកនោះ ។ ក្នុងករណីទាំងពីរ មុស្លីមទាំងអស់គ្នាមានករណីយកិច្ចរួបរួមគ្នាប្រឆាំងឃាតករ ។

៥. អាជ្ញាធរក្នុងការដោះស្រាយការវិវាទគ្នាត្រូវតែផ្អែកលើអល់ឡោះហ៍ عَزَّ وَجَلَّ និងមូហាំម៉ាដ់ صلى الله عليه وآله وسلم ។

៦. ពេលពួកមុស្លីមប្រយុទ្ធដើម្បីការពារម៉ាឌីណាស្ញ ពួកយ៉ាហ៊ូឌីត្រូវតែចូលរួមក្នុងការចាយវាយសម្រាប់សង្គ្រាម ។

៧. ពួកមុស្លីមនិងពួកយ៉ាហ៊ូឌីមានសេរីភាពអនុវត្តច្បាប់ និងសាសនារបស់ខ្លួន ។

៨. ជីវិតរបស់អ្នកជិតខាងនិងជីវិតរបស់អ្នកដែលគេឲ្យជម្រក ក៏ដូចជីវិតយើងដែរ ត្រូវតែគោរពពួកគេទាំងនេះ ។ មិនត្រូវឲ្យជម្រកដល់ពួកគូរ៉យ់ស្ហ៍ឬដល់សម្ព័ន្ធមិត្តរបស់ពួកគូរ៉យ់ស្ហ៍ទេ ។

៩. អ្នកចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀងនេះ មានភារកិច្ចរួមគ្នាក្នុងការការពារម៉ាឌីណាស្ញ ។

១០. ពេលពួកមុស្លីមសូមឲ្យពួកយ៉ាហ៊្វូឌី ធ្វើកិច្ចព្រមព្រៀងសន្តិភាពជាមួយសត្រូវ ពួកយ៉ាហ៊្វូឌីត្រូវយល់ព្រមទទួលសំណូមពរ ។ ពួកមុស្លីមក៏ត្រូវយល់ព្រមទទួលសំណូមពរដូចនេះដែរពីសំណាក់យ៉ាហ៊្វូឌី លើកលែងតែពេលសត្រូវប្រឆាំងអ៊ីស្លាម ។

អល់ឡោះហ្វ៎ﷻគាំទ្រមនុស្សល្អនិងអ្នកមានសទ្ធាជ្រះថ្លា មូហ៊ាំម៉ាដ្ឋ៍ﷺជាព្រះសាសនៈទូតរបស់ព្រះអង្គﷻ ។"

អ្នកស្រុកម៉ាឌីណាស្ង់ភាគច្រើន យល់ព្រមទទួលយកឯកសារដែលមើលឃើញវែងឆ្ងាយនេះ ។ ពួកយ៉ាហ៊្វូឌីមួយចំនួនតូចដែលបានបដិសេធពីដំបូងនោះ ក៏បានចុះហត្ថលេខាយល់ព្រមដែរក្រោយមក ។

បានធ្វើការរៀបចំដើម្បីការពារម៉ាឌីណាស្ង់ហើយ ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ៍ﷺ អាចប្រមូលអារម្មណ៍ទៅលើការគំរាមរបស់ពួកគូរ៉យ៉ស្ហ៍ស្រុកម៉ាក់កាស្ង់ ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. រដ្ឋធម្មនុញ្ញគឺអ្វី ហេតុអ្វីចាំបាច់ត្រូវបង្កើតរដ្ឋធម្មនុញ្ញមួយនៅម៉ាឌីណាស់ ?

២. ព្រះសាស្តាមូហាំម៉ាដ់ﷺបានដោះស្រាយ ជម្លោះរវាងប្រជាជាតិអៅស៍ និងប្រជាជាតិខុស្ស័រ៉ច់ដោយវិធីណា ?

៣. ព្រះអង្គﷺបានដោះស្រាយបញ្ហាពួកយ៉ាហ៊ូឌីដោយមធ្យោបាយណា ?

៤. ពួកអាន់ស្វារ៍បានជួយព្រះអង្គﷺ ធ្វើឲ្យពួកមូហាជ៊ីរីនមានស្ថានភាពជីវិតប្រសើរឡើងដូចម្តេច ?

៥. បន្ទាប់ពីស្រុកម៉ាឌីណាស់មានសន្តិភាព ព្រះសាស្តាមូហាំម៉ាដ់ﷺអាចធ្វើអ្វីបាន ?

## មេរៀនទី ២

# អាពាហ៍ពិពាហ៍របស់ព្រះនាងហ្វាទីម៉ាស់ سلام الله عليها

ព្រះនាងហ្វាទីម៉ាស់ سلام الله عليها ឧត្តមស្ត្រីលើសអស់ស្ត្រី ជាព្រះរាជបុត្រីទោលរបស់ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ។ រាល់ពេលដែលព្រះនាង سلام الله عليها មកជួបព្រះអង្គ صلى الله عليه وآله وسلم ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم តែងតែងើបឈរដោយសេចក្តីគោរព ពុំមែនព្រោះតែព្រះនាង سلام الله عليها ជាព្រះរាជបុត្រីព្រះអង្គ صلى الله عليه وآله وسلم នោះទេ តែព្រោះតែព្រះនាង سلام الله عليها ប្រកបដោយគុណសម្បត្តិឧត្តមកំពូលក្នុងចំណោមស្ត្រីទាំងអស់ (خَيْرُ نِسَاءِ الْعَالَمِينَ) គឺប្រកបដោយការក្រែងខ្លាចអល់ឡោះហ៍ عز وجل និងជំនឿស៊ប់ចិត្តចំពោះអល់ឡោះហ៍ عز وجل ។

ព្រោះតែព្រះនាងហ្វាទីម៉ាស់ سلام الله عليها ជាឧត្តមនារី បានជាព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានទទួលការស្តីដណ្តឹងព្រះរាជបុត្រីព្រះអង្គ صلى الله عليه وآله وسلم ពីសំណាក់ត្រកូលមានទ្រព្យសម្បត្តិស្តុកស្តម្ភនិងមេកុលសម្ព័ន្ធនានា ។ ព្រះអង្គ صلى الله عليه وآله وسلم ឆ្លើយបដិសេធការស្តីដណ្តឹងទាំងអស់ដោយអះអាងថាព្រះអង្គ صلى الله عليه وآله وسلم រង់ចាំព្រះរាជបញ្ជារបស់អល់ឡោះហ៍ عز وجل ដើម្បីសម្រេចចិត្តត្រូវលើកព្រះនាង سلام الله عليها ឲ្យទៅបុគ្គលណា ។

ពួកមុស្លីមដឹងថា បុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ជាមួយមហារីរូបនេះមិនចាំបាច់មានទ្រព្យឬមានអំណាចទេ តែបុគ្គលនោះត្រូវប្រកបដោយគុណសម្បត្តិល្អប្រសើរគឺៈ សេចក្តីទៀងត្រង់ ការខ្លាចក្រែងអល់ឡោះហ៍ عز وجل និងមានមេត្តាករុណា ។ ដូច្នេះអ្នកខ្លះស្នើឲ្យអ៊ីម៉ាំអាលី صلوات الله عليه والسلام ទៅជួបព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ស្តីដណ្តឹងព្រះនាងហ្វាទីម៉ាស់ سلام الله عليها ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام ក៏មានបំណងដូច្នោះដែរ ព្រះអង្គ صلوات الله عليه والسلام បានទៅជួបព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام ញញើតស្នើសូម តែព្រះសាស្តា صلى الله عليه وآله وسلم សូមឲ្យព្រះអង្គ صلوات الله عليه والسلام ប្រាប់គោលបំណង អ៊ីម៉ាំអាលី صلوات الله عليه والسلام ក៏បានសូមស្តីដណ្តឹងព្រះរាជបុត្រីព្រះអង្គ صلى الله عليه وآله وسلم ។

ពេលបានឮសំណូមពរ ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم មានសេចក្តីត្រេកអរណាស់ ព្រះអង្គ صلى الله عليه وآله وسلم ញញឹមហើយមានព្រះវចនៈថាៈ "នេះគឺការស្នើសូមគួរឲ្យរីករាយ ។" តែព្រះសាស្តា صلى الله عليه وآله وسلم សូមឲ្យអ៊ីម៉ាំអាលី صلوات الله عليه والسلام ទុកពេលឲ្យព្រះអង្គ صلى الله عليه وآله وسلم សាកសួរព្រះរាជបុត្រីព្រះអង្គ صلى الله عليه وآله وسلم សិន ។ ពេលព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ប្រាប់ព្រះរាជបុត្រីឲ្យជ្រាបអំពីការ

ស្ដីដណ្ដឹងរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ព្រះនាងហ្វាទីម៉ាស់ سلام الله عليها មិនថាអ្វីព្រោះតែអៀនខ្មាស ។ ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ក៏មានព្រះវចនៈថាៈ "ព្រះនាង سلام الله عليها មិនថាអ្វីក៏ដូចជាយល់ព្រមដែរ ។"

សម័យនោះ អ៊ីម៉ាំអាលី صلوات الله عليه والسلام មិនមានទ្រព្យអ្វីក្រៅពីដាវនិងអាវក្រោះទេ ។ ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ណែនាំព្រះអង្គ صلوات الله عليه والسلام ឲ្យយកអាវក្រោះទៅលក់ ដើម្បីចាយវាយលើពិធីអាពាហ៍ពិពាហ៍ ។ ជំនូនខាន់ស្លាព្រះនាងហ្វាទីម៉ាស់ត្រូវបានមកពីប្រាក់លក់អាវក្រោះ មានទឹកអប់ អាវដៃវែង អាវពណ៌ខ្មៅសម្រាបពាក់ក្រោយងូតទឹករួចកន្សែងទទូរក្បាល គ្រែធ្វើអំពីរោមសត្វ សរសៃត្នោត ពូកពីរធ្វើអំពីសរសៃផ្ទៃអេស៊ីបត៍ ខ្នើយបួន វាំងននមួយ ព្រំមួយ ត្បាល់កិនពីរ ចានគោមមួយធ្វើអំពីឈើសម្រាប់ដាក់ទឹកដោះគោ អាងដាក់ទឹកមួយ កូនដបនានា កងដៃប្រាក់និងចូស្ពាន់មួយ ។

ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ជាអ្នកដឹកនាំពិធីអាពាហ៍ពិពាហ៍ ក្នុងខែរ៉ម៉ាដូនឆ្នាំទី ២ នៃសករាជហ៊ីជ្រ៉េាះត៍ ។ ពួកមូហាជីរីននិងពួកអាន់ស្វារ៍បានប្រជុំគ្នាអបអរសាទរព្រះអាពាហ៍ពិពហ៍ អ៊ីម៉ាំអាលី صلوات الله عليه والسلام បានរៀបចំពិធីជប់លៀង (វ៉ាលីម៉ាស់) ជាកិត្តិយសដល់ព្រះមហេសីព្រះអង្គ صلوات الله عليه والسلام ។

ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានប្រាប់ព្រះរាជបុត្រីព្រះអង្គ صلى الله عليه وآله وسلم ឲ្យជ្រាបអំពីគុណសម្បត្តិនិងសីលធម៌របស់ព្រះស្វាមីព្រះនាង ។ បន្ទាប់មកព្រះអង្គ صلى الله عليه وآله وسلم បានបែរទៅរកអ៊ីម៉ាំអាលី صلوات الله عليه والسلام រៀបរាប់ប្រាប់ព្រះអង្គ صلوات الله عليه والسلام នូវភាពឧត្ដុង្គឧត្ដមរបស់ព្រះរាជបុត្រីព្រះអង្គ صلى الله عليه وآله وسلم ហើយព្រះអង្គ صلى الله عليه وآله وسلم មានព្រះវចនៈថាបើអ៊ីម៉ាំអាលី صلوات الله عليه والسلام មិនបានប្រសូតមកទេប្រាកដជាពុំមានបុរសណាមួយស្មើព្រះរាជបុត្រីព្រះអង្គ صلى الله عليه وآله وسلم ទេ ។ រួចហើយព្រះអង្គ صلى الله عليه وآله وسلم បែងចែកករណីយកិច្ចរបស់គូស្វាមីភរិយាទាំងពីរ ។ ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានប្រាប់ព្រះនាងហ្វាទីម៉ាស់ سلام الله عليها ឲ្យប្រកបកិច្ចការផ្ទះ ឯអ៊ីម៉ាំអាលី صلوات الله عليه والسلام ទទួលភារកិច្ចក្រៅផ្ទះ ។

អល់ឡោះហ៊ូ عز وجل បានព្រះរាជទានឲ្យគូស្វាមីភរិយាមានបុត្រប្រុសពីរនាក់ អ៊ីម៉ាំហាសាន់ صلوات الله عليه والسلام និងអ៊ីម៉ាំហ៊្សសែន៍ صلوات الله عليه والسلام មានបុត្រីពីរនាក់ ព្រះនាង ស្សៃណាប់ سلام الله عليها និងព្រះនាង អ៊ូម គុលស៊្សូម سلام الله عليها ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ឋានន្តរស័ក្តិ "ខ៌យ់រុន-នីសាអ៍ អាល់-អាឡាមីន (خَيْرُ نِسَاءِ الْعَالَمِينَ)" របស់ព្រះនាងហ្វាទីម៉ាស់ سلام الله عليها មានន័យថាអ្វី ?

២. ពេលបានប្រាប់ការស្តីដណ្តឹងរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ព្រះនាងហ្វាទីម៉ាស់ سلام الله عليها មិននិយាយស្តីទេ ។ ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានបកស្រាយការមិននិយាយស្តីនេះថាអ្វី ?

៣. ហេតុអ្វីគេហៅព្រះនាងហ្វាទីម៉ាស់ سلام الله عليها ថា "អ៊ុមមុល អាអ៊ីម៉ាស់ (أُمُّ الْأَئِمَّةِ)" ព្រះមាតារបស់ព្រះសន្តអាអ៊ីម៉ាំ عليهم السلام ?

៤. ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បែងចែកភារកិច្ចរបស់ព្រះនាងហ្វាទីម៉ាស់ سلام الله عليها និងអ៊ីម៉ាំអាលី صلوات الله عليه والسلام ដូចម្តេច ?

៥. គេហៅពិធីលៀងអាហារពិសេសរៀបចំដោយអ៊ីម៉ាំអាលី صلوات الله عليه والسلام ថាអ្វី ? តើយើងនៅតែធ្វើបែបនេះទេក្នុងអាពាហ៍ពិពាហ៍សព្វថ្ងៃនេះ ?

## មេរៀនទី ៣

# ការផ្លាស់ប្តូរគិបឡាត់

កាលអល់ឡោះហ្ហ៍ﷻបានដាក់ព្រះបញ្ញាគ្រាដំបូង ឲ្យព្រះសាស្តាមូហាំម៉ាដ់ﷺ និងមុស្លីមទាំងអស់ស្វ៉ឡាត់ប្រចាំថ្ងៃ ព្រះអង្គﷻបានឲ្យស្វ៉ឡាត់ដោយបែរមុខទៅរកបៃទុល ម៉ាក់ឌីស (بَيْتُ الْمَقْدِسِ យេរូសាឡេម) ។ ទង្វើនេះបានប្រព្រឹត្តទៅនៅឯម៉ាក់កាស្ហ៍ ហើយបានប្រព្រឹត្តបន្តទៅទៀតនៅឯម៉ាឌីណាស្ហ៍ដល់ខែទី ១៧ បន្ទាប់ពីបានភៀសខ្លួន ។

នៅម៉ាឌីណាស្ហ៍ ពួកយ៉ាហ៊ូឌីក៏ស្វ៉ឡាត់បែរមុខទៅរកបៃទុល ម៉ាក់ឌីសដែរ ។ ពួកគេមិនសប្បាយចិត្តទេដែលពួកមុស្លីមមានគិបឡាត់ដូចពួកគេដែរនោះ ពួកគេលើកយកប្រការនេះមកប្រើដើម្បីបង្ខូចអ៊ីស្លាមនិងព្រះសាស្តាមូហាំម៉ាដ់ﷺ ។ ពួកគេប្រាប់ពួកមុស្លីមថា៖ "មូហាំម៉ាដ់ﷺថាមានសាសនាដែលមានច្បាប់ដែលលើកចោលច្បាប់មុនៗទាំងអស់ តែមិនមានគិបឡាត់ដាច់ឡែកទេ គេﷺស្វ៉ឡាត់ដោយបែរមុខទៅរកគិបឡាត់របស់ពួកយ៉ាហ៊ូឌីដែរ ។"

បន្ទាប់ពីបានឮដំណឹងនេះ ព្រះសាស្តាមូហាំម៉ាដ់ﷺតែងតែចេញពីផ្ទះពេលយប់ មើលមេឃ រង់ចាំអល់ឡោះហ្ហ៍ﷻដាក់ព្រះវិវរណៈយៈ (គឺបើកឲ្យដឹង) អំពីបញ្ហានេះ ។ អាយ៉ាស្ហ៍ខាងក្រោមត្រូវបានបើកឲ្យដឹងក្នុងពេលនោះ គឺ៖

قَدْ نَرَىٰ تَقَلُّبَ وَجْهِكَ فِي ٱلسَّمَآءِ ۖ فَلَنُوَلِّيَنَّكَ قِبْلَةً تَرْضَىٰهَا ۚ فَوَلِّ وَجْهَكَ شَطْرَ ٱلْمَسْجِدِ ٱلْحَرَامِ ۚ وَحَيْثُ مَا كُنتُمْ فَوَلُّوا۟ وُجُوهَكُمْ شَطْرَهُۥ ۗ وَإِنَّ ٱلَّذِينَ أُوتُوا۟ ٱلْكِتَٰبَ لَيَعْلَمُونَ أَنَّهُ ٱلْحَقُّ مِن رَّبِّهِمْ ۗ وَمَا ٱللَّهُ بِغَٰفِلٍ عَمَّا يَعْمَلُونَ ﴿١٤٤﴾

*144. យើងបានឃើញអ្នកបែរមុខអ្នកទៅឯមេឃ ។ ដូច្នេះយើងបំបែរអ្នកទៅរកទិសមួយដែលអ្នកពេញចិត្ត ។ ដូច្នេះចូរអ្នកបែរមុខអ្នកឆ្ពោះទៅឯម៉ាស់យ៉ិដពិសិដ្ឋ ។ មិនថាឡើយពួកអ្នកនៅទីណាក៏ដោយ ចូរពួកអ្នកបែរមុខពួកអ្នកទៅរកទិសនោះ ។ បណ្តាអ្នកដែលបានទទួលព្រះគម្ពីរដឹងច្បាស់ថា នោះគឺការពិតដែលមកពីព្រះម្ចាស់ពួកគេ ។ អល់ឡោះហ្ហ៍មិនធ្វេសប្រហែសចំពោះទង្វើរបស់ពួកគេឡើយ ។ ស៊ូរ៉ោះត្ហ៍* អាល់-បាក្ហ៍រ៉ោះត្ហ៍ អាយ៉ាស្ហ៍ 144 (2:144)

មូលហេតុដែលគិប្លាត់ពួកមុស្លីមដូចគិប្លាត់ពួកយ៉ាហ៊ូឌីនោះ ព្រោះវាជាការល្បងពិសោធន៍ជំនឿមនុស្សដែរ ។ ជំនឿពិតរបស់បណ្ដាអ្នកមានជំនឿនៅលើការព្រមឬការបដិសេធបែរមុខទៅរកគិប្លាត់ថ្មី ជ្រើសរើសដោយអល់ឡោះហ៊ូ عز وجل ។ ព្រះគម្ពីរគួរអានអះអាងបញ្ជាក់រឿងនេះថា៖

وَمَا جَعَلْنَا ٱلْقِبْلَةَ ٱلَّتِى كُنتَ عَلَيْهَآ إِلَّا لِنَعْلَمَ مَن يَتَّبِعُ ٱلرَّسُولَ مِمَّن يَنقَلِبُ عَلَىٰ عَقِبَيْهِ ۚ وَإِن كَانَتْ لَكَبِيرَةً إِلَّا عَلَى ٱلَّذِينَ هَدَى ٱللَّهُ ۗ وَمَا كَانَ ٱللَّهُ لِيُضِيعَ إِيمَٰنَكُمْ ۚ إِنَّ ٱللَّهَ بِٱلنَّاسِ لَرَءُوفٌ رَّحِيمٌ ﴿١٤٣﴾

*143. ...ដែលយើងបានកំណត់ទិស (គឺគិប្លាត់) ដែលពួកអ្នកបែរទៅរកនោះ ព្រោះតែដើម្បីនឹងញែកឲ្យដឹងច្បាស់ថាអ្នកណាខ្លះប្រតិបត្តិតាមព្រះសាស្ដា អ្នកណាខ្លះវិលត្រឡប់ក្រោយ ។ ការពិតនេះជារឿងពិបាកមួយ វៀរលែងតែសម្រាប់ជនានុជនណាដែលអល់ឡោះហ៍ដឹកនាំប៉ុណ្ណោះ ។ អល់ឡោះហ៍មិនធ្វើឲ្យជំនឿរបស់ពួកអ្នកបាត់បង់ទេ ។ ការពិតអល់ឡោះហ៍ទ្រង់សព្វព្រះហឫទ័យ ព្រះអង្គទ្រង់មានព្រះមេត្តាករុណាប្រណីមនុស្សទាំងឡាយ ។* ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 143 (2:143)

ថ្ងៃមួយ ខណៈដែលព្រះសាស្ដាមូហាំម៉ាដ់ ﷺ និងមុស្លីមឯទៀតកំពុងស៊ូឡាត់ជុំគ្នា អល់ឡោះហ៊ូ عز وجل បានដាក់ព្រះរាជបញ្ជាឲ្យផ្លាស់ប្ដូរទិសពី បៃទុល ម៉ាក៏ឌីស ទៅរកព្រះមហាគ្រឹះ កាក់បាស់ នៅម៉ាក់កាស់ ។ ពេលព្រះសាស្ដាមូហាំម៉ាដ់ ﷺ ស៊ូឡាត់ស៊ូហ្វូរបានពីរ៉ក់អាត់ ទេវតាយ៉ីបរ៉អ៊ីល عليه السلام បាននាំព្រះរាជបញ្ជារបស់អល់ឡោះហ៊ូ عز وجل មកប្រាប់ព្រះអង្គ ﷺ ។

យ៉ីបរ៉អ៊ីល عليه السلام បានចាប់ដៃព្រះសាស្ដាមូហាំម៉ាដ់ ﷺ ហើយបានបំបែរព្រះអង្គ ﷺ ទៅរកព្រះមហាគ្រឹះ កាក់បាស់ នៅក្នុង ម៉ាស់យ៉ិឌុល-ហារ៉ម នៅឯម៉ាក់កាស់ ។ ព្រះសាស្ដាមូហាំម៉ាដ់ ﷺ ក៏បានផ្លាស់ទិសភ្លាមកណ្ដាលស៊ូឡាត់ ។ អ៊ីមុាំអាលី صلوات الله عليه والسلام ក៏បានធ្វើបែបនេះភ្លាមដែរ ។ មុស្លីមឯទៀតទីទើរ មានតែមួយចំនួនតូចទេដែលធ្វើតាមអ៊ីមុាំអាលី صلوات الله عليه والسلام ។

គេហៅម៉ាស់យ៉ិដដែលព្រឹត្តិការណ៍នេះបានកើតឡើងនោះថា "ម៉ាស់យ៉ិដស៊ុល-គិប្លាតែន៍ (مسجد ذو القبلتين)" មានន័យថា "ម៉ាស់យ៉ិដពីរគិប្លាត់" ។ ម៉ាស់យ៉ិដនេះគង់នៅរហូតមកដល់សព្វថ្ងៃនៅឯម៉ាឌីណាស់ ។



អាស្រ័យឧបករណ៍ទាន់សម័យ និងវិទ្យាសាស្ត្រ យើងអាចរកម៉ាឌីណាស់ឃើញនៅឯ រិត្តារន្តរ (រយៈទទឹង) ២៤ អង្សា អាយាមន្តរ (រយៈបណ្តោយ) ៣៩ អង្សា ។ កាក់បាស់ស្ថិតនៅឯ ៤៥ អង្សាខាងត្បូងម៉ាឌីណាស់ ។

ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺ បានបែរទៅរកគិប្ល៉ាត់ថ្មីឥតរួញរា ។ គេអាចឃើញបាននៅឡើយ គិប្ល៉ាត់ថ្មីនិងគិប្ល៉ាត់ចាស់នៅឯ ម៉ាស្ជិដ ស៊ិល គិប្ល៉ាតៃន៍ ។ នេះគឺអព្ភូតហេតុអស្ចារ្យមួយរបស់ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺ ដែលព្រះអង្គﷺបានបែរមុខចំព្រះមហាគ្រឹះកាក់បាស់ត្រឹម ដោយមិនបាច់ប្រើឧបករណ៍ និងការវាស់ស្ទង់វិទ្យាសាស្ត្រណាមួយឡើយ ។

ពួកអារ៉ាប់គោរពរហូតព្រះមហាគ្រឹះកាក់បាស់ ដែលប្រើជាគិប្ល៉ាត់សម្រាប់មុស្លីមទាំងអស់សព្វថ្ងៃនេះ កាលពីមុនព្រះសាស្តាមូហ៊ាំម៉ាដ់ﷺក៏ពួកគេគោរពព្រះមហាគ្រឹះកាក់បាស់នេះដែរ ។ គិប្ល៉ាត់នេះជាមូលហេតុទាក់ទាញពួកអារ៉ាប់ច្រើនឡើងមករកអ៊ីស្លាម ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. ព្រះសាស្ដាមូហាំម៉ាដ ﷺ អាចបែរមុខចំព្រះមហាគ្រឹះកាក់បាស់ បានដូចម្ដេច ?

២. កាលពីដើមហេតុអ្វីគិបឡាត់ពួកមុស្លីមដូចគិបឡាត់ពួកយ៉ាហ៊ូឌីដែរ ?

៣. គិបឡាត់ត្រូវផ្លាស់ប្ដូរកាលណា ?

៤. ការផ្លាស់ប្ដូរគិបឡាត់នេះមានលទ្ធផលអ្វី ?

៥. យើងអាចដកស្រង់បាននូវមេរៀនអ្វីពីព្រឹត្តិការណ៍នេះ ?

**មេរៀនទី ៤**

# សមរភូមិបាដារ

ពាក់កណ្តាលខែយ៉ាម៉ាដ្ឋា អាល់-អៅវ៉ាល់នៃសករាជហ៊ីចូរ៉េះត៍ (គឺក្រោយពីបានភៀសខ្លួនទៅម៉ាឌីណាស់) ម៉ាឌីណាស់បានទទួលដំណឹងថាមានក្បួនទូរចរជំនួញចេញដំណើរពីម៉ាក់កាស់ទៅកាន់ប្រទេសស៊ីរីដោយមាន អាប៊ូ ស៊ុហ្វយ៉ាន ជាអ្នកដឹកនាំ ។

ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺបានចាត់បញ្ជូនមនុស្សពីរនាក់ ទៅយកដំណឹងបន្ថែមអំពីក្បួនទូរចរជំនួញនេះ ។ ព្រះអង្គﷺឲ្យបុរសទាំងពីរស៊ើបសួរអំពីមុខព្ជួញរបស់ក្បួនទូរចរនោះ អំពីចំនួនអ្នកការពារនិងអំពីទំនិញដែលក្បួនទូរចរនោះដឹកជញ្ជូន ។ បុរសទាំងពីរប្រមូលបានព័ត៌មានដូចតទៅគឺ៖

១. នោះគឺក្បួនទូរចរធំ អ្នកស្រុកម៉ាក់កាស់ទាំងអស់មានទំនិញមួយចំណែកនៅក្នុងក្បួនទូរចរនោះ ។

២. មេដឹកនាំក្បួនទូរចរឈ្មោះ អាប៊ូ ស៊ុហ្វយ៉ាន មានអ្នកការពារ ៤០ នាក់ ។

៣. អូដ្ឋ ១០០០ ក្បាលដឹកជញ្ជូនទំនិញមានតម្លៃប្រមាណ ៥០០០០ ឌីណារ ។

ពួកគូរ៉ាយ៉ស្ហ៍បានអូសយកទ្រព្យរបស់ពួកមុស្លីមទាំងអស់ ដែលភៀសខ្លួនទៅម៉ាឌីណាស់ ។ ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺបានសម្រេចចិត្តរឹបយកទ្រព្យរបស់ពួកម៉ាក់កាស់សងវិញ ។ ពួកមុស្លីមបានដេញតាម អាប៊ូ ស៊ុហ្វយ៉ាន តែតាមមិនទាន់ ។ តែក្បួនទូរចរមានពេលវេលាត្រឡប់ទៅវិញស្ទើរតែច្បាស់លាស់ ព្រោះពួកគូរ៉ាយ៉ស្ហ៍ត្រឡប់ពីប្រទេសស៊ីរីទៅកាន់ម៉ាក់កាស់វិញនាដើមសរទៈរដូវ (ដើមរដូវធ្លាក់ខ្យល់ធ្លាក់ភ្លៀង) ។

ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺបានចាកចេញពីម៉ាឌីណាស់ទៅកាន់ច្រកភ្នំ បាដារចម្ងាយ ៨០ ម៉ៃល៍ (ប្រមាណ ១២៩ គីឡូម៉ែត្រ) ពីម៉ាឌីណាស់ ចាំក្បួនទូរចរជំនួញត្រឡប់មកវិញ ។

អាប៊ូ ស៊ុហ្វយ៉ាន ដឹងថាពួកមុស្លីមចាំគាត់នៅឯបាដ្វារដែលជាដំណាក់សម្រាកផ្លូវទៅកាន់ម៉ាក់កាស្ហ ដូច្នេះគាត់បានផ្ញើសារទៅម៉ាក់កាស្ហសូមជំនួយជាបន្ទាន់។ ពួកម៉ាក់កាស្ហក៏បានចាត់បញ្ជូនទ័ពដ៏សម្បើមមកភ្លាម ក្រោមបញ្ជាការរបស់ អាប៊ូ យ៉ាហ្វាល់ ដើម្បីប្រយុទ្ធទល់នឹងពួកមុស្លីមនៅឯបាដ្វារ។ ព្រះសាស្តាមូហ៊ាំម៉ាដ្ជ ﷺ បានទទួលដំណឹងថាម៉ាក់កាស្ហបានបញ្ជូនទ័ពមក។ ព្រះអង្គ ﷺ បានសួរពួកមុស្លីមថាតើយល់ឃើញយ៉ាងណាអំពីការប្រយុទ្ធតទល់ពួកគេ។ ទោះបីអាប៊ូ បាការ និង អ៊ុម៉ារ ចង់ត្រឡប់ទៅម៉ាឌីណាស្ហវិញក៏ដោយ តែមិត្តដ្វាដ្ជដែលជាមុស្លីមសប់ចិត្តនោះបានងើបឡើង ថា៖ "ព្រះសាស្តា ﷺ អល់ឡោះហ៍ عزّوجلّ អើយ អស់ទូលបង្គំនៅខាងព្រះអង្គ ﷺ យើងនឹងប្រយុទ្ធ។"

ព្រមនឹងពេលនោះដែរ អាប៊ូ ស៊ុហ្វយ៉ាន បានសម្រេចចិត្តត្រឡប់ទៅលំនៅវិញដោយចៀសបាដ្វារតាមផ្លូវវាង។ លុះបានចាកផុតគ្រោះថ្នាក់នៅម៉ាក់កាស្ហហើយ គាត់បានបញ្ជូនសារទៅ អាប៊ូ យ៉ាហ្វាល់ ឲ្យគាត់ត្រឡប់មកវិញ តែ អាប៊ូ យ៉ាហ្វាល់ ជាមនុស្សមានះចង់ឈ្នះមិនចង់ត្រឡប់ក្រោយវិញទេ គាត់ចង់បង្ក្រាបពួកមុស្លីមជាមួយកងទ័ពដ៏សម្បើមរបស់គាត់។

ទ័ពទាំងពីរប្រយុទ្ធគ្នាថ្ងៃទី ១៧ ខែ រ៉ម៉ាដ្ហន ឆ្នាំទី ២ នៃសករាជហ៊ីជ្រ៉ះត៏។ ទ័ពមុស្លីមមានរេហ៍ពល ៣១៣ នាក់ សរុបទាំងអស់មានសេះតែ ២ មានអូដ្ឋតែ ៧០ ទេ។ ទ័ពម៉ាក់កាស្ហមានរេហ៍ពល ៩០០ នាក់ មានសេះ ១០០ អូដ្ឋ ៧០០។ ពួកគេមានប្រដាប់ធ្វើសង្គ្រាមគ្រប់គ្រាន់ជាងពួកមុស្លីមឆ្ងាយណាស់។

តាមទំនៀមទម្លាប់អារ៉ាប់ ចម្បាំងត្រូវចាប់ផ្ដើមដោយការប្រយុទ្ធតតួ (មួយទល់មួយ)។ យុទ្ធជនដ៏ល្បីបីនាក់ឈ្មោះ អ៊ុតបាស្ហ ប៊ិន រ៉ប៊ីអ៊ាស្ហ (عُتْبَةُ بْنُ رَبِيعَةَ), ស្ហៃបាស្ហ ប៊ិន រ៉ប៊ីអ៊ាស្ហ (شَيْبَةَ بْنِ رَبِيعَةَ), វ៉ាលីដ្ហ ប៊ិន អ៊ុតបាស្ហ (وَلِيدُ بْنُ عُتْبَةَ) បបួលពួកមុស្លីមប្រយុទ្ធ។ មុស្លីមបីនាក់ឈ្មោះ អៅហ្វ៍, មូអ៊ាស្ហ (مُعاذ), អ៊ាប់ឌុលឡោះហ៍ ប៊ិន រ៉ាវ៉ាហ្វាស្ហ (بد الله بن رَواحة) ចូលមកក្នុងលានប្រយុទ្ធ។ បុរសទាំងបីនាក់នេះជាពួកអាន់ស្ហរម៉ាឌីណាស្ហ។ អ៊ុតបាស្ហបានថា៖ "យើងមិនប្រយុទ្ធទល់នឹងអស់លោកទេ។ ចូរបញ្ជូនដៃគូយើងមក ដែលមានសមត្ថភាពស្មើយើង។"

ព្រះសាស្តាមូហ៊ាំម៉ាដ្ជ ﷺ ក៏បានបញ្ជូន អ៊ុបៃដ្វាស្ហ, ហ៊ាំស្ហាស្ហ និង អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام ទៅប្រយុទ្ធតតួ។ អ៊ុបៃដ្វាស្ហប្រយុទ្ធទល់នឹងអ៊ុតបាស្ហ, ហ៊ាំស្ហាស្ហប្រយុទ្ធទល់ស្ហៃបាស្ហ, អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام ប្រយុទ្ធទល់វ៉ាលីដ្ហ។ ហ៊ាំស្ហាស្ហនិងអ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام បាន

ប្រហារគូប្រយុទ្ធយ៉ាងឆាប់ តែអ៊ូបៃដ្ហាស់ត្រូវរបួសធ្ងន់ ហើយបានទទួលមរណភាពក្រោយពីនោះ ។ អ៊ីម៉ាំអាលីﷺក៏បានប្រហារអ៊ុតបាស់ ។ ពួកគូរ៉ាយ៉ស្ទស្លន់ស្មារតីដែលបានឃើញយុទ្ធជនមុស្លីមពូកែប្រយុទ្ធ ហើយក៏បានចាប់ផ្តើមវាយសម្រុកទាំងអស់គ្នាតែម្តង ។

ព្រះសាស្តាﷺបានឲ្យទ័ពដ៏តូចរបស់ព្រះអង្គﷺនៅខាងក្រោយ ហើយបានបញ្ជាឲ្យបាញ់គ្រាប់ព្រួញស្រោចទៅលើបច្ចាមិត្ត ។ ការវាយប្រហារដ៏មានរបៀបនេះបានធ្វើឲ្យទ័ពម៉ាក់កាស់បែក ដោយឃើញពួកគេជ្រួលច្របល់ ព្រះសាស្តាﷺក៏បានបញ្ជាឲ្យទាំងអស់គ្នាចូលប្រយុទ្ធ ។ ពួកមុស្លីមប្រយុទ្ធដោយសេចក្តីអង់អាច សម្លេងប្រយុទ្ធបានលាន់ឮពេញច្រកភ្នំបាដ្ឋារ ។ អ៊ីម៉ាំអាលីﷺបានពុះបំបែកចំកណ្តាលទ័ពម៉ាក់កាស់ សម្លាប់ខ្មាំងយ៉ាងងាយគួរឲ្យរន្ធត់អនេក ។ ឥទ្ធិពលនិងការប៉ិនប្រសប់គុនដាវរបស់ព្រះអង្គﷺធ្វើឲ្យពួកម៉ាក់កាស់ភ័យស្លន់ស្លោ នាំគ្នារត់គេចលានប្រយុទ្ធ ។

មិនយូរប៉ុន្មាន ការប្រយុទ្ធបានចប់ បក្សមុស្លីមបានទទួលជ័យជំនះទោះបីមានគ្នាតិចជាងពួកសត្រូវក៏ដោយ ។

នៅក្នុងសមរភូមិនេះ បក្សមុស្លីមបានបាត់បង់យុទ្ធជន ១៤ នាក់ ចំណែកឯពួកម៉ាក់កាស់ ៧០ នាក់ រាប់ទាំងពួកមេដឹកនាំពួកគេ អាប៊ូ យ៉ាហ្វាល់, ណៅហ្វាល់, អ៊ូម៉ៃយ៉ាស់ និងច្រើននាក់ទៀតបានស្លាប់ ។ ក្នុងចំណោមបុគ្គលស្លាប់ទាំង ៧០ នាក់នេះ អ៊ីម៉ាំអាលីﷺបានសម្លាប់ ៣៦ នាក់តែម្នាក់ឯង ហើយព្រះអង្គﷺបានជួយគេសម្លាប់ច្រើននាក់ទៀត ។

៧០ នាក់ត្រូវទ័ពមុស្លីមចាប់ខ្លួនបានជាឈ្លើយសឹក ។ អ្នកស្រុកម៉ាឌីណាស់បានប្រព្រឹត្តដោយសប្បុរសធម៌ណាស់ចំពោះឈ្លើយសឹក អ្នកខ្លះបានទៅជាមុស្លីម ។ ក្រោយមកជនជាប់ចំណាប់ម្នាក់បានថា៖ "សូមព្រះជូនពរជ័យឲ្យពួកអ្នកស្រុកម៉ាឌីណាស់ ។ ពួកគេឲ្យយើងជិះសេះ ចំណែកឯខ្លួនឯងវិញសុខចិត្តដើរ ។ ពួកគេឲ្យបាយសាលីនិងនំប៉ាំងយើងបរិភោគពេលវានៅសល់តែបន្តិច ។ ចំណែកឯពួកគេសុខចិត្តបរិភោគផ្លែលម៉ើ ។"

ពួកឈ្លើយសឹកដែលសម្បូរទ្រព្យបានទិញសេរីភាព ដោយបង់ថ្លៃលោះខ្លួន ។ គេបានសូមឲ្យឈ្លើយឯទៀតបង្ហាត់ម្នាក់ៗកូនក្មេង ១០ នាក់ឲ្យចេះអាននិងចេះសរសេរ ចំណែកឯអ្នកឯទៀតត្រូវព្រះសាស្តាﷺដោះលែង អនុញ្ញាឲ្យពួកគេ

ត្រឡប់ទៅម៉ាក់កាស់វិញបាន ។

ជ័យជំនះសមរភូមិបាដ្ទារបានពង្រឹងជំនឿក្រុមមុស្លីម ហើយព្រមានពួកទមិឡ ឥតសាសនាស្រុកម៉ាក់កាស់ថាអំណឹះតទៅ អ៊ីស្លាមជាកម្លាំងមួយដែលត្រូវទទួលស្គាល់ ។ ក្នុងឆ្នាំតែមួយ អល់ឡោះហ្ជ័ﷻបានដាក់ព្រះបញ្ញាឲ្យក្រុមមុស្លីមកាន់សីលត្រណម ។ អាយ៉ាស់ព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 185) ត្រូវដាក់មកចែងអំពីរឿងនេះថា៖

شَهْرُ رَمَضَانَ ٱلَّذِىٓ أُنزِلَ فِيهِ ٱلْقُرْءَانُ هُدًى لِّلنَّاسِ وَبَيِّنَٰتٍ مِّنَ ٱلْهُدَىٰ وَٱلْفُرْقَانِ ۚ فَمَن شَهِدَ مِنكُمُ ٱلشَّهْرَ فَلْيَصُمْهُ ۖ وَمَن كَانَ مَرِيضًا أَوْ عَلَىٰ سَفَرٍ فَعِدَّةٌ مِّنْ أَيَّامٍ أُخَرَ ۗ يُرِيدُ ٱللَّهُ بِكُمُ ٱلْيُسْرَ وَلَا يُرِيدُ بِكُمُ ٱلْعُسْرَ وَلِتُكْمِلُوا۟ ٱلْعِدَّةَ وَلِتُكَبِّرُوا۟ ٱللَّهَ عَلَىٰ مَا هَدَىٰكُمْ وَلَعَلَّكُمْ تَشْكُرُونَ ﴿١٨٥﴾

*185. ខែរ៉ម៉ាដូនគឺខែដែលគេបានបើកឲ្យដឹងគួរអានជាមគ្គទេសក៍ដឹកនាំមនុស្ស ជាភ័ស្តុតាងជាក់ច្បាស់របស់មគ្គទេសក៍ដឹកនាំនិងជាលក្ខណៈវិនិច្ឆ័យ (គឺការវែកញែកឲ្យដឹងខុសត្រូវ) ។ ដូច្នេះ បុគ្គលណាមួយក្នុងចំណោមពួកអ្នកបានឃើញខែនោះជាក់ច្បាស់ហើយ ចូរឲ្យអ្នកនោះកាន់សីលត្រណមអាហារក្នុងខែនោះ ។ អ្នកណាមួយក្នុងចំណោមពួកអ្នកឈឺឬកំពុងធ្វើដំណើរ [អ្នកនោះត្រូវកាន់សីលត្រណមអាហារ]ថ្ងៃផ្សេងឲ្យស្មើចំនួនថ្ងៃទាំងនោះ ។ អល់ឡោះហ្ជ័ចង់ឲ្យពួកអ្នកងាយស្រួល ព្រះអង្គមិនចង់ឲ្យពួកអ្នកលំបាកទេ ដើម្បី[ព្រះអង្គ]នឹងឲ្យពួកអ្នកបង្គ្រប់ចំនួន[ថ្ងៃ]ឲ្យពេញលេញ ដើម្បីនឹងឲ្យពួកអ្នកលើកតម្កើងព្រះអធិកភាពរបស់អល់ឡោះហ្ជ័ ដែលព្រះអង្គបានដឹកនាំពួកអ្នក ដើម្បីពួកអ្នកនឹងដឹងព្រះគុណ ។* (2:185)

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ បានសម្រេចចិត្តវាយលុក ក្បួនទូរចរជំនួញរបស់ អាប៊ូ ស៊ុហ្វយ៉ាន ?

២. តើពួកម៉ាក់កាស់មានប្រតិកម្មអ្វីប្រឈមនឹងសង្គ្រាមនេះ ?

៣. អ្នកណាបានទទួលជ័យជំនះសមរភូមិបាដ្ឋារ ?

៤. ច្បាប់អ្វីដែលជាច្បាប់ដ៏សំខាន់មួយ ដែលអល់ឡោះហ្ ﷻ បានដាក់មកក្នុងឆ្នាំនោះ ?

៥. តើអ្នកស្គាល់អាយុរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ទេកាលនោះ ?

## មេរៀនទី ៥

# កុស់រ៉ាស់ទាំងបី

ដំណឹងពួកគូរ៉យ់ស្ស៍ច្បាំងចាញ់ក្រុមមុស្លីមក្នុងសមរភូមិបាដ្សារ បានលេចឮពេញដែនដីអារ៉ាប៊ី ។ នៅម៉ាក់កាស់ ពួកឥតសាសនាស្លុតរន្ធត់ខ្លាំងដោយសារបរាជ័យនេះ ។ ពួកគេមួយចំនួនបានថាដរាបណាមិនបានសងសឹកឲ្យមិត្តដែលបានស្លាប់នោះទេ ដរាបនោះពួកគេនឹងមិននៅស្ងៀមជាដាច់ខាត ។ ពួកយ៉ាហ៊ូឌីដែលសម្បូរទ្រព្យនៅម៉ាឌីណាស់ ខុយ់បារ និង វ៉ាឌី អាល់-គូរ៉ (وَادِي اَلْقُرَى) ភ័យរំជើបរំជួលដែលក្រុមមុស្លីមមានឥទ្ធិពលនិងល្បីខ្លាំងឡើងយ៉ាងឆាប់រហ័ស ។ ដូច្នេះឯងបានជាក្រុមទាំងពីរនេះបានក្លាយទៅជាសត្រូវស្លាប់រស់របស់ក្រុមមុស្លីម ។

ពួកយ៉ាហ៊ូឌី បានី កូយ់នូក៏អ៊ុ (بَنِي قَيْنُقَاعَ) រស់នៅម៉ាឌីណាស់ជាមួយពួកមុស្លីម ពួកគេគ្រប់គ្រងការជួញដូរក្នុងស្រុកច្រើនជាងគេ ។ ដើម្បីរំលាយកម្លាំងក្រុមមុស្លីម ពួកយ៉ាហ៊ូឌីទាំងនេះផ្សាយដំណឹងចចាមអារ៉ាមបង្ខូចអ៊ីស្លាម ចំអកដាក់អាយ៉ាស់ព្រះគម្ពីរគូរអាន ។

ព្រះសាស្ដាមូហាំម៉ាដ្ ﷺ បានសម្រេច បញ្ឈប់សកម្មភាពប្រកបដោយគ្រោះថ្នាក់របស់ពួកយ៉ាហ៊ូឌីនោះ ។ ព្រះអង្គ ﷺ បានប្រកាសព្រមានពួកយ៉ាហ៊ូឌីនៅឯទីផ្សាររបស់ពួក បានី កូយ់នូក៏អ៊ុ ថា៖ "កម្មវាសនារបស់ពួកគូរ៉យ់ស្ស៍ជាមេរៀនសម្រាប់ពួកគេនិងជាមេរៀនសម្រាប់អស់លោកដែរ ។ ខ្ញុំ ﷺ ក្រែងតែកម្មវាសនាដូចនោះដែរនឹងរង់ចាំអស់លោកនៅពេលខាងមុខ បើអស់លោកនៅតែប្រព្រឹត្តបែបនេះ ។ មានអ្នកចេះដឹងសាសនាច្រើននៅក្នុងចំណោមអស់លោក អស់លោកអ្នកចេះដឹងទាំងនោះនឹងអះអាងបញ្ជាក់ថាខ្ញុំ ﷺ ជាព្រះសាស្ដារបស់អល់ឡោះហ៊ូ ﷻ ពិតមែន ព្រោះនៅក្នុងព្រះគម្ពីរតៅរ៉ែតរបស់អស់លោកមានចែងរឿងនេះដែរ ។"

សម្ដីរបស់ព្រះសាស្ដា ﷺ ពុំមានឥទ្ធិពលលើពួកយ៉ាហ៊ូឌីមានះទេ ពួកគេបានឆ្លើយតបថាខ្លួនមិនខ្សោយដូចពួកគូរ៉យ់ស្ស៍ទេ ហើយនៅតែនិយាយប្រមាថ មើលងាយ ។ ព្រះសាស្ដា ﷺ បានឆ្លើយតបពួកគេដោយរំលឹកអំពីច្បាប់រដ្ឋធម្មនុញ្ញអ៊ីស្លាមដែលដឹកនាំស្រុកម៉ាឌីណាស់ ហើយបានព្រមានពួកគេកុំឲ្យល្មើសច្បាប់ ។

ពួកយ៉ាហ៊្វូឌីជឿជាក់លើកម្លាំងខ្លួនណាស់ ដូច្នេះពួកគេនៅតែព្រហើនដាក់ក្រុមមុស្លីម ។ ពួកគេរង់ចាំតែយកលេសមួយដើម្បីបង្ខំក្រុមមុស្លីមឲ្យវាយប្រហារពួកគេ ។

ថ្ងៃមួយ ស្ត្រីមុស្លីមទៅផ្សារពួក បានី កូយ៉ន់នូក៏អ៊ុ ឈ្មួញយ៉ាហ៊្វូឌីឲ្យស្ត្រីនោះបើកក្រណាត់បិទមុខចេញដើម្បីឲ្យគាត់ឃើញមុខគាត់ ។ ពេលស្ត្រីនោះបដិសេធ មានគេម្នាក់ហែកសំលៀកបំពាក់ស្ត្រីនោះ បណ្តាលឲ្យឃើញមួយប៉ែកនៃខ្លួនស្ត្រីនោះពេលគាត់ងើបឈរ ។ ពេលឃើញគេមើលងាយស្ត្រីនោះបែបនេះ បុរសមុស្លីមម្នាក់នៅទីនោះបានវាយឈ្មួញយ៉ាហ៊្វូឌីស្លាប់ ។ ពួកយ៉ាហ៊្វូឌីទាំងអស់គ្នាបានបែរទៅរកបុរសមុស្លីមម្នាក់ឯង វាយសម្លាប់គាត់ ។

ក្រុមមុស្លីមក្រោធណាស់ពេលបានដំណឹង ថាពួកយ៉ាហ៊្វូឌីបានប្រួតគ្នាវាយបុរសមុស្លីមម្នាក់ឯង ។ ពួកយ៉ាហ៊្វូឌីដឹងខ្លួនថាស្ថានការណ៍ដុនដាបខ្លាំងក៏បានចោលការជួញដូរ រត់ទៅពួនក្នុងលំនៅដែលស្ថិតនៅក្នុងបន្ទាយ នៅឯខាងក្រៅស្រុកម៉ាឌីណាស់ ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបានបញ្ជាឲ្យក្រុមមុស្លីមឡោមព័ទ្ធបន្ទាយ ១៥ ថ្ងៃក្រោយមកពួកយ៉ាហ៊្វូឌីសូមចុះចាញ់ ។ ប្តូរនឹងការលើកលែងទោសឲ្យពួកគេ ពួកយ៉ាហ៊្វូឌីព្រមចាកចេញពីម៉ាឌីណាស់លែងត្រឡប់មកវិញជាដាច់ខាតដោយព្រមចោលអាវុធនិងទ្រព្យ ។

ទោះបីក្រុមមុស្លីមបានរួចផុតពីឥទ្ធិពលអាក្រក់របស់ពួក បានី កូយ៉ន់នូក៏អ៊ុ ក៏ដោយ តែពួកគេនៅតែរងអំពើក្បត់ច្រើនទៀតគ្រប់ពេល ។ តទៅនេះយើងនឹងលើកឡើងនូវគុស្ស៊ូវ៉ាស់ខ្លះ ។ គុស្ស៊ូវ៉ាស់ (غَزْوَة) មានន័យថាចម្បាំងដែលព្រះសាស្តាមូហាំម៉ាដ់ﷺបានចូលរួមផ្ទាល់ ។

## ១. គុស្ស៊ូវ៉ាទុល-គុដូរ៍ (غَزْوَةُ الْكُدْرِ ឬ គុស្ស៊ូវ៉ាទុល-កាដ្វារ)

ប្រជាជាតិ (ឬកុលសម្ព័ន្ធ) បានី សាលីម (ឬ បានី ស៊ូឡៃម៍) រស់នៅឯតំបន់មួយហៅថា អាល់-គុដូរ៍ ឬ កាដ្វារ ។ ដំណឹងបានឮមកដល់ម៉ាឌីណាស់ថាប្រជារាស្ត្រនេះប្រមូលកម្លាំងប្រដាប់អាវុធដើម្បីវាយលុកក្រុមមុស្លីម ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបានទៅកាន់កាដ្វារជាមួយទ័ពមួយកងតូច ។ តែពួកសត្រូវ ពេលបានដំណឹងថាព្រះសាស្តាមូហាំម៉ាដ់ﷺបានធ្វើដំណើរមកកាន់ទីនេះ ក៏បានបែកខ្ញែកគ្នា

អស់ ។ ព្រះអង្គﷺក៏បានត្រឡប់ទៅវិញដោយពុំបានប្រយុទ្ធ ។ ក្រោយមក ព្រះអង្គﷺបានចាត់បញ្ជូនកងទ័ពមួយទៀត លើកនេះពួកគេបានប្រយុទ្ធគ្នាទល់នឹងពួក បានី សាលីម ហើយបាននាំជ័យជំនះត្រឡប់មកម៉ាឌីណាស់វិញ ។

## ២. គុស្សវ៉ាទុស-សាវីក្វ (غَزْوَة السَّوِيق)

នៅម៉ាក់កាស់ អាប៊ូ ស៊ុហ្វយ៉ាន បានស្បថថានឹងសងសឹកវិញដែលបានចាញ់សមរភូមិបាដារ ។ គាត់បាននាំរេហ៍ពល ២០០ នាក់ចេញទៅបង្កបញ្ហា ។ គាត់មិនមានទ័ពខ្លាំងគ្រាន់បើដើម្បីអាចវាយម៉ាឌីណាស់ទល់មុខគ្នាបានទេ ។ ដូច្នេះអាស្រ័យជំនួយរបស់ប្រជាជាតិយ៉ាហ៊ូឌី បានី ណាឌៀរ (بَنِي النَّضِير) គាត់បានវាយលុកក្រុមមុស្លីមនៃតំបន់អ៊ូរ៉យដ៍ (عُرَيْد) បានសម្លាប់បុរសមុស្លីមម្នាក់ បានដុតបំផ្លាញចម្ការលម៉ើ ។ ពេលបានទទួលដំណឹងឧប្បត្តិហេតុ ព្រះសាស្តាមូហាំម៉ាដ់ﷺនិងកងទ័ពព្រះអង្គﷺបានដេញតាម អាប៊ូ ស៊ុហ្វយ៉ាន និងទ័ពរបស់គាត់ ។ ពួកសត្រូវបានរត់គេចខ្លួន ចោលថង់ម្សៅ "សាវីក្វ" (គឺចំណីធ្វើអំពីម្សៅនិងផ្លែលម៉ើ) ។ ក្រុមមុស្លីមបានយកថង់ម្សៅទាំងនោះ ហើយហៅគុស្សវ៉ាស់ (សមរភូមិ) នេះថា គុស្សវ៉ាទុស-សាវីក្វ ។

## ៣. គុស្សវ៉ាស់ ស៊ី អាម៉ារ (غَزْوَةُ ذِي أَمَرٍّ)

ម៉ាឌីណាស់បានដំណឹងថាប្រជាជាតិគ៏ត្ហ្វាន់ (غطفان) ប្រមូលគ្នាដើម្បីវាយក្រុមមុស្លីមនិងដើម្បីវាយយកម៉ាឌីណាស់ ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបាននាំរេហ៍ពល ៤៥០ នាក់ទៅប្រឈមនឹងបច្ចាមិត្ត ។ ពួកសត្រូវភ័យ រត់ទៅពួននៅឯភ្នំ ។ ព្រមនឹងពេលនោះ ភ្លៀងធ្លាក់ទទឹកសំលៀកបំពាក់ព្រះសាស្តាﷺ ។ ព្រះអង្គﷺបានដោះអាវក្រៅដាក់ហាលលើមែកឈើ ។ បច្ចាមិត្តម្នាក់ឃើញព្រះសាស្តាﷺគ្មានអាវុធក៏បានចុះពីលើភ្នំទៅគំរាមព្រះអង្គﷺដោយដាវ ថា៖ "អ្នកណាអាចជួយជីវិតឯងបានពេលនេះ ?" ព្រះសាស្តាﷺបានឆ្លើយវិញដោយស្ងប់ថា៖ "អល់ឡោះហ្ជ័ ﷻ ។" បុរសបច្ចាមិត្តឃើញព្រះសាស្តាﷺឆ្លើយដោយសេចក្តីទុកចិត្តក៏ភ្ញាក់ផ្អើលខ្លាំង ទប់អារម្មណ៍មិនបាន បណ្តាលឲ្យគាត់ញ័រខ្លួន ។ ព្រះសាស្តាﷺក៏

បានចាប់យកដាវគាត់ ហើយថា៖ "អ្នកណាអាចជួយជីវិតលោកបានពេលនេះ ?" បុរសនេះធ្វើសក្ការៈព្រះរូបចម្លាក់ គាត់ដឹងខ្លួនថាព្រះនានារបស់គាត់ធ្វើអំពីឈើនោះមិនអាចជួយជីវិតគាត់បានទេ គាត់ក៏ទទួលស្គាល់ថា៖ "ពុំមានអ្នកណាអាចជួយជីវិតខ្ញុំបានទេ ។"

ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ ពុំបានធ្វើអ្វីបុរសនោះទេ ។ បុរសនោះបានទៅជាមុស្លីម កាន់សាសនាខ្ជាប់ខ្ជួនលុះស្លាប់ ។

នាដើមសម័យអ៊ីស្លាមនោះ ក្រុមមុស្លីមចាំបាច់ត្រូវការពារសាសនាខ្លួនច្រើនលើក ច្រើនគ្រា ។ តែពួកគេមិនដែលព្រមចុះចាញ់ឡើយក្រោមសម្ពាធបណ្តាប្រជាជាតិជិតខាង ដែលមិនអាចស៊ូទ្រាំបានក្រោមអំណាចអ៊ីស្លាមដែលកាន់តែរីកធំឡើងៗនោះ ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. ពួកយ៉ាហ៊ូឌី បានី កូយ៉ន់នូក្វ៉អ៊ុំ បានធ្វើដូចម្ដេចដើម្បីបង្ខំក្រុមមុស្លីមឲ្យប្រយុទ្ធ ?

២. ការប្រព្រឹត្តរបស់ពួកយ៉ាហ៊ូឌីទាំងនោះបានទទួលផលអ្វី ?

៣. កុស្ស៉វ៉ាស្វ៉គឺអ្វី ?

៤. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺមិនធ្វើអ្វីបុរស ដែលប៉ងសម្លាប់ព្រះអង្គﷺ ?

៥. ហេតុអ្វីក្រុមមុស្លីមត្រូវពួកជិតខាងធ្វើបាបឥតស្រាក ?

## មេរៀនទី ៦

# សមរភូមិ អ៊ូហ៊្លុដ - ភាគ ១

ពួកម៉ាក់កាស៊ូប្តូរផ្តាច់សងសឹកបរាជ័យសមរភូមិបាដ្រារ ។ បណ្តាស្ត្រីមិនសុខចិត្តឲ្យបណ្តាជើងឯករបស់ខ្លួនត្រូវក្រុមមុស្លីមសម្លាប់ដោយងាយៗទេ ដូច្នេះបណ្តាស្ត្រីម៉ាក់កាស៊ូឥតសាសនា និយាយចំអកអំពីចំណុចខ្សោយរបស់បណ្តាបុរសមុស្លីម ។ អាប៊ូ ស៊ុហ្វយ៉ានចង់បង្កាត់ភ្លើងកំហឹងប្រជាស្ត្រុឲ្យនៅតែឆេះឆួល គាត់បានហាមមិនឲ្យធ្វើពិធីកាន់ទុកទេ ដរាបណាមិនទាន់បានសងសឹកឲ្យមិត្តទាំងអស់ដែលបានស្លាប់នោះឲ្យបានចប់សព្វគ្រប់សិនទេ ។ ពួកយ៉ាហ៊្វូឌីខ្លះដែលបានតែងកំណាព្យញុះញង់ឲ្យធ្វើសង្គ្រាមនោះ បានធ្វើឲ្យពួកម៉ាក់កាស៊ូកាន់តែកម្រើកអារម្មណ៍ខ្លាំងឡើង ។

ពេលព្រះសាស្តាមូហ៊ាំម៉ាដ្ឋ៌ﷺបានរារាំងផ្លូវ ក្បួនទូរចរជំនួញរបស់ពួកគូរ៉យស៊្ហ៍ទៅកាន់ស្រុកអ៊ីរ៉ាក់ វាជាមូលហេតុធ្វើឲ្យពួកម៉ាក់កាស៊ូទ្រាំលែងបាន ។ មេដឹកស្រុកម៉ាក់កាស៊ូបានសម្រេចថាពេលនេះមានមូលហេតុគ្រប់គ្រាន់ ដើម្បីវាយពួកមុស្លីម ។ ពួកឈ្មួញគូរ៉យស៊្ហ៍នឹងអាចមានផ្លូវសម្រាប់ក្បួនទូរចរជំនួញខ្លួនវិញបានបើច្បាំងឈ្នះពួកមុស្លីម ។ ដូច្នេះ ពួកគេយល់ព្រមចំណាយសោហ៊ុយសង្គ្រាមទាំងអស់ ។

អាប៊ូ ស៊ុហ្វយ៉ាន ដឹងថាពួកមុស្លីមក្លាហាន ហើយគាត់ដឹងថាត្រូវមានរេហ៍ពលច្រើនជាងពួកមុស្លីមដើម្បីឈ្នះសង្គ្រាម ។ ដូច្នេះគាត់បានហៅពួកប្រជាជាតិគីណាណាស៊ូ (كِنَانَة) និងប្រជាជាតិស្ហាគ៊ីហ្វ (ثقيف) មកចូលរួម ដោយសន្យាផ្តល់អាវុធនិងស្បៀងសម្រាប់ធ្វើដំណើរ ។

ពួកទាសៈបម្រើគេមួយចំនួនធំបានចូលរួមជាមួយពួកគូរ៉យស៊្ហ៍ដែរ ដោយសង្ឃឹមថាគេនឹងដោះលែងខ្លួនឲ្យមានសេរីភាព ។ ក្នុងចំណោមទាសៈទាំងនេះមានវ៉ាស៊្ហ៍ស៊្ហ៊ី (وحشي) ទាសៈជាតិអេត្យូពី ។ គាត់ពូកែខាងប្រើលំពែង ។ គេបានសន្យាគាត់ថានឹងដោះលែងគាត់ឲ្យមានសេរីភាពបើគាត់សម្លាប់ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ៌ﷺ អ៊ីម៉ាំអាលីصلوات الله عليه والسلامឬហ៊ាំស្ហាស៊ូ ។

ដូច្នេះ អាប៊ូ ស៊ុហ្វយ៉ាន ប្រមូលបាននូវកងទ័ពមួយដ៏ធំ មានរេហ៍ពលប្រដាប់គ្រោះ ៧០០ នាក់ មានរេហ៍ពលអូដ្ឋ ៣០០០ នាក់ មានរេហ៍ពលសេះ ២០០ នាក់ និងមានរេហ៍ពលថ្មើជើងមួយក្រុម ។ ទ័ពនេះសំដៅមុខព្រួញទៅកាន់ម៉ាឌីណាស្ញ៉ូ បានបោះជំរំនៅឯជើងភ្នំអ៊ូហ៊្វុដថ្ងៃទី ៥ ខែស្ហៅវ៉ាល់ ឆ្នាំទី ៣ នៃសករាជហ៊ីជ្រ៉ោះត៍ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានដឹងផែនការណ៍របស់ពួកគូរ៉យស្ញ៍ តាមរយៈអាប់បាស់ ឪពុកធំព្រះអង្គﷺដែលរស់នៅឯម៉ាក់កាស្ញ៉ូ ។ បន្ទាប់ពីបានប្រឹក្សាជាមួយពួកមុស្លីម ព្រះអង្គﷺបានសម្រេចប្រយុទ្ធមនឹងពួកសត្រូវនៅក្រៅព្រំប្រទល់ម៉ាឌីណាស្ញ៉ូដោយមានមូលហេតុបីគឺ៖

១. ប្រយុទ្ធទល់មុខគ្នាតាមផ្លូវចង្អៀតម៉ាឌីណាស្ញ៉ូនឹងធ្វើឲ្យបែកបាក់ យុទ្ធជននឹងពុំអាចជុំគ្នាបានទេដើម្បីទប់ទល់ពួកសត្រូវ ។ ម្យ៉ាងទៀត ពេលសត្រូវចូលមកដល់ក្នុងស្រុក ក្មេងៗនិងស្ត្រីនឹងរងគ្រោះថ្នាក់ ។

២. សត្រូវអាចឡោមព័ទ្ធស្រុក អាចកាន់ក្តាប់ផ្លូវចេញទាំងអស់ទៅខាងក្រៅស្រុកបាន ។ ការឡោមព័ទ្ធបែបនេះអាចធ្វើឲ្យពួកមុស្លីមបាក់ទឹកចិត្ត ។

៣. ព្រះសាស្តាមូហាំម៉ាដ់ﷺមិនទុកចិត្តពួកមានពុតត្បុត ដូចជាអាប់ឌុលឡោះហ្ញ៍ អ៊ូបៃ ជាដើម ខ្លាចពួកនេះបៀតបៀនពួកមុស្លីមនៅក្នុងស្រុកតែម្តង ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបាននាំរេហ៍ពល ១០០០ នាក់ទៅកាន់អ៊ូហ៊្វុដ មានចម្ងាយ ៥ គីឡូម៉ែត្រពីម៉ាឌីណាស្ញ៉ូ ។ អាប់ឌុលឡោះហ្ញ៍ អ៊ូបៃ ដែលចង់ប្រយុទ្ធនៅឯម៉ាឌីណាស្ញ៉ូនោះ បានរត់ចោលទ័ពមុស្លីមជាមួយបក្សពួក ៣០០ នាក់ ។ គាត់បានយកលេសសថាព្រះសាស្តាﷺស្តាប់តែក្មេងៗ មិនស្តាប់គាត់ទេ ។ ដូច្នេះ ព្រះសាស្តាមូហាំម៉ាដ់ﷺនៅសល់រេហ៍ពលតែ ៧០០ នាក់ទេ ។ មានតែ ១០០ នាក់ទេដែលប្រដាប់គ្រោះ ហើយមានតែសេះពីរគត់ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានរៀបចំទ័ពដើម្បីចូលប្រយុទ្ធ ។ ខ្មាន់ធ្នូ ៥០ នាក់

ត្រូវដាក់នៅត្រង់ចន្លោះទួលអ៊ូហ៊្វូដទាំងពីរ ដើម្បីការពារការវាយប្រហារប៉ែកខាងក្រោយទ័ព ។ ពួកគេទាំងនេះបានទទួលបញ្ជាកុំឲ្យចាកចេញពីកន្លែងខ្លួនជាដាច់ខាត ទោះបីការប្រយុទ្ធមានលទ្ធផលចុងក្រោយដូចម្តេចក៏ដោយ ។

ព្រះសាស្តាﷺដឹងច្បាស់ថា បក្សមុស្លីមនឹងបារម្ភដែលពួកសត្រូវមានគ្នាច្រើនជាង ។ ដូច្នេះឯងបានជាព្រះអង្គﷺកម្លាចិត្តពួកគេថា៖ "ប្រយុទ្ធនឹងសត្រូវជាភារកិច្ចលំបាក មានតែអ្នកដែលអល់ឡោះហ្ ﷻដឹកនាំនិងគាំទ្រទេដែលរឹងប៉ឹងស្មារតី ឥតប្រែប្រួល ។ ចូរអស់លោកចងចាំថាអល់ឡោះហ្ ﷻនៅខាងអ្នកណាដែលស្តាប់បង្គាប់ព្រះអង្គ ﷻ ចំណែកឯស្ហៃតូន ﷹ ជាបក្សពួករបស់អ្នកណាដែលស្តាប់វា ﷹ ។ ចូរអស់លោករឹងប៉ឹងនៅក្នុងយ៉ីហាដ្ឋ នេះជាឱកាសសម្រាប់ទទួលបាននូវព្រះពរដែលអល់ឡោះហ្ ﷻបានសន្យាឲ្យអស់លោក ។ បើអល់ឡោះហ្ ﷻមិនបានសម្រេចទេ នឹងពុំមានអ្នកណាមួយស្លាប់ទេក្នុងលោកនេះ ។" បន្ទាប់មក ព្រះអង្គﷺមានព្រះវចនៈប្រាប់ពួកគេថា បើពួកគេមិនបានទទួលបញ្ជាឲ្យប្រយុទ្ធទេ ចូរកុំឲ្យពួកគេចាប់ផ្តើមប្រយុទ្ធ ។

ខាងម៉ាក់កាស្វិញ អាប៊ូ ស៊ុហ្វយ៉ាន បានចែកទ័ពជា ៣ រេហ៍ពលប្រដាប់អាវុធត្រូវដាក់ចំកណ្តាល ។ បក្សពួកគាត់ត្រៀមខ្លួនរួចរាល់ជាស្រេច ។ ទ័ពមុស្លីមដ៏តូចដែលបានប្តេជ្ញាចិត្តបូជាជីវិតដើម្បីការពារអ៊ីស្លាមនោះ ប្រឈមមុខទល់នឹងទ័ពទមិឡឥតសាសនាដ៏សម្បើម ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. សមរភូមិអ៊ូហ៊្វដូបានកើតឡើងដោយមានមូលហេតុពិសេសអ្វី ?

២. ហេតុអ្វី អាប៊ូ ស៊ុហ្វយ៉ាន ចង់ឈ្នះជាដាច់ខាត ?

៣. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺបានសម្រេចថា មិនប្រយុទ្ធគ្នានៅក្នុងស្រុកម៉ាឌីណាស់ទេ ?

៤. ព្រះសាស្តាមូហាំម៉ាដ់ﷺបានសន្យាអ្វីឲ្យក្រុមមុស្លីម នៅក្នុងសុន្ទរកថាព្រះអង្គﷺមុនប្រយុទ្ធ ?

៥. ម្ចាស់របស់វ៉ាស់ស៊្គីបានសន្យាអ្វីឲ្យគាត់ ?

## មេរៀនទី ៧

# សមរភូមិ អ៊ូហ៊្វុដ - ភាគ ២

បុរសដែលបានចាប់ផ្តើមសមរភូមិអ៊ូហ៊្វុដឈ្មោះ ត្វល់ហាស៊ុ បិន អាប៊ី ត្វល់ហាស៊ុ (طَلْحَةَ بْنِ أَبِي طَلْحَةَ) យុទ្ធជនល្បីល្បាញរបស់ទ័ព អាប៊ូ ស៊ុហ្វយ៉ាន ។ គាត់បានចូលក្នុងលានប្រយុទ្ធដោយបបួលក្រុមមុស្លីមប្រយុទ្ធតតួ មួយទល់មួយ ។ អ៊ីមុាំអាលីصلوات الله عليه والسلامទទួលការបបួលប្រយុទ្ធតតួ ខ្លួនត្វល់ហាស៊ុរលំទៅលើដី ក្លាយជាសាកសពយ៉ាងរហ័ស ។ ទង់ត្រូវបងប្អូនប្រុសពីរនាក់របស់ត្វល់ហាស៊ុចាប់កាន់ តែទាំងពីរនាក់បានស្លាប់ដោយត្រូវគ្រាប់ព្រួញពួកមុស្លីម ។

បន្ទាប់មក បុរសម៉ាក់កាស៊ុប្រាំបួននាក់បានចាប់ទង់កាន់ បន្តបន្ទាប់គ្នា តែម្នាក់ៗត្រូវអ៊ីមុាំអាលីصلوات الله عليه والسلامបញ្ជូនទៅកាន់ឋាននរក ។ ក្រោយពីនោះ យុទ្ធជនម្នាក់ជនជាតិអេត្យូពីឈ្មោះ សាវ៉ាប់ ចូលក្នុងលានប្រយុទ្ធ ។ មុខគាត់គួរឲ្យខ្លាច ពេលឃើញគាត់ពុំមានមុស្លីមណាម្នាក់ហ៊ានចូលប្រយុទ្ធទេ ។ បុរសនេះត្រូវអ៊ីមុាំអាលីصلوات الله عليه والسلامប្រហារតែមួយខ្ទាប់ ។

ឃើញបក្សពួកខ្លួនត្រូវសម្លាប់ដោយស្រួលៗ អាប៊ូ ស៊ុហ្វយ៉ាន បញ្ជាឲ្យវាយលុកស្រុះគ្នា ។ ទ័ពទាំងពីរបានប្រឈមទល់មុខគ្នា សម្លេងអាវុធប៉ះទង្គិចគ្នាបានលាន់ឮរន្ទឺពេញបរិយាកាស ។ ខាងមុស្លីម ហ៊ាំស្សាស៊ុ رضي الله عنه, អាប៊ូ ឌូយ៉ាណាស៊ុ رضي الله عنه (أَبُو دُجَانَةَ) និងអ៊ីមុាំអាលីصلوات الله عليه والسلامបានសម្តែងឲ្យឃើញវីរៈភាពនិងសេចក្តីអង់អាចក្លាហាន បណ្តាលឲ្យមានការជ្រួលច្របល់ក្នុងទ័ព អាប៊ូ ស៊ុហ្វយ៉ាន ។

ព្រមនឹងពេលនោះ វ៉ាស៊ុស៊្យី ទាសៈអេត្យូពី លបទៅនៅពីក្រោយហ៊ាំស្សាស៊ុ ដោយមិនឲ្យលោកرضي الله عنهដឹងខ្លួន ។ បុរសត្រូវបណ្តាសារូបនេះបានចោលលំពែងយ៉ាងលឿននិងត្រង់ត្រូវពោះហ៊ាំស្សាស៊ុ رضي الله عنه សម្លាប់លោកرضي الله عنه ។



ក្រុមមុស្លីមបន្តការវាយប្រហារ ពួកសត្រូវប្រកបដោយជោគជ័យ ពួកម៉ាក់កាស៊ុចាប់ផ្តើមបាក់ទឹកចិត្ត ។ បន្ទាប់ពីបានបាត់បង់រេហ៍ពលច្រើន ពួកគេបានសម្រេចដកថយ រត់គេចលាន

ប្រយុទ្ធ ។

ពេលនេះឯងដែលពួកមុស្លីមបានធ្វើខុសធ្ងន់ បណ្តាលឲ្យវិនាសធំ ។ ពួកគេគួរតែធ្វើតាមបញ្ជាព្រះសាស្តាﷺ ដោយដេញតាមពួកសត្រូវក្រៅលានប្រយុទ្ធ ផ្ទុយទៅវិញពួកគេទម្លាក់អាវុធទៅប្រមូលទ្រព្យសង្គ្រាម ។

គិតថាការប្រយុទ្ធបានចប់រួចរាល់ ខ្មាន់ធ្នូភាគច្រើនដែលការពារច្រកចន្លោះទួលពីរបានចាកចោលកន្លែងយាមទៅប្រមូលទ្រព្យសង្គ្រាម ដោយល្មើសបញ្ជាមេបញ្ជាការ ។

មេបញ្ជាការទ័ពម៉ាក់កាស្ហ៍ម្នាក់ឈ្មោះ ខ៊ុលីដ្ជ ប៊ិន វ៉ាលីដ្ជ កំពុងតែរត់បាក់ទ័ពស្រាប់តែឃើញឱកាសល្អដើម្បីវាយប្រហារពួកមុស្លីមបកពីក្រោយ ។ គាត់បានប្រមូលរេហ៍ពល វាយសម្រុកពេញទំហឹងពីក្រោយ ។

ក្រុមមុស្លីមភ្ញាក់ផ្អើល ស្លន់មិនដឹងធ្វើអ្វីកើត ។ នៅក្នុងការជ្រួលច្របល់ ពួកគេបែកបាក់ជួរ រប៉ាត់រប៉ាយ ។ ពួកម៉ាក់កាស្ហ៍ដែលបានដកថយបាក់ទ័ពនោះក៏បានប្រមូលផ្តុំគ្នាជាថ្មីដើម្បីវាយលុកពីមុខ ។

ខ្មាន់ទង់មុស្លីមឈ្មោះ មុស្ហ្អាប់ ប៊ិន អ៊ុម៉ៃរ៍ (مصعب بن عمير) ត្រូវសម្លាប់ ។ មុខគាត់ស្រដៀងព្រះសាស្តាﷺមូហ៊ាំម៉ាដ្ជ៍ﷺណាស់ ពួកម៉ាក់កាស្ហ៍ក៏បានស្រែកថាព្រះសាស្តាមូហ៊ាំម៉ាដ្ជ៍ﷺស្លាប់ហើយ បណ្តាលឲ្យពួកមុស្លីមរឹតតែជ្រួលច្របល់និងស្រងាកចិត្តខ្លាំងឡើង ។

ឥស្សរជនមុស្លីមល្បីៗច្រើននាក់បាត់បង់សេចក្តីក្លាហាន ។ ខ្លះទៀត ដែលទន់ខ្សោយដូចជា អាប៊ូ បាការ និង អ៊ុម៉ារ ប៊ិន ខ៊ុត្តុតប់ ជាដើម បានបោះអាវុធចោលដោយថាបើអត់ព្រះសាស្តាﷺហើយ ប្រយុទ្ធតទៅទៀតក៏លែងមានប្រយោជន៍ដែរ ។ អ៊ុស្ហ្ម៉ានក៏បានរត់ចោលលានប្រយុទ្ធដែរ គាត់រត់បានឆ្ងាយណាស់ រត់អស់ ៣ ថ្ងៃទើបត្រឡប់មកម៉ាឌីណាស្ហ៍វិញ ។

នៅឯនាយ យុទ្ធជនអង់អាចច្រើននាក់ដែលនៅតែស្ម័គ្រស្មោះ បានសម្រុកចូលទៅក្នុងជួរម៉ាក់កាស្ហ៍ ប្តូរផ្តាច់ប្រយុទ្ធលុះផុតដង្ហើម ។ សកម្មភាពប្រយុទ្ធមានដំណើរការតទៅមុខបែបនេះលុះបុរសមុស្លីមម្នាក់បានឃើញព្រះសាស្តាﷺ គាត់ក៏បានស្រែកយ៉ាងខ្លាំងតាមដែលធ្វើបាន ថាព្រះសាស្តាមូហ៊ាំម៉ាដ្ជ៍ﷺនៅរស់ទេ ។

ក្រុមមុស្លីមភ្ញាក់រលឹកស្មារតីឡើងវិញ តែពេលនេះព្រះសាស្តាមូហ៊ាំម៉ាដ្ជ៍ﷺក្លាយទៅជាទិសដៅចម្បងរបស់ពួកម៉ាក់កាស្ហ៍ ។ ពួកម៉ាក់កាស្ហ៍វាយសម្រុកទៅលើ

ព្រះអង្គﷺ ធ្មេញមុខលើពីររបស់ព្រះអង្គﷺត្រូវបាក់ក្រោមផ្លែដាវបុរសម៉ាក់កាស្ម់ម្នាក់ ។ ព្រះអង្គﷺបានធ្លាក់ទៅក្នុងអន្លង់មួយកាលអ៊ីម៉ាំអាលី صلوات الله عليه والسلام ជួបព្រះអង្គﷺការពារព្រះអង្គﷺពីការវាយប្រហារយ៉ាងសកម្មពីសំណាក់ទ័ពម៉ាក់កាស្ម់ ។ អ្នកស្មោះត្រង់ច្រើននាក់ទៀត រាប់បញ្ចូលលោកស្រី អ៊ុម អាំម៉ារ៉ោះត៍ (أم عمارة رضي الله عنها) ដែរបានរារាំងពួកសត្រូវកុំឲ្យចូលជិតព្រះសាស្តាﷺ បានការពារព្រះអង្គﷺពីគ្រាប់ព្រួញដែលបាញ់ស្រោចមកលើដូចទឹកភ្លៀង ។

នៅក្នុងសមរភូមិនេះឯងដែលអ៊ីម៉ាំអាលី صلوات الله عليه والسلام ល្បីឈ្មោះ ដែលគេទទួលស្គាល់ព្រះអង្គ صلوات الله عليه والسلام ជាគ្រូគុនដាវចម្បាំង ។ ព្រះអង្គ صلوات الله عليه والسلام ប្រយុទ្ធខ្លាំងក្លាបំផុត បណ្តាលឲ្យដាវព្រះអង្គ صلوات الله عليه والسلام បាក់ ។ ព្រះសាស្តាមូហាំម៉ាដ្ឋﷺក៏បានប្រគល់ដាវព្រះអង្គﷺឈ្មោះ "ស៊្សុល ហ្វីក្ការ (ذُو الْفَقَار)" ឲ្យទៅអ៊ីម៉ាំអាលី صلوات الله عليه والسلام ។ សម្លេងរបស់ទេវតាយ៉ីបរ៉អ៊ីល عليه السلام បានបន្លឺនៅលើមេឃ ដោយកោតសរសើរសេចក្តីក្លាហានរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ថា៖ "ពុំមានយុទ្ធជនណាដូចអាលី صلوات الله عليه والسلام ទេ ។ ពុំមានដាវណាដូចស៊្សុល ហ្វីក្ការទេ (لَا فَتَى إِلَّا عَلِيٌّ لَا سَيْفَ إِلَّا ذُو الْفَقَارِ)" ។



ទ័ពម៉ាក់កាស្ម់បានត្រឡប់ស្ថានការណ៍សង្គ្រាម តែពុំអាចឆ្លៀតយកឱកាសនេះវាយលុកម៉ាឌីណាស្ម់ឬដេញក្រុមមុស្លីមចុះពីលើទួលអ៊ូហ៊្វដ្ឋបានទេ ព្រោះតែនឿយហត់ខ្លាំងពេក ។ ដូច្នេះពួកគេបានត្រឹមតែប្រព្រឹត្តអំពើឃោរឃៅទៅលើជនរងរបួសប៉ុណ្ណោះដើម្បីបំពេញបំណងសងសឹក ដោយកាត់ត្រចៀក កាត់ច្រមុះនិងធ្វើកាយវិកលកម្មទៅលើខ្លួនប្រាណពួកគេ ។ វីរៈបុរសហ៊ាំស្សាស្ម់ رضي الله عنه នៅក្នុងចំណោមទុក្ករបុគ្គលទាំងនេះដែរ ។ ហ៊ីនដ្ធ៍ ភរិយារបស់ អាប៊ូ ស៊ុហ្វយ៉ាន បានវះយកថ្លើមលោក رضي الله عنه មកទំពា ។

នៅក្នុងសមរភូមិនេះ មុស្លីម ៧០ នាក់បានទទួលទុក្ករកម្មដោយបូជាជីវិត ៧០ នាក់រងរបួស ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام ក៏រងរបួសធ្ងន់ដែរ ។ ពួកម៉ាក់កាស្ម់បានបាត់បង់យុទ្ធជន ២២ នាក់ ១២ នាក់ត្រូវអ៊ីម៉ាំអាលី صلوات الله عليه والسلام ប្រហារ ។

បរាជ័យរបស់ក្រុមមុស្លីមជាវិញ្ញាសាសម្រាប់ពួកគេ ។ ពួកគេបានងើបពីគំនរផេះផង់នៃសមរភូមិឡើងប្រកបដោយការប្តេជ្ញាផ្តាច់ និងគោលបំណងការពារជំនឿរបស់ខ្លួននិងផលប្រយោជន៍អ៊ីស្លាម ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. ហេតុអ្វីក្រុមមុស្លីមទទួលបរាជ័យក្នុងសមរភូមិអ៊ូហ៊្វូដ ?

២. ពេលបានឮថាព្រះសាស្ដាមូហាំម៉ាដ់ﷺស្លាប់ មុស្លីមខ្លះមានប្រតិកម្មអ្វី ?

៣. មេបញ្ជាការម៉ាក់កាស្ទូណាមួយដែលមើលឃើញឱកាសល្អ កាលច្រកទួលទាំងពីរគ្មានអ្នកយាម ?

៤. ដាវដ៏ល្បីណាមួយដែលអ៊ីម៉ាំអាលីصلوات الله عليه والسلامបានប្រើនៅក្នុងសមរភូមិ ? តើអ្នកដឹងទេថាដាវនោះមានសណ្ឋានបែបណា ?

៥. អ្នកណា ដែលជាសាច់សាលោហិតរបស់ព្រះសាស្ដាមូហាំម៉ាដ់ﷺ បានស្លាប់នៅក្នុងសមរភូមិ ?

**មេរៀនទី ៨**

# អ្នកផ្សាយសាសនាអ៊ីស្លាម

បន្ទាប់ពីក្រុមមុស្លីមបានចាញ់សមរភូមិអ៊ូហ៊្វូដ្ធ ប្រជាជាតិច្រើនក្រុមលែងកោតញញើត គិតថាខ្លួនអាចចាត់បញ្ជូនទ័ពទៅវាយយកម៉ាឌីណាស្វ័បាន ។

តែក្រុមមុស្លីមបានចាញ់សមរភូមិអ៊ូហ៊្វូដ្ធព្រោះតែខ្វះវិន័យប៉ុណ្ណោះ ពួកគេចងចាំមេរៀនបានល្អណាស់ ។ ក្រុមមុស្លីមនៅតែជាកងកម្លាំងខ្លាំងដដែល ។ ដើម្បីព្រមាន ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ បានទប់ទល់ប្រជាជាតិនានាដែលគិតវាយលុកម៉ាឌីណាស្វ័នោះ ដោយចាត់បញ្ជូនកងតូចៗប្រដាប់អាវុធទៅរកពួកគេដើម្បីបង្ក្រាបសកម្មភាពមកលើពួកមុស្លីម ។ កងប្រដាប់អាវុធទាំងនេះត្រួសត្រាយផ្លូវសម្រាប់ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ ដែរ ដើម្បីចាត់បញ្ជូនក្រុមបេសកជនទៅបង្ហាត់បង្រៀនប្រជាជាតិផ្សេងៗឲ្យចេះដឹងសាសនាអ៊ីស្លាម ។

ប្រជាជាតិបច្ចាមិត្តខ្លះប្រើមធ្យោបាយបោកប្រាស់ ដើម្បីធ្វើឲ្យអ៊ីស្លាមខ្សោយ ។ តំណាងប្រជាជាតិខ្លះ ដែលរស់នៅក្រៅម៉ាឌីណាស្វ័ បានមករកព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ ដោយថាខ្លួនចង់ទៅជាមុស្លីម ថាពួកគេចង់បានអ្នកបង្ហាត់បង្រៀនឲ្យចេះដឹងអ៊ីស្លាម ។ ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ ចាំបាច់ត្រូវតែធ្វើតាមសំណូមពរនេះព្រោះវាជាករណីយកិច្ចព្រះអង្គ ﷺ ម្យ៉ាងទៀតបុគ្គលទាំងនេះជាតំណាងរបស់ប្រជាជាតិធំៗ ។ ព្រះអង្គ ﷺ ក៏បានអនុញ្ញាតឲ្យបេសកជន ១០ នាក់ទៅជាមួយតំណាងប្រជាជាតិទាំងនេះ ។

ពេលចេញផុតពីតំបន់នៅក្រោមអាជ្ញាធររដ្ឋបាលមុស្លីម ពួកគេបានបើកឲ្យដឹងគោលបំណងពិត ។ ពួកគេបានព័ទ្ធបេសកជនទាំងដប់នាក់ ។ ក្រុមមុស្លីមពុំមានមធ្យោបាយផ្សេងពីហ្វូតដារទេ ។ តែពួកសត្រូវស្បថថាពួកគេមានបំណងចាប់ខ្លួនពួកគេយកទៅឲ្យពួកគូរ៉យស្វ៍ដូរនឹងរង្វាន់តែម្យ៉ាង ។

ក្រុមមុស្លីមមើលមុខគ្នា ហើយសម្រេចចិត្តប្រយុទ្ធ ។ ពួកគេបានឆ្លើយវិញថាមិនជឿសម្ដីពួកធ្វើសក្ការៈរូបព្រះទេ ហើយបានស្លាប់ក្នុងនាមអ៊ីស្លាមដោយប្រយុទ្ធយ៉ាងអង់អាចក្លាហាន ។ ទាំងអស់គ្នាបានស្លាប់ នៅសល់តែបីនាក់ ។ បុរសទាំងបី

បានដាក់អាវុធចុះ សូមចុះចាញ់ ដោយជឿសុច្ឆន្ទៈរបស់សត្រូវ ។

ពេលត្រូវគេនាំខ្លួន បុរសម្នាក់នឹកខ្មាសខ្លួនឯងដែលបានចុះចាញ់ ។ គាត់លួចស្រាយចំណងដៃរួច ក៏បានចាប់យកដាវ វាយប្រហារពួកសត្រូវ ។ ពួកសត្រូវដកខ្លួនថយ វាយឈ្នះគាត់ដោយចោលគាត់ដោយដុំថ្ម ។ ពេលគាត់ដួល ពួកវាបានគប់គាត់នឹងដុំថ្មលុះស្លាប់ ហើយបានកប់សពគាត់នៅកន្លែងនោះតែម្តង ។

ចំណាប់ពីរនាក់ទៀតត្រូវប្រគល់ខ្លួនឲ្យទៅពួកគូរ៉យស្ហ៍នៅម៉ាក់កាស្ហ៍ ដើម្បីយកទៅដូរនឹងបក្សពួកខ្លួនពីរនាក់ទៀតដែលត្រូវគេចាប់ជាឈ្លើយសឹកនោះ ។ នៅម៉ាក់កាស្ហ៍ បុរសម្នាក់ដែលឪពុកខ្លួនត្រូវក្រុមមុស្លីមសម្លាប់ក្នុងសមរភូមិបាដ្ឋារ បានទិញខ្លួនបេសកជនម្នាក់ ។ ដើម្បីសងសឹក គាត់បានព្យួរកបេសកជននេះ ។ បុរសម្នាក់ទៀតត្រូវគេឃុំឃាំងមួយរយៈពេល មុននឹងត្រូវគេសម្លាប់ដោយព្យួរកដែរ ។ មុនត្រូវគេប្រហារជីវិតដោយព្យួរក គាត់បានសូម យ៉ាងក្លាហាន ឲ្យពួកម៉ាក់កាស្ហ៍ទុកពេលឲ្យគាត់ស្ហ៍ឡាត់ ។ ដូច្នេះ ទោះបីជិតស្លាប់ក៏ដោយ គាត់បានធ្វើឲ្យពួកឃាតករស្ញើចគាត់ដែលជឿអ៊ីស្លាមស៊ប់ចិត្ត ។

ព្រះសាស្តាមូហ្ហាំម៉ាដ្ហ៍ﷺសោកសង្រេងណាស់ ពេលបានដឹងថាបណ្តាបេសកជនរងជោគវាសនាអកុសល ។ ព្រះអង្គﷺចាត់បញ្ជូនបុរសពីរនាក់ទៅបញ្ចុះសពបេសកជនទីពីរដែលគេព្យួរចោល នៅលើបង្គោលចងកច្រើនថ្ងៃហើយនោះ ដោយលួចលាក់ ។

ច្រើនខែក្រោយមក បុរសប្រជាជាតិ បានី អ៊ាមៀរ (بَنِي عَامِرٍ) ម្នាក់បានមកម៉ាឌីណាស្ហ៍ ។ ព្រះសាស្តាមូហ្ហាំម៉ាដ្ហ៍ﷺបានអញ្ជើញគាត់មកចូលអ៊ីស្លាម ។ បុរសនេះសូមឲ្យគេចាត់បញ្ជូនបេសកជនទៅតំបន់ ណាយ៉ាដ្ហ៍ (نجد) ។ ពេលព្រះសាស្តាﷺនិយាយអំពីសន្តិសុខរបស់បេសកជនទាំងនោះ ដោយលើកឡើងនូវបទពិសោធន៍កន្លងមកហើយនោះ បុរសនោះប្រាប់ព្រះអង្គﷺថាគាត់នឹងនៅម៉ាឌីណាស្ហ៍ដើម្បីធានាថា ប្រជាជាតិគាត់នឹងមិនប្រព្រឹត្តអាក្រក់ចំពោះក្រុមមុស្លីមទេ ។

ព្រះសាស្តាមូហ្ហាំម៉ាដ្ហ៍ﷺក៏បានចាត់បញ្ជូនមុស្លីម ៤០ នាក់ទៅកាន់តំបន់ណាយ៉ាដ្ហ៍ ក្រោមអាជ្ញាធររបស់បុរសម្នាក់ឈ្មោះ មុនស្ហៀរ ។ ព្រះអង្គﷺបានផ្ញើសារទៅមេដឹកនាំប្រជាជាតិមួយក្រុមទៀតដែរ អញ្ជើញគាត់មកចូលអ៊ីស្លាម ។ តែមេដឹកនាំនេះ មិនខ្វីបើកសារមើលទេ ក៏បានសម្លាប់អ្នកនាំសារភ្លាម ។ គាត់បាន

សូមការគាំទ្រពីសំណាក់ក្រុមប្រជាជាតិឯទៀតដែលនៅជិតៗនោះ ដើម្បីវាយប្រហារក្រុមបេសកជនដែលបោះជំរំនៅតំបន់ណាយ៉ាដ្ជ ។ ទោះបីប្រជាជាតិ បានីអាុមៀរ ព្យាយាមណែនាំគាត់ឲ្យផ្លាស់ប្តូរគំនិតក៏ដោយ ពួកគាត់មានគ្នាតិច ។

បុរសមុស្លីមពីរនាក់កំពុងឃ្វាលអូដ្ឋ ពេលការវាយប្រហារបានកើតឡើង ។ បុរសម្នាក់ស្លាប់ ម្នាក់ទៀតឈ្មោះ អាុម៉ារ រត់រួច ។ មុស្លីមឯទៀតមិនត្រឹមតែជាបេសកជនច្បងម្យ៉ាងទេ តែជាបុគ្គលក្លាហាននិងថ្មឹកខាងចម្បាំងផង ។ ដូច្នេះ ពួកគាត់យល់ឃើញថាសូមចុះចាញ់ជាប្រការអាម៉ាស់ ។

ទាំងអស់គ្នាក៏បានចាប់អាវុធប្រយុទ្ធ តែមានគ្នាតិចទល់នឹងសត្រូវ ។ បន្ទាប់ពីបានប្រយុទ្ធយ៉ាងអង់អាច ទាំងអស់គ្នាបានបូជាជីវិត សល់តែម្នាក់ឈ្មោះ កាអាុប់ (كعب) ។ លោករងរបួសតែអាចទៅកាន់ម៉ាឌីណាស្ទុំបាន ហើយបានប្រាប់ឲ្យដឹងហេតុការណ៍ ។

ព្រឹត្តិការណ៍ទាំងនេះសឲ្យឃើញនូវពលីកម្មដែលមុស្លីមមុនៗបានធ្វើ ដើម្បីផ្សព្វផ្សាយនិងការពារអ៊ីស្លាម ។ សូមអល់ឡោះហ្ស៊ عزّ وجلّ ជូនពរជ័យឲ្យលោកទាំងអស់នេះដែលបានខិតខំព្យាយាមពុះពារឧបសគ្គ ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. ហេតុអ្វីប្រជាជាតិនានាប្រុងប្រយុទ្ធនឹងក្រុមមុស្លីម ?

២. បេសកជនគឺអ្វី ?

៣. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺព្យាយាមធ្វើតាមសំណូមពរ ដែលសូមឲ្យចាត់បញ្ជូនបេសកជន ?

៤. ហេតុអ្វីពួកម៉ាក់កាស់សម្លាប់ដោយព្យួរកមុស្លីមពីរនាក់ដែលចាប់បាន ?

៥. យើងអាចដកស្រង់បាននូវមេរៀនអ្វីពីព្រឹត្តិការណ៍នេះ ?

## មេរៀនទី ៩

# សមរភូមិ អាស់សាប់

ពួកយ៉ាហ៊ូឌី បានី កូយ់នូក៍អ៊ុ ត្រូវបណ្តេញចេញពីម៉ាឌីណាស់ព្រោះតែបានបង្កបញ្ហា ឯបានី ណាឌៀរ (بَنِي النَّضِير) ប្រជាជាតិយ៉ាហ៊ូឌីបងប្អូនពួកគេនោះ ក្រោធណាស់ ។ ប្រជាជាតិយ៉ាហ៊ូឌី បានី ណាឌៀរ នេះក៏បានក្លាយទៅសត្រូវស្លាប់រស់របស់អ៊ីស្លាម រង់ចាំឱកាសល្អដើម្បីបៀតបៀនក្រុមមុស្លីម ។

ថ្ងៃមួយ ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺបានទៅបន្ទាយប្រជាជាតិ បានី ណាឌៀរជាមួយសាវកពីរបីនាក់ ។ ពេលព្រះអង្គﷺឈរចាំនៅច្រកចូលខាងក្រៅបន្ទាយ ពួកយ៉ាហ៊ូឌីបានចាត់បញ្ជូនបុរសម្នាក់ទៅឡើងលើបន្ទាយពីខាងក្នុង ដើម្បីសម្លាប់ព្រះអង្គﷺដោយទម្លាក់ថ្មមួយដុំធំមកលើក្បាលព្រះអង្គﷺ ។ ព្រះសាស្តាﷺបានដឹងគម្រោងការក្បត់នេះទាន់ពេលក៏បានចាកចេញភ្លាមពីកន្លែងនេះ ។

ព្រោះតែពួក បានី ណាឌៀរ បានក្បត់កិច្ចសន្យាដែលខ្លួនបានចុះហត្ថលេខាយល់ព្រមហើយនោះ បានជាព្រះសាស្តាមូហ៊ាំម៉ាដ់ﷺបានទុកពេល ១០ ថ្ងៃឲ្យពួកគេដើម្បីចាកចេញពីម៉ាឌីណាស់ ។ បន្ទាប់ពីបានតវ៉ា ពួកគេក៏បានចាកចេញពីម៉ាឌីណាស់ដោយកម្ទេចលំនៅដ្ឋានខ្លួនចោលដើម្បីកុំឲ្យពួកមុស្លីមនៅបាន ។ គេបានអនុញ្ញាតឲ្យពួកគេយកទ្រព្យសម្បត្តិទាំងអស់ទៅជាមួយ លើកលែងតែអាវុធសម្រាប់ធ្វើសង្គ្រាម ។ ពួកគេខ្លះទៅរស់នៅឯប្រទេសស៊ីរី ខ្លះទៀតទៅរស់នៅជាមួយពួកយ៉ាហ៊ូឌីស្រុកខុយបារ ។

លុះបានតាំងលំនៅដ្ឋាននៅខុយបារហើយ ពួកបានី ណាឌៀរ ប្តូរផ្តាច់សងសឹកក្រុមមុស្លីម ។ ពួកគេបានទាក់ទងពួកគូរ៉យស្ន៍នៅម៉ាក់កាស់ ពួកមេដឹកនាំយ៉ាហ៊ូឌី ២០ នាក់និងមេដឹកនាំគូរ៉យស្ន៍ ៥០ នាក់បានចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀងថាដរាបណាពួកគេនៅមានជីវិត ដរាបនោះពួកគេនឹងច្បាំងតទល់ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺ ។ បន្ទាប់មក ពួកយ៉ាហ៊ូឌីនិងពួកគូរ៉យស្ន៍ទាក់ទងបក្សពួកខ្លួនរៀងៗខ្លួន ចាត់បញ្ជូនភ្នាក់ងារទៅរកប្រជាជាតិខ្លះដើម្បីសូមជំនួយ ។ ដូច្នេះ ពួកគេប្រមូល

បានរេហ៍ពល ១០០០០ នាក់ ។ ពួកគេក៏បានលើកទ័ពទៅកាន់ម៉ាឌីណាស្ថ៍ក្រោម បញ្ជាការរបស់ អាប៊ូ ស៊ុហ្វយ៉ាន ។

ពេលម៉ាឌីណាស្ថ៍បានទទួលដំណឹងរៀបចំធ្វើសង្គ្រាមនេះ ព្រះសាស្ដា មូហ៊ាំម៉ាដ្ឋ៍ﷺបានពិភាក្សាជាមួយបណ្ដាសាវកព្រះអង្គﷺ ។ សាល់ម៉ាន ហ្វារីស៊ី (سَلْمَانُ الْفَارِسِيُّ) ឲ្យយោបល់ជីកស្នាមភ្លោះធំនិងជ្រៅនៅជ្រុងម៉ាឌីណាស្ថ៍ណាដែលគ្មានគេការពារ ។ គេក៏បានទទួលយកផែនការណ៍នេះ ហើយគេបានបែងចែកពួកមុស្លីមជា ១០ ក្រុម ក្រុមនីមួយៗទទួលបន្ទុកជីកដី ១០ ម៉ែត្រ ។

ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ﷺផ្ទាល់ក៏បានចូលរួមក្នុងការជីកគាស់ដែរ ។ គេបានជីកស្នាមភ្លោះ (ខុន់ដ្ឋាក្ញ) រួចរាល់ទាន់ពេលវេលា ៣ ថ្ងៃមុនទ័ពបច្ចាមិត្តមកដល់ម៉ាឌីណាស្ថ៍ ។ ក្រុមមុស្លីមអាចប្រមូលទ័ពបានត្រឹមតែ ៣០០០ នាក់ទេទល់នឹងទ័ពដ៏សម្បើមនេះ ។ ពួកគេបានបោះជំរំពីរបីគីឡូម៉ែត្រនៅខាងក្រៅម៉ាឌីណាស្ថ៍ ។

ព្រមនឹងពេលនេះ មេដឹកនាំប្រជាជាតិបានី ណាដៀ្ឌរបានទៅជួបពួកយ៉ាហ្វ៊ូឌីដែលនៅតែរស់នៅឯម៉ាឌីណាស្ថ៍ ព្យាយាមញុះញង់ឲ្យពួកគេក្បត់កិច្ចសន្យាដែលពួកគេបានចុះហត្ថលេខាយល់ព្រមជាមួយក្រុមមុស្លីម ។ ហេតុដូច្នេះ ក្រុមមុស្លីមរងគ្រោះថ្នាក់នៅខាងក្នុងនគរម៉ាឌីណាស្ថ៍ ពួកយ៉ាហ្វ៊ូឌីក៏បានសម្លុត គំរាមស្ត្រីនិងក្មេងៗ ។ ពេលព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ﷺបានដឹងហេតុការណ៍ ព្រះអង្គﷺបានចាត់បញ្ជូនក្រុមយាមល្បាតស្រុក ៥០០ នាក់ ។

បច្ចាមិត្តភ្ញាក់ផ្អើលដែលបានឃើញស្នាមភ្លោះ ព្រោះវាជានវាគតភណ្ឌ (របស់ដែលទើបនឹងមកដល់ថ្មីៗ) សម្រាប់ពួកអារ៉ាប់ ។ ពួកគេព្យាយាមឆ្លងស្នាមភ្លោះទាំងថ្ងៃទាំងយប់ តែត្រូវយុទ្ធជនមុស្លីមវាយច្រាន ។ ខកបំណង ពួកសត្រូវក៏បានបាញ់ព្រួញនិងចោលដុំថ្មស្រោចទៅលើទ័ពមុស្លីម ។

ទីបំផុត យុទ្ធជនគូរ៉យស្ស៍ខ្លះដូចជាបុគ្គលល្បីល្បាញឈ្មោះ អ៊ុំរ៉ូ ប៊ិន អ៊ុប់ឌីវ៉ុដ្ឋ (عَمْرُو بْنُ عَبْدِ وُدٍّ) ជាដើមឆ្លងស្នាមភ្លោះរួចត្រង់កន្លែងដែលមានទទឹងមិនសូវឆ្ងាយ ។ អ៊ុំរ៉ូជាយុទ្ធជនពូកែជាងគេពេញមួយដែនដីអារ៉ាប៊ី ។ ពេលគាត់ប្រយុទ្ធ គេប្រៀបផ្ទឹមគាត់ស្មើយុទ្ធជន ១០០០ នាក់ ។ គាត់បានហៅយុទ្ធជនមុស្លីមមកប្រយុទ្ធទល់នឹងគាត់ តែពួកមុស្លីមស្ទាក់ស្ទើរព្រោះតែស្គាល់កេរ្ដិ៍ឈ្មោះគាត់ ។ ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ﷺបានហៅក្រុមមុស្លីមឲ្យប្រយុទ្ធនឹងអ៊ុំរ៉ូបីដង រាល់ៗដងមានតែអ៊ីម៉ាំអាលីصلوات الله عليه والسلامទេដែលងើបឡើង ។ ទីបំផុត ព្រះសាស្ដាﷺអនុញ្ញាតឲ្យអ៊ីម៉ាំអាលីصلوات الله عليه والسلام

ចូលប្រយុទ្ធ ដោយប្រគល់ដាវព្រះអង្គ صلى الله عليه وآله وسلم ឲ្យអ៊ីម៉ាំអាលី صلوات الله عليه والسلام និងជូតក្បាលឲ្យព្រះអង្គ صلوات الله عليه والسلام ដោយឈ្នួតក្បាលពិសេស ។ ពេលអ៊ីម៉ាំអាលី صلوات الله عليه والسلام ចូលក្នុងលានប្រយុទ្ធ ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ប្រកាសថា៖ "សទ្ធាសុទ្ធសាធទល់នឹងអសទ្ធាសុទ្ធសាធ ។"

ពេលអាំរ៉ូស្គាល់អត្តសញ្ញាណអ៊ីម៉ាំអាលី صلوات الله عليه والسلام គាត់មិនព្រមប្រយុទ្ធទេព្រោះអាប៊ូ ត៉ូលិបធ្លាប់ជាមិត្តគាត់ គាត់មិនចង់សម្លាប់កូនរបស់មិត្តគាត់ទេ ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام បានប្រាប់គាត់ថាកុំឲ្យបារម្ភអំពីការស្លាប់របស់ព្រះអង្គ صلوات الله عليه والسلام ពីព្រោះបើព្រះអង្គ صلوات الله عليه والسلام ស្លាប់ អល់ឡោះហ៊្វ عز وجل នឹងឲ្យព្រះអង្គ صلوات الله عليه والسلام ចូលឋានសួគ៌ ចំណែកអាំរ៉ូនឹងចូលឋាននរក ។

អ៊ីម៉ាំអាលី صلوات الله عليه والسلام បានសួររំលឹកអាំរ៉ូថា គាត់ធ្លាប់ថាពេលគូប្រយុទ្ធរបស់គាត់ស្នើគាត់បីសំណូមពរ គាត់នឹងធ្វើតាមមួយសំណូមពរ ។ អាំរ៉ូទទួលស្គាល់ថាពិតជាដូច្នេះមែន ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام ក៏បានសូមឲ្យគាត់ចូលសាសនាអ៊ីស្លាម ឬត្រឡប់ទៅម៉ាក់កាសុំវិញ ឬចុះពីលើសេះ ព្រោះអ៊ីម៉ាំអាលី صلوات الله عليه والسلام មិនមានសេះទេ ព្រះអង្គ صلوات الله عليه والسلام ជាថ្មើរជើង ។

អាំរ៉ូធ្វើតាមសំណូមពរចុងក្រោយ គាត់ចុះពីលើសេះ ។ ចម្បាំងដ៏សាហាវក៏បានចាប់ផ្តើម ។

ធូលីហុយដណ្តប់ជិតគូប្រយុទ្ធទាំងពីរអស់មួយរយៈពេល ពុំមានអ្នកណាមួយដឹងថាអ្វីបានកើតឡើងទេ ។ អាំរ៉ូបានវាយសម្លាប់តម្រង់ក្បាលអ៊ីម៉ាំអាលី صلوات الله عليه والسلام ។ ទោះបីអ៊ីម៉ាំអាលី صلوات الله عليه والسلام យកខែលទប់ក៏ដោយ តែដាវអាំរ៉ូបានពុះខែលដាច់ មកត្រូវក្បាលព្រះអង្គ صلوات الله عليه والسلام រងរបួសជាដំណំ ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام កាប់សំដៅជើងអាំរ៉ូបណ្តាលឲ្យគាត់ដួល ។ រំពេចនោះ អ៊ីម៉ាំអាលី صلوات الله عليه والسلام ស្រែកឡើងថា "អល់ឡហ៊្វអាក់បារ" ព្រមនឹងកាប់ផ្តាច់ក្បាលអាំរ៉ូ ។ មរណៈភាពរបស់អាំរ៉ូធ្វើឲ្យយុទ្ធជនឯទៀតដែលបានឆ្លងមកម្ខាងស្នាមភ្លោះនោះស្លន់ស្មារតី រត់ចោលចម្បាំង ។

សមរភូមិត្រូវចប់ដោយសារបីប្រការ គឺ៖

១. ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានចុះហត្ថលេខា ធ្វើកិច្ចព្រមព្រៀងសន្តិភាពជាមួយប្រជាជាតិខ្លះដែលបានប្រជុំគ្នាដើម្បីច្បាំងនឹងក្រុមមុស្លីម ។

២. បច្ចាមិត្តបានបាត់បង់ទឹកចិត្តពេល អាំរ៉ូ ប៊ិន អាប់ឌ៏ វុដ្ទ ស្លាប់ ។

៣. រដូវត្រជាក់ខ្លាំងបានធ្វើឲ្យសេះក្រុមសត្រូវស្លាប់ ហើយពួកគេជិតអស់ស្បៀង ។

ទីបំផុត ព្រះសាស្ដាមូហាំម៉ាដ្ ﷺ បានទៅកាន់កន្លែងដែលគេដំឡើងម៉ាស់យិដ្ជជ័យជំនះ (مَسْجِدُ الْفَتْحِ) បួងសួងអល់ឡោះហ៍ ﷻ សូមជំនួយ ។ ខ្យល់ព្យុះដ៏សាហាវបានបោកបក់កន្ទ្រាក់ជំរំពួកសត្រូវ ពង្រាយទ្រព្យពួកគេដេរដាស បណ្ដាលឲ្យក្រុមសត្រូវភ័យរន្ធត់ ។ ពួកម៉ាក់កាស់និងពួកយ៉ាហ៊ូឌីរត់ចោលសមរភូមិ ។ គេហៅសមរភូមិនេះថា អាស់ស៊ាប់ (الْأَحْزَاب ចម្បាំងសម្ពន្ធប្រជាជាតិ) ឬ ខ៊ន់ដាក់ (ចម្បាំងស្នាមភ្លោះ) ដែលក្រុមមុស្លីមបានពុះពារប្រកបដោយជោគជ័យទោះបីមានគ្នាតិចក៏ដោយ ។ ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ 33 (អាល់-អាស់ស៊ាប់) អាយ៉ាស់ 9 ថែងថា៖

يَـٰٓأَيُّهَا ٱلَّذِينَ ءَامَنُوا۟ ٱذْكُرُوا۟ نِعْمَةَ ٱللَّهِ عَلَيْكُمْ إِذْ جَآءَتْكُمْ جُنُودٌ فَأَرْسَلْنَا عَلَيْهِمْ رِيحًا وَجُنُودًا لَّمْ تَرَوْهَا ۚ وَكَانَ ٱللَّهُ بِمَا تَعْمَلُونَ بَصِيرًا ﴿٩﴾

*9. បណ្ដាអ្នកមានសទ្ធាអើយ ចូរពួកអ្នកនឹកដល់ព្រះគុណអល់ឡោះហ៍មកលើពួកអ្នកកាលកងទ័ពបានមកប្រឈមទល់ពួកអ្នក ។ យើងបានបញ្ជូនខ្យល់និងកងទ័ពដែលពួកអ្នកមើលមិនឃើញមកប្រឈមទល់ពួកគេ ។ អល់ឡោះហ៍ទ្រង់មហាទស្សនាការអ្វីដែលពួកអ្នកធ្វើ ។*

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីពួកយ៉ាហ៊ូឌីចូលរួមជាមួយពួកគូរ៉យស៍ ដើម្បីច្បាំងក្រុមមុស្លីម ?

២. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺ បានចាត់បញ្ជូនមួយប៉ែកនៃទ័ពព្រះអង្គﷺទៅក្នុងនគរម៉ាឌីណាស់ ?

៣. ហេតុអ្វី អុំរូ ប៊ិន អាប់ឌី វុដ្ឋ មិនចង់ប្រយុទ្ធទល់អ៊ីម៉ាំអាលីصلوات الله عليه والسلام ?

៤. សមរភូមិបានចប់ដោយសារអ្វី ?

៥. មានអាយ៉ាស់មួយចែងអំពីរឿងនេះនៅក្នុងស៊ូរ៉ោះគ៍ អាល់-អាស់ស្ហាប់ ។ ចូររកស៊ូរ៉ោះគ៍នេះនិងសរសេរសម្រាយវា ។

# មេរៀនទី ១០

# សម្បថ រីដ្វាន

ឆ្នាំទី ៥ សករាជហ៊ិជ្រោះត៍ ព្រះសាស្តាមូហាំម៉ាដ់ﷺបានទទួលព្រះរាជបញ្ជាពីអល់ឡោះហ៊្ជ ឲ្យដាក់ពិធីហាជ្ជ៍ជាទង្វើវ៉ាយិបសម្រាប់មុស្លីមទាំងអស់ ។ ឆ្នាំបន្ទាប់ព្រះអង្គﷺសុបិនឃើញថា ព្រះអង្គﷺធ្វើពិធីហាជ្ជ៍ជាមួយបណ្តាសាវកព្រះអង្គﷺ ។ ដូច្នេះ ព្រះអង្គﷺបានសម្រេចទៅធ្វើពិធីហាជ្ជ៍ក្នុងឆ្នាំនេះ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានប្រកាសប្រាប់មុស្លីមទាំងអស់ថា ព្រះអង្គﷺចង់ទៅធ្វើពិធីហាជ្ជ៍ក្នុងខែ ស៊ុល ក្វក់ដាស់ (ذُو الْقَعْدَة) ឆ្នាំទី ៦ សករាជហ៊ិជ្រោះត៍ ។ ពួកមូហាជីរីន ដែលបានភៀសខ្លួនជាមួយព្រះអង្គﷺទៅម៉ាឌីណាស់នោះត្រេកអរណាស់ដែលមានឱកាសត្រឡប់ទៅកាន់ស្រុកកំណើតជាទីស្រឡាញ់វិញ ។ ពួកអាន់ស្វរដែលមានកំណើតនៅម៉ាឌីណាស់នោះក៏ត្រេកអរដែរ ព្រោះនឹងបានធ្វើដំណើរដែលប្រកបដោយសិរីសួស្តី ។ សរុបទាំងអស់ មុស្លីម ១៤០០ នាក់បានរៀបចំខ្លួនទៅម៉ាក់កាស់ជាមួយព្រះសាស្តាមូហាំម៉ាដ់ﷺ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានចាកចេញពីម៉ាឌីណាស់តាមថ្ងៃកំណត់ ហើយបានចាត់បញ្ជូនទ័ពមួយកងទៅមុនព្រះអង្គﷺ ដើម្បីប្រាប់ព្រះអង្គﷺឲ្យដឹងអំពីស្ថានការណ៍ផ្លូវក្រែងលោមានការគំរាមពីសំណាក់បនគូរ៉យ់ស្ហ៍ ។ ព្រះអង្គﷺបានសូមឲ្យក្រុមមុស្លីមកុំយកអាវុធផ្សេងក្រៅពីដាវ ។ ព្រះសាស្តាﷺនិងបណ្តាសាវកព្រះអង្គﷺគ្រងអ៊ិះហ្រ៊ាម៍តាមផ្លូវ បានជ្រើសរើសអូដ្ឋ ៧០ ក្បាលសម្រាប់ធ្វើពលីទានក្នុងពីធីហាជ្ជ៍ ។

ព្រមនឹងពេលនេះ ពួកគូរ៉យ់ស្ហ៍បានទទួលដំណឹងថាក្រុមមុស្លីមធ្វើដំណើរមកឯម៉ាក់កាស់ ហើយបានចាត់បញ្ជូនវរេហ៍ពល ២០០ នាក់ទៅទប់ស្កាត់ ។ ពេលព្រះសាស្តាﷺបានដឹងថាមានការរង់ចាំលួចវាយឆ្មក់ ព្រះអង្គﷺបានឲ្យអ្នកនាំផ្លូវនាំក្រុមមុស្លីមដើរតាមផ្លូវវាងពួកសត្រូវ ។ ទីបំផុត បន្ទាប់ពីបានដើរកាត់តាមផ្លូវពិបាក គេបានទៅដល់កន្លែងមួយដែលមានអណ្តូងទឹកមួយហៅថា ហ៊្វូដៃប៊ីយ៉ាស់ (اَلْحُدَيْبِيَة) ឆ្ងាយពីម៉ាក់កាស់ ១៥ គីឡូម៉ែត្រ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានដាក់បញ្ជាឲ្យក្រុមមុស្លីមឈប់ទីនេះ និងឲ្យបោះជំរំ ។ បន្ទាប់មកព្រះអង្គﷺបានបញ្ជូនសារទៅពួកគូរ៉យស្ហ៍ថាព្រះអង្គﷺចង់ចូលទៅក្នុងម៉ាក់កាស់ដើម្បីបំពេញពិធីធម្មយាត្រា ។ ព្រះអង្គﷺបានឲ្យពួកគេដឹងដែរថាព្រះអង្គﷺមកក្នុងគោលបំណងល្អប្រកបដោយសន្តិភាព និងមានបំណងដោះស្រាយបញ្ហាដោយការចរចា ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានចាត់ អ៊ូម៉ារ ប៊ិន ខត្តត្តប់ ដែលពុំបានប្រយុទ្ធទល់នឹងពួកគូរ៉យស្ហ៍នៅក្នុងសមរភូមិណាមួយឡើយនោះ ជាតំណាងក្រុមមុស្លីមឲ្យទៅម៉ាក់កាស់ ។ អ៊ូម៉ារបានឆ្លើយដោះសាថាគាត់មានឋានៈទាប ។ ព្រះសាស្តាﷺក៏បានបញ្ជូន អ៊ុស្មម៉ាន បិន អាហ្វហ្វាន (عثمان بن عفان) ដែលជាក្មួយរបស់ អាប៊ូស៊ុហ្វយ៉ាន មេដឹកនាំម៉ាក់កាស់ ។

គេបានទទួល អ៊ុស្មម៉ាន យ៉ាងរាក់ទាក់ព្រោះតែគាត់ជាសាច់សាលោហិតជាមួយ អាប៊ូ ស៊ុហ្វយ៉ាន ។ ពួកគូរ៉យស្ហ៍ប្រាប់គាត់ថាគាត់អាចធ្វើពិធីហាច្ជ៍បានដោយសេរី តែមិនឲ្យមុស្លីមឯទៀតចូលមកក្នុងម៉ាក់កាស់ទេ ។ អ៊ុស្មម៉ានមិនព្រមធ្វើពិធីហាច្ជ៍តែម្នាក់ឯងទេ ដូច្នេះគេបានឃាត់ខ្លួនគាត់ទុកនៅឯម៉ាក់កាស់ ។

ដោយមិនឃើញ អ៊ុស្មម៉ាន ត្រឡប់មកវិញ ក្រុមមុស្លីមបារម្ភខ្លាចគេស្លាប់គាត់ ។ ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថាអាចកើតមានការប្រយុទ្ធគ្នា ។ ដូច្នេះ ព្រះអង្គﷺបានសូមឲ្យក្រុមមុស្លីមធ្វើសម្បថស្មោះស្ម័គ្រថានឹងគាំគ្រព្រះអង្គﷺទោះបីត្រូវប្រឈមនឹងសេចក្តីស្លាប់ក៏ដោយ ។ ការធ្វើសម្បថដ៏ល្បីនេះបានប្រព្រឹត្តឡើងនៅក្រោមដើមឈើមួយដើម (acacia) គេហៅសម្បថនេះថា សម្បថរីដ្វវ៉ាន (بَيْعَةَ الرِّضْوَانِ) ។ ព្រឹត្តិការណ៍នេះមានចែងនៅក្នុងព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត៍អាល់-ហ្វាត់ហ្ា៍, 48:18) ថា៖

۞لَّقَدْ رَضِيَ ٱللَّهُ عَنِ ٱلْمُؤْمِنِينَ إِذْ يُبَايِعُونَكَ تَحْتَ ٱلشَّجَرَةِ فَعَلِمَ مَا فِي قُلُوبِهِمْ فَأَنزَلَ ٱلسَّكِينَةَ عَلَيْهِمْ وَأَثَٰبَهُمْ فَتْحًا قَرِيبًا ﴿١٨﴾

*18 ពិតណាស់ អល់ឡោះហ៍សព្វព្រះហឫទ័យអ្នកមានសទ្ធាជ្រះថ្លាទាំងឡាយ កាលពួកគេបានសច្ចាស្មោះស្ម័គ្រចំពោះអ្នកនៅក្រោមដើមឈើ ។ ព្រះអង្គទ្រង់ញាណនូវអ្វីដែលមាននៅក្នុងចិត្តពួកគេ ។ ដូច្នេះព្រះអង្គបានប្រទានសេចក្តីស្ងប់មកលើពួកគេ ហើយបានតបស្នងពួកគេដោយជ័យជំនះដ៏ជិតមួយ ។*

បន្ទាប់មកបន្តិច អ៊ុស្មម៉ាន ត្រឡប់មកពីម៉ាក់កាស្ទុំវិញដោយសុវត្ថិភាព ។ បុរសម្នាក់ឈ្មោះ ស៊ូហៃល៍ មកជាមួយគាត់ដែរ ត្រូវចាត់បញ្ជូនមកដោយពួកគូរ៉យ៉ស្ទ៍ជាមួយបង្គាប់ឲ្យដោះស្រាយជម្លោះដោយសន្តិវិធី ។ ក្រោយពីការចរចារវាងស៊ូហៃល៍និងព្រះសាស្តាមូហាំម៉ាដ្ទុំﷺ ក្រុមមុស្លីមនិងពួកគូរ៉យ៉ស្ទ៍បានចុះហត្ថលេខាយល់ព្រមធ្វើកិច្ចព្រមព្រៀងសន្តិភាព ។ លក្ខខណ្ឌនៃកិច្ចព្រមព្រៀងមានដូចតទៅ គឺ៖

១. ក្រុមមុស្លីមត្រូវត្រឡប់ទៅម៉ាឌីណាស្ទុំវិញក្នុងឆ្នាំនេះ ដោយមិនធ្វើពិធីហាច្ជ ។

២. ពួកគេអាចត្រឡប់មកវិញបានក្នុងឆ្នាំមុខ តែមិនអាចស្នាក់នៅបានលើសពី ៣ ថ្ងៃទេ ។

៣. ក្រុមមុស្លីមមិនត្រូវមានអាវុធជាប់ខ្លួនទេ លើកលែងតែដាវនៅក្នុងស្រោម ។

៤. នឹងពុំមានសង្គ្រាមទេរវាងក្រុមមុស្លីមនិងពួកគូរ៉យ៉ស្ទ៍ក្នុងរយៈពេល ១០ ឆ្នាំតទៅ ។

៥. បុគ្គលធ្វើសក្ការៈរូបព្រះ ឬបុគ្គលមុស្លីមណាមួយដែលទៅម៉ាឌីណាស្ទុំដោយគ្មានការអនុញ្ញាតពីប្រជាជាតិខ្លួន ត្រូវបញ្ជូនខ្លួនបុគ្គលនោះត្រឡប់មកម៉ាក់កាស្ទុំវិញ ។ តែបុគ្គលមុស្លីមម៉ាឌីណាស្ទុំមកកាន់ម៉ាក់កាស្ទុំដោយគ្មានការអនុញ្ញាតនឹងត្រូវឃាត់ខ្លួនទុក ។

ប្រជាជាតិទាំងអស់នៃដែនដីអារ៉ាប៊ី អាចចូលរួមជាមួយបក្សមួយណាក៏បានក្នុងចំណោមបក្សទាំងពីរនេះដែលបានចុះហត្ថលេខាយល់ព្រម ឯសម្ពន្ធមិត្តក៏ត្រូវគោរពកិច្ចព្រមព្រៀងដែរ ។

នៅចុងបញ្ចប់កិច្ចព្រមព្រៀង អ៊ុម៉ារ ដែលជាបុគ្គលខ្សោយជំនឿនោះ បានចោទព្រះសាស្តាមូហាំម៉ាដ្ទុំﷺថាបណ្តោយឲ្យគេទិញក្បាលបាន ។ ទោះបីមានខ្លះនៅក្នុងកិច្ចព្រមព្រៀងនេះ ហាក់ដូចជាប្រឆាំងផលប្រយោជន៍បក្សមុស្លីមក៏

ដោយ តែការពិតវាមិនមែនដូច្នេះទេ ។ បន្ទាប់ពីបានស្នាក់នៅហ៊្វូដៃប៊ីយ៉ាស់អស់ ៣ ថ្ងៃ ក្រុមមុស្លីមបានត្រឡប់ទៅម៉ាឌីណាស់វិញ ។ ពេលនោះ ស៊ូរ៉ោះត៍ អាល់-ហ្វាត់ហ៊ុ (ជ័យជំនះ) ត្រូវដាក់មក ចែងប្រាប់ថាកិច្ចព្រមព្រៀងនេះជាជ័យជំនះមួយសម្រាប់បក្សមុស្លីម ។

កិច្ចព្រមព្រៀងហ៊្វូដៃប៊ីយ៉ាស់ (صُلْح الْحُدَيْبِيَة) បាននាំសន្តិភាពមកលើដែនដីអារ៉ាប៊ីបន្ទាប់ពីបានរងការលំបាកដ៏យូរ ។ ក្នុងអំឡុងពេល ២ ឆ្នាំបន្ទាប់ពីបានធ្វើកិច្ចព្រមព្រៀងសន្តិភាពនេះ មានមនុស្សចូលសាសនាអ៊ីស្លាមច្រើនជាងក្នុងរយៈពេល ១៩ ឆ្នាំកន្លងមកចាប់តាំងពីព្រះសាស្តាមូហាំម៉ាដ់ﷺបានចាប់ផ្តើមបំពេញបេសកកម្មសាស្តា ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺសម្រេចធ្វើពិធីហាជ្ជ៍ក្នុងនេះ ?

២. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺបានចាត់បញ្ជូន អ៊ុស្មម៉ាន ដើម្បីចរចាជាមួយពួកគូរ៉យស្ស៍ ?

៣. ហេតុអ្វីសម្បថរីឌ្វ៉ាន់សំខាន់ម្លេះ ?

៤. ហេតុអ្វីកិច្ចព្រមព្រៀងនេះធ្វើឲ្យ អ៊ុម៉ារ ច្រឡោតខ្លាំង ?

៥. ហេតុអ្វីអល់ឡោះហ្វ៍ﷻចាត់ទុកកិច្ចព្រមព្រៀងនេះជាជ័យជំនះដ៏ធំ ?

**មេរៀនទី ១១**

# ការសូមអញ្ជើញបរទេសមកកាន់អ៊ីស្លាម

សន្តិភាពក្រោយពីបានចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀងហ៊្ទូដៃប៊ីយ៉ាស់ ជាឱកាសល្អសម្រាប់ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمដើម្បីផ្សព្វផ្សាយអ៊ីស្លាម ។ ឆ្នាំទី ៧ សករាជហ៊ុិច្ចរ៉េះត៍ ព្រះអង្គصلى الله عليه وآله وسلمបានសរសេរសំបុត្រផ្ញើទៅច្រើនប្រទេសជិតខាង ដោយស្នើសូមឲ្យប្រមុខរដ្ឋនិងប្រជារាស្ត្រមកកាន់អ៊ីស្លាម ។

សម័យនោះ មានមហាអំណាច ៤ នៅជុំវិញដែនដីអារ៉ាប៊ី ។

ម្ខាងមានមហាអំណាចអ៊ីរ៉ង់ដែលវាតចាប់ពីទ្វីបអាស៊ីកណ្តាល ទៅដល់ប្រទេសអ៊ីរ៉ាក់ ។

មហាអំណាចទី ២ គឺមហាអំណាចប៊ីសង់ទីន (Byzantine) ដែលពួកអារ៉ាប់ហៅថារ៉ូមនោះ ។ ចក្រភពប៊ីសង់ទីនក្តាប់ទ្វីបអាស៊ីតូច ប្រទេសស៊ីរីនិងដែនដីប៉ាលេស្ទីន ។

មហាអំណាចទី ៣ គឺប្រទេសអេស៊ីបត៍ ដែលធ្លាប់នៅក្រោមអំណាចចក្រភពប៊ីសង់ទីន តែពេលនេះមានឯករាជ្យវិញ ។

មហាអំណាចទី ៤ គឺមហាអំណាចអាប៊ីស៊ីនី (Abyssinie ឬ Abyssinia) ស្ថិតនៅឯប៉ែកខាងត្បូងនៃប្រទេសអេស៊ីបត៍ ដែលលាតសន្ធឹងឥទ្ធិពលទៅលើដែនដីឯទៀតនៃទ្វីបអាហ្វ្រិកដែលមានប្រជានិករ ។

ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានចាត់បញ្ជូនភ្នាក់ងារក្លាហានម្នាក់ ឈ្មោះអាុប់ឌុលឡោះហ្ញ៉ ហ៊្ញស្មាហ្វាស់ (عبدُ الله بنُ حُذَافَةَ السَّهْمِيُّ) ទៅជួបព្រះចៅអធិរាជនៃមហាអំណាចអ៊ីរ៉ង់ឈ្មោះ ឃុស្រូ ប៉ារវីស (خسرو بَرْوِيز) ។ ពេលគេអានសារអញ្ជើញមកកាន់អ៊ីស្លាមឲ្យស្តាប់ ព្រះចៅអធិរាជអង្គនេះក្រោធឆេះឆួល ។ ព្រះអង្គបានហែកសារខ្ទេចខ្ទី ហើយបានដេញអាុប់ឌុលឡោះហ្ញ៉ចេញពីវាំងទាំងកំរោល ។

ពេលអាុប់ឌុលឡោះហ្ញ៉ត្រឡប់មកម៉ាឌីណាស់វិញ បានតំណាលព្រឹត្តិការណ៍ដែលបានកើតឡើងនោះ ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمមានសេចក្តីទោមនស្ស ព្រះអង្គ

ﷺបានដាក់បណ្ដាសាឃុស្រូថា៖ "អល់ឡោះហ្ ﷻ អើយ សូមព្រះអង្គ ﷻ កម្ទេចអាណាចក្រស្ដេចនេះឲ្យខ្ទេចខ្ទី ។"

ព្រមនឹងពេលនោះ ព្រះចៅអធិរាជបូកធំរូបនេះបានផ្ញើសារទៅអាណាព្យាបាលប្រទេសយេមេន ដែលនៅក្នុងចំណុះខ្លួន ដាក់បញ្ជាឲ្យចាត់បញ្ជូនទ័ពទៅចាប់ខ្លួនព្រះសាស្ដាមូហាំម៉ាដ់ﷺមកកាន់រាជវាំងខ្លួន ។

ដូច្នេះ ភ្នាក់ងារយេមេនពីរនាក់បានចូលទៅក្នុងនគរម៉ាឌីណាស់ដើម្បីធ្វើតាមបញ្ជា ។ ពេលឃើញក្រុមមុស្លីមគាំទ្រព្រះសាស្ដាមូហាំម៉ាដ់ﷺយ៉ាងខ្លាំង ពួកភ្នាក់ងារដឹងថាមិនអាចចាប់ខ្លួនព្រះអង្គﷺបានឡើយ ។

ប៉ុន្តែភ្នាក់ងារទាំងពីរបានប្រាប់ព្រះសាស្ដាមូហាំម៉ាដ់ﷺ ឲ្យជ្រាបអំពីបញ្ជាដែលខ្លួនបានទទួលមក ហើយបានព្រមានព្រះអង្គﷺអំពីវិបត្តិដែលអាចកើតមកពីកំហឹងរបស់ព្រះចៅអធិរាជដ៏មានឥទ្ធិឫទ្ធិនៃប្រទេសអ៊ីរ៉ង់ ។ ព្រះសាស្ដាមូហាំម៉ាដ់ﷺបានតបវិញថា ឃុស្រូ ប៉ារវីស៍ ទើបនឹងត្រូវកូនប្រុសបង្កើតរបស់ខ្លួនឈ្មោះស្ញៀរវីយ៉ាស់ សម្លាប់ ហើយពេលនេះស្ញៀរវីយ៉ាស់ជាព្រះចៅអធិរាជថ្មី ។

ព្រះសាស្ដាមូហាំម៉ាដ់ﷺបានដាស់តឿនភ្នាក់ងារទាំងពីរ ឲ្យប្រាប់ប្រជារាស្ត្រយេមេនថាឲ្យដោះខ្លួនចេញពីការគ្រប់គ្រងរបស់អ៊ីរ៉ង់ ហើយមកចូលអ៊ីស្លាម ។ ការចេះដឹងដ៏អស្ចារ្យរបស់ព្រះសាស្ដាមូហាំម៉ាដ់ﷺ បានធ្វើឲ្យភ្នាក់ងារយេមេនស្ញប់ស្ញែងខ្លាំងណាស់ បុគ្គលទាំងពីរព្រមទទួលអ៊ីស្លាមជាសាសនាខ្លួនភ្លាម ហើយក្រោយមកប្រជារាស្ត្រយេមេនច្រើនបានទៅជាមុស្លីម ។

ព្រះសាស្ដាមូហាំម៉ាដ់ﷺបានចាត់បញ្ជូន ឌិះហ៊្យ៉ាស់ ប៊ិន អាល់-កាល់ប៊ី (دِحْيَة ٱبْن خَلِيفَة ٱلْكَلْبِيّ) ទៅជួប ហ៊ីរ៉ាក់ល៍ ឬ ហ៊ែរគ្គូល (هِرَقْل Hercules) ព្រះចៅអធិរាជរ៉ូម (ឬ ប៊ីសង់ទីន) ជាមួយព្រះរាជសារអញ្ជើញមកកាន់អ៊ីស្លាម ។ ព្រះចៅអធិរាជទទួលឌិះហ៊្យ៉ាស់ ដោយសេចក្ដីគោរព កោតស្ញើចសេចក្ដីនៅក្នុងព្រះរាជសារ ។

បន្ទាប់ពីបានស៊ើបសួរនៅឯដែនដីអារ៉ាប៊ី និងបន្ទាប់ពីបានពិភាក្សាជាមួយពួកមេសាសនារ៉ូម (គឺពួកមេសាសនាគ្រិស្ត) ព្រះចៅអធិរាជជឿជាក់ថាព្រះរាជសារមកពីព្រះសាស្ដាតែមួយដែលព្រះគម្ពីរតៅរ៉ត្តនិងព្រះគម្ពីរអ៊ីនយ៉ីលបានចែងរួចហើយ ។

តែព្រះចៅអធិរាជខ្លាចពួកមេសាសនាគ្រិស្តដែលសម្បូរឥទ្ធិពលនោះ ទម្លាក់អំណាចបើព្រះអង្គប្រកាសខ្លួនថាជាមុស្លីម ។ ទោះជាដូច្នេះក្ដី ព្រះអង្គបានសរសេរសំបុត្រទៅព្រះសាស្ដាមូហាំម៉ាដ់ﷺថាព្រះអង្គជឿ និងគោរពព្រះសាស្ដាមូហាំម៉ាដ់

ﷺ ហើយបានផ្ញើអំណោយឲ្យព្រះអង្គﷺ ។



ក្នុងចំណោមអំណោយទាំងនោះ មានសេះទេសសមួយ ឈ្មោះ ឌុលឌុល (دلدل) ដែលបានរស់នៅជាមួយអ៊ីមុាំអាលីصلوات الله عليه والسلامនិងបណ្តាកូនចៅព្រះអង្គصلوات الله عليه والسلام ក្រោយៗមក ។ ព្រះចៅអធិរាជរូម (ឬ ប៊ីសង់ទីន) បានឲ្យស្ត្រីទាសីពីរនាក់មកព្រះអង្គﷺដែរ ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបានរៀបការជាមួយនារីទាសីម្នាក់ឈ្មោះ ម៉ារីយ៉ាស់ អាល់-គិបទីយ៉ាស់ (مَارِيَةُ الْقِبْطِيَّةُ) ឯ ហាសាន់ ប៊ិន ស្សាប៊ីត (حسان ابن ثابت) រៀបការជាមួយនារីទាសីម្នាក់ទៀត ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានចាត់បញ្ជូន ហាទីប ប៊ិន អាប៊ី បាល់តាអាស់ (حَاطِبُ بْنُ أَبِي بَلْتَعَةَ)អ្នកដំណើរប្រកបដោយប្រាជ្ញាញាណនិងមានបទពិសោធន៍ច្រើនទៅជួបព្រះចៅ មូកៅគីស (الْمُقَوْقِسُ) ស្តេចប្រទេសអេស៊ីបត៍ ។ បន្ទាប់ពីបានអានព្រះរាជសារ ព្រះចៅ មូកៅគីស បានប្រើពេលរិះគិតយ៉ាងយូរអំពីខ្លឹមសារព្រះរាជសារ ។

នៅក្នុងការចរចាបន្ទាប់មក ហាទីប បានអធិប្បាយរៀបរាប់អំពីព្រះរាជសារ និងអំពីព្រះបេសកកម្មរបស់ព្រះសាស្តាមូហាំម៉ាដ់ﷺ ។ ទោះបីព្រះចៅ មូកៅគីស ជឿជាក់ពាក្យពេជន៍របស់ ហាទីប ក៏ដោយតែព្រះអង្គមិនទាន់ដាច់ស្រេចលាលែងតំណែងប្រមុខគណៈវិហារក្តុបត៍នៅឡើយទេ ។ ព្រះអង្គបានសរសេរសំបុត្រមួយច្បាប់សម្តែងសេចក្តីសោកស្តាយទៅព្រះសាស្តាមូហាំម៉ាដ់ﷺ ហើយបានផ្ញើអំណោយឲ្យទៅព្រះអង្គﷺតាម ហាទីប ។ ពេលបានទទួលសំបុត្រនៅម៉ាឌីណាស់ ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "ព្រះអង្គមិនទទួលសាសនាអ៊ីស្លាមទេ ព្រោះតែខ្លាចបាត់បង់អំណាចគ្រងរាជ្យ តែអំណាចនិងអាជ្ញាធររបស់ព្រះអង្គជិតដល់អវសានហើយ ។"

ព្រះសាស្តាមូហាំម៉ាដ់ﷺបានផ្ញើព្រះរាជសារពីរច្បាប់ ទៅព្រះចៅ អាស្វហាម៉ាស់ (أَصْحَمَة) ស្តេច ណាយ៉ាស្ស៊ី នៃដែនដី អាប៊ីស៊ីនី (អេត្យូពី) តាម អាំរូ ប៊ិន អ៊ូម៉ៃយ៉ាស់ ។ នៅក្នុងសំបុត្រមួយ ព្រះអង្គﷺអញ្ជើញស្តេចណាយ៉ាស្ស៊ីមកកាន់អ៊ីស្លាម ។ នៅក្នុងសំបុត្រមួយទៀត ព្រះអង្គﷺសូមឲ្យស្តេចណាយ៉ាស្ស៊ីអនុញ្ញាត

និងសូមជួយសម្រួលឲ្យ យ៉ាក់ហ្វារ ប៊ីន អាប៊ូ ត៉ូលិប និងមុស្លីមឯទៀតដែលបានភៀសខ្លួនទៅឯដែនដីអាប៊ីស៊ីនីកាលពីដើមសម័យអ៊ីស្លាមដ៏លំបាកនោះ អាចវិលត្រឡប់មកកាន់មាតុភូមិខ្លួនវិញបាន ។

ស្តេចបានទទួលសំបុត្រព្រះសាស្តាមូហាំម៉ាដ់ﷺ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ថែមទាំងសម្តែងសេចក្តីគោរពដោយថើបសំបុត្រនោះមុនបើកអានម្ល៉េះ ។ បន្ទាប់ពីបានអានសំបុត្រដំបូងរួចភ្លាម ព្រះចៅ នេគុស បានសូត្រកាលីម៉ាស្ហ៎ ហើយក៏បានទៅជាមុស្លីម ។ ព្រះអង្គបានសម្រួលឲ្យក្រុមមុស្លីមអាចវិលត្រឡប់ទៅកាន់មាតុភូមិវិញបាន ហើយបានចាត់ឲ្យរាជបុត្រព្រះអង្គឈ្មោះ វ៉ារហា ទៅជាមួយពួកគេ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានផ្ញើសំបុត្រច្រើនទៀតទៅប្រជាជាតិ និងប្រទេសឯទៀត ដូចជាព្រះអង្គម្ចាស់ កុស់សាន់ (غَسَّانَ) និងប្រមុខរដ្ឋយ៉ាម៉ាម៉ាស្ហ៎ (اليمامة) ជាដើម ។ តែបុគ្គលទាំងពីរនេះមិនបានប្តេជ្ញាជឿអ៊ីស្លាមយ៉ាងមុតមាំទេ ព្រោះអ៊ីស្លាមមិនស៊ីគ្នានឹងគោលនយោបាយរបស់ខ្លួន ។ តែប្រមុខរដ្ឋឯទៀតចាប់អារម្មណ៍អ៊ីស្លាម ហើយបានចាត់បញ្ជូនអ្នកតំណាងមកកាន់ម៉ាឌីណាស្ហ៎ដើម្បីសិក្សាបន្ថែមអំពីព្រះសាស្តាមូហាំម៉ាដ់ﷺនិងអ៊ីស្លាម ។

ដោយបានចាត់បញ្ជូនអ្នកនាំសារទៅកាន់ដែនដីទាំងអស់នេះ ព្រះសាស្តាមូហាំម៉ាដ់ﷺបានបញ្ជាក់ឲ្យឃើញថា អ៊ីស្លាមមិនមែនសាសនាសម្រាប់តែពួកអារ៉ាប់ដាច់មុខទេ តែអ៊ីស្លាមជាសាសនាសម្រាប់ពិភពលោកទាំងមូល ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. នៅជុំវិញដែនដីអារ៉ាប៊ីមានរដ្ឋអំណាចធំៗ ៤ តើមានរដ្ឋអំណាចណាខ្លះ ? តើព្រះសាស្តាមូហ៊ាំម៉ាដ់ﷺបានចាត់បញ្ជូនអ្វីទៅរកប្រមុខរដ្ឋទាំងនេះ ? ហេតុអ្វី ?

២. តើ ឃុសរូ ប៉ារវីស៊ ព្រះចៅអធិរាជនៃប្រទេសអ៊ីរ៉ង់ មានប្រតិកម្មអ្វី ? តើព្រះអង្គបានចេញបញ្ជាអ្វី ?

៣. តើព្រះចៅ ហ្វេៀរគ្នូល (هِرَقْل Hercules) ព្រះចៅអធិរាជរូម (ឬ ប៊ីសង់ទីន) មានប្រតិកម្មអ្វី ?

៤. តើព្រះចៅ មូកៅ្គីស (الْمُقَوْقِس) ស្តេចប្រទេសអេស៊ីបត៍ មានប្រតិកម្មអ្វី ?

៥. តើព្រះចៅ អាស្ហំហ្វាម៉ាស់ (أَصْحَمَة) ស្តេច នេគុស នៃដែនដី អាប៊ីស៊ីនី (អេត្យូពី) មានប្រតិកម្មអ្វី ?

## មេរៀនទី ១២

# សមរភូមិ ខុយ៉់បារ - ភាគ ១

នៅខាងជើងម៉ាឌីណាស្ញ មានទឹកដីមួយដែលមានជីវជាតិដែលគេហៅថា ច្រកឬជ្រលង ខុយ៉់បារ ។ ទឹកដីនេះមានប្រជារាស្ត្រយ៉ាហ្វូឌីរស់នៅ ២០០០០ នាក់ ដែលជំនាញខាងកសិកម្មនិងខាងធ្វើសឹក ។ ពួកគេបានសាងសង់បន្ទាយប្រាំពីរនៅ ខុយ៉់បារ ដើម្បីការពារខ្លួនពីការវាយប្រហារនានា ។

កាលប្រជាជាតិយ៉ាហ្វូឌី បានី កូយ៉់នូក៏អ៉ុ និងប្រជាជាតិ បានី ណាឌៀរ ត្រូវ បណ្តេញចេញពីម៉ាឌីណាស្ញ ព្រោះពួកគេបានរួមគំនិតគ្នាក្បត់ដោយវាយប្រហារ ពួកអ៊ីស្លាម ពួកគេមួយចំនួនបានតាំងលំនៅនៅឯខុយ៉់បារ ។ នៅទីនេះ ពួកគេនៅ តែគាំទ្រនិងជួយជ្រោមជ្រែងប្រជាជាតិអារ៉ាប់វាយប្រហាររដ្ឋអ៊ីស្លាម ។

ទោះបីបន្ទាប់ពីបានចាញ់ក្រុមមុស្លីមក្នុងសមរភូមិអាស្ញស្សាប់ក៏ដោយ ក៏ពួក យ៉ាហ្វូឌីនៅតែជាប្រភពគ្រោះថ្នាក់សម្រាប់បក្សមុស្លីមដែរ ។ ម្យ៉ាងទៀត ព្រះសាស្ដា មូហាំម៉ាដ្ញ ﷺ បានផ្ញើសំបុត្រទៅមេដឹកនាំប្រទេសជិតខាងជាច្រើន ព្រះអង្គ ﷺ ក្រែងបណ្ដាប្រមុខរដ្ឋដែលបានបដិសេធព្រះរាជសារអ៊ីស្លាមនោះ បែរទៅចូលដៃ ជាមួយពួកយ៉ាហ្វូឌីតំបន់ខៃយ៉់បារដើម្បីគំរាមបក្សមុស្លីម ។

ព្រះអង្គ ﷺ ទើបតែបានចុះហត្ថលេខា ធ្វើកិច្ចព្រមព្រៀងសន្តិសុខជាមួយពួក គូរ៉យ៉ស្ញ ដូច្នេះព្រះសាស្ដាមូហាំម៉ាដ្ញ ﷺ មិនបារម្ភអំពីពួកគេទេ ព្រះអង្គ ﷺ អាច ផ្ដោតអារម្មណ៍ទៅលើការកម្ចាត់គ្រោះថ្នាក់សម្រាប់អ៊ីស្លាមពីខុយ៉់បារ ។ ដូច្នេះព្រះ អង្គ ﷺ បានបញ្ជាឲ្យក្រុមមុស្លីមត្រៀមខ្លួន វាយយកមជ្ឈដ្ឋានចុងក្រោយរបស់ពួក យ៉ាហ្វូឌីនៅក្នុងដែនដីអារ៉ាប៊ី ។

ទ័ពមុស្លីមមានរេហ៍ពល ១៦០០ នាក់ ដោយមានរេហ៍ពលសេះ ២០០ នាក់ ។ ទ័ពមុស្លីមបានចេញដំណើរក្រោមទង់អ៊ីម៉ាំអាលី صلوات الله عليه والسلام ។

ដើម្បីរារាំងប្រជាជាតិ បានី ក៏ត្ហ្វាន (بني غَطَفَان) និង បានី ហ្វាស្សារ៉ាះត្ញ (بني فزارة) កុំឲ្យមកជួយបក្សពួកយ៉ាហ្វូឌីរបស់ខ្លួនបាន ព្រះសាស្ដាមូហាំម៉ាដ្ញ ﷺ បាន លើកទ័ពទៅប្រឈមនឹងពួកនេះជាដំបូងដើម្បីនឹងធ្វើឲ្យពួកគេចាកចេញពីលំនៅ ។

បន្ទាប់មក ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ បានបែរមុខព្រួញទៅរកខយ់បារ ពេលប្រជាជាតិទាំងពីរនេះដឹងថាគោលដៅពិតគឺពួកយ៉ាហ៊ូឌី វាយឺតពេលសម្រាប់ពួកគេមិនអាចមកជួយបក្សពួកខ្លួនបានទេ ។

បន្ទាយទាំងប្រាំពីរនៅតំបន់ខយ់បារឈ្មោះ ណាអ៊ីម (ناعم), ណាតាត់ (نَطَاة), ក៏មុស្វ (القَموص), កាទីបាស់ (الكَتِيبة), ស៊ីក្គ (الشِّق), វ៉ាទិះហ៊ា (الوَطِيح), ស៊ូឡាលិម (السُلاَلم) ។ បន្ទាយនីមួយៗមានឆ្មាំក្នុងប៉មយាមឃ្លាំមើលក្រែងលោមានបញ្ហា ។ បន្ទាយត្រូវសាងសង់ឡើងដើម្បីអាចការពារបរិវេណទាំងអស់បានដោយងាយ ឯកំផែងប្រដាប់ដោយអាវុធការពារដូចជាដង្ហក់ធំៗជាដើមសម្រាប់វាយច្រានសត្រូវ ។

ទ័ពមុស្លីមបានទៅដល់ជ្រលងខយ់បារ បន្ទាប់ពីបានពិនិត្យមើលស្ថានការណ៍ពួកគេបានកាន់កាប់កន្លែងចេញចូលសំខាន់ៗទាំងអស់ ដើម្បីកុំឲ្យពួកយ៉ាហ៊ូឌីរត់រួច ។

ពុំមានអ្នកណាបានឃើញទ័ពមុស្លីមមកដល់ទេ ពេលពួកកសិករចេញពីក្នុងបន្ទាយពេលព្រឹកនៃថ្ងៃបន្ទាប់ ពួកគេស្លន់ស្មារតីដែលពើបនឹងកងទ័ព ។ ពួកយ៉ាហ៊ូឌីរត់ចូលទៅក្នុងបន្ទាយវិញ ហើយពិភាក្សាគ្នារកមធ្យោបាយទប់ទល់ ។

ទីបំផុត ពួកគេបានសម្រេចនាំបណ្តាស្ត្រីនិងក្មេងៗទៅក្នុងបន្ទាយមួយ នាំស្បៀងទៅទុកនៅក្នុងបន្ទាយមួយទៀត ។ គេអាចធ្វើបែបនេះបានពីព្រោះបន្ទាយនានាអាចទាក់ទងគ្នាបានតាមរយៈផ្លូវរូងក្រោមដី ។ បន្ទាប់មកពួកយ៉ាហ៊ូឌីបានសម្រេចវាយក្រុមមុស្លីមពីបន្ទាយនីមួយៗ ដោយរើសយកយុទ្ធជនរបស់ខ្លួនដែលពូកែៗជាងគេ ។

ព្រមនឹងពេលនោះ ក្រុមមុស្លីមក៏រៀបចំខ្លួនប្រយុទ្ធដែរ ។ បន្ទាយខយ់បារមុនគេបង្អស់ដែលធ្លាក់ក្នុងកណ្តាប់ដៃបក្សមុស្លីមគឺបន្ទាយណាអ៊ីម ។ ក្នុងការវាយយកបន្ទាយនេះ មុស្លីមខ្លះបានស្លាប់ ច្រើនទៀតរងរបួស ។ យុទ្ធជនរងរបួសទាំងនេះត្រូវគេនាំទៅកាន់មន្ទីរព្យាបាលបណ្តោះអាសន្នដែលមានបណ្តាស្ត្រីប្រជាជាតិ បានីគីហ្វារ ជាអ្នកព្យាបាល ។

បន្ទាយទីពីរដែលបក្សមុស្លីមវាយយកបានគឺបន្ទាយក៏មុស្វ ។ បន្ទាប់ពីបានតស៊ូដោយពុះពារយ៉ាងស្វិតស្វាញ បន្ទាយនេះក៏ត្រូវវាយយកបានដែរ ។ ស្ត្រីពីរនាក់នៅក្នុងបន្ទាយត្រូវចាប់បាន ។ ស្ត្រីម្នាក់ឈ្មោះ ស្វហ្វីយ៉ាស់ (صَفِيَّة) កូនស្រីរបស់ហ៊ូយៃ ប៊ិន អាក់តុប់ (حُيَيُّ بْنُ أَخْطَبَ) បានរៀបការជាមួយព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ

ក្រោយមក ។ ការវាយយកបានបន្ទាយទាំងពីនេះបានធ្វើឲ្យបក្សមុស្លីមមានសេចក្តីទុកចិត្តច្រើនឡើង ឯពួកយ៉ាហ៊ូឌីវិញព្រួយបារម្ភនិងភ័យរន្ធត់ ។

បក្សមុស្លីមខ្វះស្បៀងខណៈដែលបន្តការឡោមព័ទ្ធបន្ទាយ ដូច្នេះពួកគេចាំបាច់ត្រូវបរិភោគសាច់សេះដែលច្បាប់ចែងថាម៉ាក់រុះហ៍តែមិនហាមឃាត់បរិភោគទេ ។

នៅក្នុងកាលៈទេសៈដ៏លំបាកនេះ បុរសគង្វាលចៀមម្នាក់ដែលមើលចៀមឲ្យពួកយ៉ាហ៊ូឌីមករកព្រះសាស្តាមូហាំម៉ាដ់ﷺ ។ បន្ទាប់ពីបានចរចាសាសង បុរសនេះជឿជាក់ថាអ៊ីស្លាមជាសាសនាពិត ហើយក៏បានទៅជាមុស្លីម ។ ពេលគាត់សួរថាតើត្រូវអ្វីអំពីសត្វចៀមដែលគេឲ្យគាត់មើលថែទាំនោះ ព្រះសាស្តាមូហាំម៉ាដ់ﷺបានប្រាប់គាត់យ៉ាងច្បាស់នៅចំពោះមុខយុទ្ធជនអត់បាយរាប់រយនាក់ថា៖ "នៅក្នុងសាសនាខ្ញុំﷺ ការក្បត់ពាក្យសន្យាជាបទឧក្រិដ្ឋធំមួយ ។ ចូរលោកនាំចៀមទៅឯទ្វារចូលបន្ទាយ ហើយប្រគល់ចៀមទាំងនេះឲ្យទៅម្ចាស់វាវិញ ។"

បុរសគង្វាលចៀមបានធ្វើតាមបញ្ជា បន្ទាប់មកបានចូលរួមក្នុងសមរភូមិ ហើយបានបូជាជីវិត ។

ដែលព្រះអង្គﷺធ្វើបែបនេះ ព្រះសាស្តាមូហាំម៉ាដ់ﷺចង់បង្ហាញឲ្យឃើញថាព្រះអង្គﷺមកកាន់ខ្ញយ់បារមិនមែនដើម្បីវាយយកទឹកដីឬទ្រព្យសម្បត្តិទេ តែគោលបំណងព្រះអង្គﷺ គឺកម្ចាត់គ្រោះថ្នាក់សម្រាប់អ៊ីស្លាមដែលកើតមកពីពួកយ៉ាហ៊ូឌី ។ ទោះបីបក្សពួកព្រះអង្គﷺនៅក្នុងអាសន្នអន្ទ្រក់ក៏ដោយ ក៏ព្រះអង្គﷺមិនអនុញ្ញាតឲ្យប្រើប្រាស់ទ្រព្យសត្រូវដោយខុសច្បាប់នោះទេ ផ្ទុយទៅវិញ ព្រះអង្គﷺសុខចិត្តបួងសួងអល់ឡោះហ៍ﷻវិញ សូមឲ្យបក្សមុស្លីមវាយយកបានបន្ទាយដែលមានស្បៀង ។

ថ្ងៃបានកន្លងទៅជាបន្តបន្ទាប់ បក្សមុស្លីមវាយយកបានបន្ទាយមួយបន្ទាប់បន្ទាយមួយ ។ ម្តងហើយម្តងទៀត វីរៈបុរសអ៊ីស្លាមបានសម្តែងឲ្យឃើញសេចក្តីក្លាហាននិងស្មារតីបូជាខ្លួនដើម្បីទទួលបាននូវព្រះពរអល់ឡោះហ៍ﷻ ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. អ្នកណារស់នៅឯជ្រលងខ្ញុំយ់បារ ?

២. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺវាយយកខ្ញុំយ់បារ ?

៣. តើមានបន្ទាយប៉ុន្មាននៅខ្ញុំយ់បារ ? គេបានសាងសង់បន្ទាយទាំងនេះដើម្បីអ្វី ?

៤. ព្រះសាស្តាមូហាំម៉ាដ់ﷺបានប្រាប់បុរសគង្វាលចៀម ថាត្រូវធ្វើអ្វីអំពីហ្វូងចៀមរបស់ពួកយ៉ាហ្ញូឌី ?

៥. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺប្រាប់បុរសគង្វាលចៀមឲ្យធ្វើដូច្នេះ ? តើព្រះអង្គﷺបានបួងសួងអល់ឡោះហ៍عز وجلសូមអ្វី បន្ទាប់មក ?

## មេរៀនទី ១៣

# សមរភូមិ ខុយ៉បារ - ភាគ ២

ក្រោយពីវាយយកបានបន្ទាយណាអ៊ីមនិងបន្ទាយក្វ៏មុស្វ បក្សមុស្លីមវាយយកបន្ទាយវ៉ាទ៊ិះហ្វ៍និងបន្ទាយស៊្វឡាលិម ។ បន្ទាយទាំងពីរនេះត្រូវការពារយ៉ាងប្រុងប្រយ័តបំផុត ទោះបីក្រោយពីបានប្រយុទ្ធអស់រយៈពេល ១០ ថ្ងៃក៏ដោយ ក៏បក្សមុស្លីមមិនអាចវាយយកបានដែរ ។

អាប៊ូ បាការ និង អ៊ុម៉ារ ក្នុងឱកាសផ្សេងៗ ព្យាយាមនាំក្រុមមុស្លីមចូលទៅក្នុងបន្ទាយតែត្រូវបង្ខំឲ្យដកថយវិញ ។ ពេលចុងក្រោយ អ៊ុម៉ារ បានធ្វើឲ្យក្រុមមុស្លីមបាក់ទឹកចិត្តដោយកោតសរសើរសេចក្តីក្លាហានរបស់មេដឹកនាំពួកយ៉ាហ៊្វូឌី យុទ្ធជនគួរខ្លាចម្នាក់ឈ្មោះ ម៉ារហាប់ ( مرحب بن الحارث)។ ទង្វើរបស់អ៊ុម៉ារមួយប្រការនេះបានធ្វើឲ្យព្រះសាស្តាមូហាំម៉ាដ្ឋ់صلی الله علیه وآله وسلمមានទោមនស្សបំផុត ។

ទីបំផុត ព្រះសាស្តាមូហាំម៉ាដ្ឋ់صلی الله علیه وآله وسلمបានថ្លែងសេចក្តីប្រកាសដ៏ល្បីសព្វកាលមួយ ។ ព្រះអង្គصلی الله علیه وآله وسلمមានព្រះវចនៈថា៖ "ថ្ងៃស្អែកខ្ញុំصلی الله علیه وآله وسلمនឹងប្រគល់ទង់ឲ្យទៅបុគ្គលដែលស្រឡាញ់អល់ឡោះហ្ម៍عز وجلនិងព្រះសាស្តា ឯអល់ឡោះហ្ម៍عز وجلនិងព្រះសាស្តាក៏ស្រឡាញ់បុគ្គលនោះដែរ ។ អល់ឡោះហ្ម៍عز وجلនឹងឲ្យបុគ្គលនោះវាយយកបន្ទាយនេះបាន ។ បុរសនោះមិនដែលបែរខ្នងដាក់សត្រូវឡើយ មិនដែលរត់គេចសមរភូមិឡើយ ។"

យុទ្ធជនទាំងអស់ឆ្ងល់ចង់ដឹងថាបុរសនោះគឺអ្នកណា ស្អែកឡើងយុទ្ធជនទាំងអស់គ្នាបានប្រជុំគ្នាជុំវិញព្រះសាស្តាមូហាំម៉ាដ្ឋ់صلی الله علیه وآله وسلم ដើម្បីចង់ឃើញបុគ្គលដែលនឹងត្រូវជ្រើសរើសជាអ្នកដឹកនាំយុទ្ធជន ។ ព្រះសាស្តាមូហាំម៉ាដ្ឋ់صلی الله علیه وآله وسلمសួរថា៖ "ឯណាអាុលីصلوات الله علیه والسلام ។"

គេបានទូលព្រះអង្គصلی الله علیه وآله وسلمថាអាុលីصلوات الله علیه والسلامឈឺភ្នែកធ្ងន់ មើលអ្វីមិនឃើញទេ ។ ព្រះអង្គصلی الله علیه وآله وسلمបានឲ្យគេនាំអ៊ីម៉ាំអាុលីصلوات الله علیه والسلامមកជួបព្រះអង្គصلی الله علیه وآله وسلم ។ ពេលអ៊ីម៉ាំអាុលីصلوات الله علیه والسلامមកដល់ ព្រះសាស្តាមូហាំម៉ាដ្ឋ់صلی الله علیه وآله وسلمបានញីភ្នែកព្រះអង្គصلوات الله علیه والسلامហើយបានបួងសួងសូមឲ្យជាសះស្បើយ ។ ភ្នែកអ៊ីម៉ាំអាុលីصلوات الله علیه والسلامក៏បានជាសះស្បើយមួយរំពេច ព្រះអង្គصلی الله علیه وآله وسلم

លែងមានបញ្ហាភ្នែកទៀតឡើយ ។

បន្ទាប់មក ព្រះសាស្តាមូហាំម៉ាដ់ﷺបានបញ្ជាឲ្យអ៊ីមុាំអាលីصلوات الله عليه والسلامចូលប្រយុទ្ធនឹងសត្រូវ ។ ព្រះអង្គﷺបានប្រាប់ឲ្យអ៊ីមុាំអាលីصلوات الله عليه والسلامសូមពួកមេដឹកនាំបន្ទាយឲ្យទទួលសាសនាអ៊ីស្លាម ។ បើពួកគេបដិសេធ ឲ្យព្រះអង្គصلوات الله عليه والسلامឲ្យពួកគេសូមចុះចាញ់និងរស់នៅដោយសេរីក្រោមអាណាព្យាបាលរបស់បក្សមុស្លីម ដោយបង់ពន្ធឲ្យរដ្ឋអ៊ីស្លាម ។ បើពួកគេបដិសេធសំណូមពរនេះដែរ ឲ្យព្រះអង្គصلوات الله عليه والسلامប្រយុទ្ធ ។

អ៊ីមុាំអាលីصلوات الله عليه والسلامចូលទៅជិតបន្ទាយ ប្រដាប់គ្រោះសង្គ្រាមដ៏មាំនិងកាន់ដាវផែកចុងឈ្មោះ ស៊ុល ហ្វីកា្ក (ذُو الْفَقَار) ។

បក្សយ៉ាហ៊ូឌីបានចាត់បញ្ជូនយុទ្ធជនពួកគេដែលពូកែដាច់គេឈ្មោះ ហារីស្ស បងប្អូនរបស់ ម៉ារហាប់ មកប្រយុទ្ធ ។ យុទ្ធជនមុស្លីមភ័យរឹងខ្លួននឹងថ្កល់ពេលឃើញហារីស្សបុរសដ៏សម្បើម ដើរចូលមករកពួកគេ ។ តែអ៊ីមុាំអាលីصلوات الله عليه والسلامចូលទៅប្រឈមមុខនឹងហារីស្ស ។ បន្ទាប់ពីបានប្រយុទ្ធគ្នាបន្តិច ហារីស្សដេកស្លាប់លើដី ។

ម៉ារហាប់ក្រោធណាស់ពេលប្អូនខ្លួនស្លាប់ ។ គាត់បានចេញពីក្នុងបន្ទាយប្រដាប់អាវុធពេញខ្លួន ប្រុងកាប់សម្លាប់ឥតបង្អង់ដៃ ។ គាត់ពាក់គ្រោះសង្គ្រាមដ៏មាំពាក់មួកធ្វើអំពីថ្មពីក្រោមមួកដែក ។ ពេលគាត់បង្អួតខ្លួនដាក់បក្សមុស្លីមឲ្យចេញមកប្រយុទ្ធ គាត់សូត្រកាព្យសង្គ្រាមថា៖ "កំផែងខៃប៉បារជាសាក្សីទទួលស្គាល់ថាខ្ញុំឈ្មោះម៉ារហាប់ ។ ខ្ញុំជាយុទ្ធជនពូកែដាច់គេ ។ អ្នកណាប្រយុទ្ធទល់នឹងខ្ញុំក្នុងលានប្រយុទ្ធ អ្នកនោះងូតឈាមខ្លួនឯង ។"

អ៊ីមុាំអាលីصلوات الله عليه والسلامដើរចូលលានប្រយុទ្ធដោយថ្លែងពាក្យពេជន៍ផ្ទាល់ខ្លួនថា៖ "ខ្ញុំصلوات الله عليه والسلامជាបុគ្គលដែលម្តាយដាក់ឈ្មោះឲ្យថា ហៃដារ (حَيْدَرُ) រាជសីសាហាវ ។ ខ្ញុំصلوات الله عليه والسلامឈ្នះសត្រូវយ៉ាងលឿនក្នុងលានប្រយុទ្ធ ។"

អ៊ីមុាំអាលីصلوات الله عليه والسلامបានជ្រើសរើសពាក្យពេជន៍ដោយរិះគិតល្អិតល្អន់ ។ ព្រះអង្គصلوات الله عليه والسلامបានដឹងថាថ្មីៗនេះ ម៉ារហាប់ដេកយល់សប្តិឃើញតោហែកគាត់ដាច់ជាកំណាត់ៗ ដូច្នេះសម្តីអ៊ីមុាំអាលីصلوات الله عليه والسلامធ្វើឲ្យម៉ារហាប់ភ្ញាក់ផ្អើលនិងច្របូកច្របល់អារម្មណ៍ ។ តែម៉ារហាប់ដើរចូលដោយច្រឡោត គួរឲ្យខ្លាច ប្រុងប្រើគ្រប់មធ្យោបាយដើម្បីសងសឹកឲ្យប្អូនខ្លួន ។

សម្ពុះដែលផ្ទុះឡើងរវាងយុទ្ធជនទាំងពីរ ធ្វើឲ្យទស្សនិកជនស្ងើចអនេក ។ រំពេចនោះ ម៉ារហាប់បុះលំពែងមុខបីសំដៅអ៊ីមុាំអាលីصلوات الله عليه والسلام អ៊ីមុាំអាលីصلوات الله عليه والسلامគេចផុត

មុខលំពែង កាប់តបវិញពេញទំហឹងតម្រង់ក្បាលម៉ារហ៊ាប់ ។ ដាវអ៊ីម៉ាំអាលី صلوات الله عليه والسلام ពុះមួកដែក ពុះមួកធ្វើអំពីថ្ម ពុះក្បាលម៉ារហ៊ាប់រហូតដល់ធ្មេញ ។

បក្សយ៉ាហ៊្វូឌីស្ងាត់មាត់ស្ងន្យឈឹងពេលឃើញវីរៈបុរសខ្លួនរលំ ។ ខណៈព្រះអង្គ صلوات الله عليه والسلام ស្រែកថា "អល់ឡ៎ហ៊្វ អាក់បារ!" ជាសញ្ញាជ័យជំនះ អ៊ីម៉ាំអាលី صلوات الله عليه والسلام ត្រូវយុទ្ធជនយ៉ាហ៊្វូឌីជំនាញៗព័ទ្ធជុំជិត ។ តែពួកគេមិនស័ក្តិសមនឹងកម្លាំងព្រះអង្គ صلوات الله عليه والسلام ទេ ទាំងអស់គ្នាដេកស្លាប់យ៉ាងឆាប់ ។

ពេលកំពុងប្រយុទ្ធគ្នា គេបានវាយអ៊ីម៉ាំអាលី صلوات الله عليه والسلام បែកខែល ។ ព្រះអង្គ صلوات الله عليه والسلام បានត្រឡប់ទៅឯទ្វារបន្ទាយ កាច់ទ្វារនេះចេញពីត្រចៀកទ្វារយកមកប្រើជាខែល ។ ពេលព្រះអង្គ صلوات الله عليه والسلام បោះទ្វារនោះចោលនៅទីបញ្ចប់ សូម្បីតែមុស្លីម ១០ នាក់ក៏មិនអាចលើកទ្វារនោះរួចដែរ ។ ក្រោយមក អ៊ីម៉ាំអាលី صلوات الله عليه والسلام បានអធិប្បាយថាព្រះអង្គ صلوات الله عليه والسلام លើកទ្វារនោះអាស្រ័យកម្លាំងរបស់អល់ឡោះហ៊្វ عز وجل ដោយសារព្រះអង្គ صلوات الله عليه والسلام ជឿជាក់លើថ្ងៃជំនុំជម្រះ ។

ដោយសារសេចក្តីក្លាហានរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام បក្សមុស្លីមវាយយកបានបន្ទាយ ។ បន្ទាយទាំងអស់ក៏បានធ្លាក់មកក្នុងកណ្តាប់ដៃបក្សមុស្លីមយ៉ាងឆាប់ ។ បក្សមុស្លីមបានបាត់បង់បក្សពួក ២០ នាក់ក្នុងចម្បាំង ឯពួកយ៉ាហ៊្វូឌីបានស្លាប់ ៩៣ នាក់ ។ ព្រះសាស្តាមូហ៊ាំម៉ាដ់ صلى الله عليه وآله وسلم បានធ្វើឲ្យពួកយ៉ាហ៊្វូឌីដឹងថាល្បួចធ្វើអំពើអាក្រក់មកលើបក្សមុស្លីមនោះមិនបានប្រយោជន៍ទេ ។ ក្រោយពីបានឈ្នះសង្គ្រាម ព្រះអង្គ صلى الله عليه وآله وسلم បានប្រគល់ដីធ្លីទាំងអស់ឲ្យទៅពួកយ៉ាហ៊្វូឌីវិញ ដោយដាក់បញ្ជាលើពួកគេឲ្យប្រគល់ផលដែលបានមកពីកសិកម្មចំនួនពាក់កណ្តាលឲ្យបក្សមុស្លីម ជាថ្លៃការពារពួកគេ ។

តែពួកយ៉ាហ៊្វូឌីមិនភ្លេចសេចក្តីអាម៉ាស់មុខ ដោយសារបក្សមុស្លីមនោះទេ ។ ក្រោយពីបានចាញ់គេ ស្ត្រីយ៉ាហ៊្វូឌីម្នាក់ឈ្មោះស្សៃណាប់បានយកសាច់ចៀមមកឲ្យព្រះសាស្តាមូហ៊ាំម៉ាដ់ صلى الله عليه وآله وسلم ។ សាច់នោះត្រូវដាក់ថ្នាំបំពុល ទោះបីព្រះសាស្តា صلى الله عليه وآله وسلم បានសោយតែបន្តិចក៏ដោយ តែវាមានឥទ្ធិពលក្នុងរយៈពេលដ៏យូរ ។ ច្រើនឆ្នាំក្រោយមក កាលព្រះអង្គ صلى الله عليه وآله وسلم ជិតសោយទិវង្គត ព្រះអង្គ صلى الله عليه وآله وسلم មានវចនៈថាជម្ងឺព្រះអង្គ صلى الله عليه وآله وسلم បណ្តាលមកពីថ្នាំបំពុលនេះមួយចំណែកដែរ ដែលគេបានបំពុលព្រះអង្គ صلى الله عليه وآله وسلم នៅឯខ៉ុយបារនោះ ។

ថ្ងៃដែលបក្សមុស្លីមទទួលជ័យជំនះ ក្រុមមុស្លីមដែលបានភៀសខ្លួនពី

ម៉ាក់កាស៊ុំទៅកាន់ដែនដីអាប៊ីស៊ីនីនោះបានត្រឡប់មកដល់មាតុភូមិវិញ ។ ព្រះសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلمត្រេកអរជាទីបំផុត ព្រះអង្គصلى الله عليه وآله وسلمមានព្រះវចនៈថាព្រះអង្គصلى الله عليه وآله وسلمស្មានមិនត្រូវទេថាអ្វីដែលធ្វើឲ្យព្រះអង្គصلى الله عليه وآله وسلمត្រេកអរនោះ គឺជ័យជំនះខ៉ុយបារ ឬក៏ការវិលត្រឡប់ មកពីដែនដីអាប៊ីស៊ីនីវិញរបស់បងប្អូនជីតាមួយរបស់ព្រះអង្គصلى الله عليه وآله وسلمយ៉ាកុំហ្វារ ប៊ិន អាប៊ូ ត៉ុលិបនិងមុស្លីមឯទៀត ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. អ៊ុម៉ារបានធ្វើអ្វីនៅឯសមរភូមិខុយ់បារ បានជាព្រះសាស្តាមូហ៊ាំម៉ាដ់صلى الله عليه وآله وسلم មិនសប្បាយចិត្ត ?

២. សេចក្តីប្រកាសដ៏ល្បីរបស់ព្រះសាស្តាមូហ៊ាំម៉ាដ់صلى الله عليه وآله وسلمពេលចម្បាំង មានខ្លឹមសារអ្វីខ្លះ ? ព្រះរាជសារនេះផ្តោតទៅលើអ្នកណា ?

៣. អុីមុាំអុាលីصلوات الله عليه والسلامកើតអ្វី ? ព្រះអង្គصلوات الله عليه والسلامជាសះស្បើយដូចម្តេច ?

៤. ផ្លូវបីដែលព្រះសាស្តាមូហ៊ាំម៉ាដ់صلى الله عليه وآله وسلمបានបើកឲ្យពួកសត្រូវ តាមរយៈអុីមុាំអុាលីصلوات الله عليه والسلامនោះ គឺមានផ្លូវអ្វីខ្លះ ?

៥. អុីមុាំអុាលីصلوات الله عليه والسلامបានសូត្រកំណាព្យសង្គ្រាមអ្វី ហេតុអ្វីកំណាព្យនេះ ?

**មេរៀនទី ១៤**

# រឿងហ្វាដាក់

ក្រោយពីបានឈ្នះសមរភូមិខុយបារ ព្រះសាស្តាមូហាំម៉ាដ់ﷺបានសម្រេចកម្ទេចមូលដ្ឋានទ័ពយ៉ាហ៊ូឌីដែលនៅសេសសល់ ដើម្បីកម្ចាត់គ្រោះថ្នាក់សម្រាប់អ៊ីស្លាមឲ្យអស់សូន្យបង់តែម្តង ។ ដូច្នេះ ព្រះអង្គﷺផ្តោតអារម្មណ៍ទៅលើភូមិយ៉ាហ៊ូឌីមួយនៅឯហ្វាដាក់ (فَدَك) ដែលជាតំបន់មានជីវជាតិស្ថិតនៅឯខាងជើងម៉ាឌីណាស់ ចម្ងាយ ១៨០ គីឡូម៉ែត្រ ។

ព្រះអង្គﷺបានចាត់បញ្ជូនគណៈប្រតិភូ ទៅជួបបណ្តាព្រឹទ្ធាចារ្យនៃស្រុកហ្វាដាក់ ។ មេភូមិចង់បានសន្តិភាពជាជាងប្រយុទ្ធ ។ ប្តូរនឹងការគាំពារពីបក្សមុស្លីម មេភូមិយល់ព្រមប្រគល់កសិផលនៃតំបន់នេះចំនួនពាក់កណ្តាល ឲ្យទៅព្រះសាស្តាមូហាំម៉ាដ់ﷺ ។

តាមច្បាប់អ៊ីស្លាម ដីធ្លីដែលវាយយកបានដោយកម្លាំងឬដោយធ្វើសង្គ្រាមទៅជាកម្មសិទ្ធិរបស់ពួកមុស្លីមហើយត្រូវគ្រប់គ្រងដោយរដ្ឋបាលមុស្លីម ។ តែដីធ្លីដែលត្រូវប្រគល់ឲ្យទៅពួកមុស្លីមដោយពុំបានធ្វើសង្គ្រាម ដូចជាករណីហ្វាដាក់ជាដើម ជាកម្មសិទ្ធិរបស់ព្រះសាស្តាមូហាំម៉ាដ់ﷺ បន្ទាប់ពីព្រះសាស្តាមូហាំម៉ាដ់ﷺ ជាកម្មសិទ្ធិរបស់ព្រះសន្តអ៊ីម៉ាំនៃសម័យកាលនោះ ។ ព្រះសាស្តាﷺឬអ៊ីម៉ាំសម័យកាលអាចចែកដីធ្លីនេះឲ្យទៅអ្នកណាក៏បានស្រេចតែចិត្ត ។ អាយ៉ាស់ខាងក្រោមនេះជាភ័ស្តុតាង (ស៊ូរ៉ោះត៊ុ អាល់-ហាស្ស៊រ៍, 59:7) គឺ៖

مَّآ أَفَآءَ ٱللَّهُ عَلَىٰ رَسُولِهِۦ مِنۡ أَهۡلِ ٱلۡقُرَىٰ فَلِلَّهِ وَلِلرَّسُولِ وَلِذِي ٱلۡقُرۡبَىٰ وَٱلۡيَتَٰمَىٰ وَٱلۡمَسَٰكِينِ وَٱبۡنِ ٱلسَّبِيلِ كَيۡ لَا يَكُونَ دُولَةَۢ بَيۡنَ ٱلۡأَغۡنِيَآءِ مِنكُمۡۚ وَمَآ ءَاتَىٰكُمُ ٱلرَّسُولُ فَخُذُوهُ وَمَا نَهَىٰكُمۡ عَنۡهُ فَٱنتَهُواْۚ وَٱتَّقُواْ ٱللَّهَۖ إِنَّ ٱللَّهَ شَدِيدُ ٱلۡعِقَابِ ٧

*7. អ្វីដែលអល់ឡោះប៉ាបានប្រទានឲ្យសាស្តាព្រះអង្គ ដែលបានមកពី[បណ្តាទ្រព្យនៃ]ប្រជាជននៃស្រុកនានា[ដោយពុំបានប្រយុទ្ធ] ជាកម្មសិទ្ធិរបស់អល់ឡោះប៉ា របស់ព្រះសាស្តានិងសាច់ញាតិជិតស្និទ្ធរបស់គេ របស់កូនកំព្រា របស់អ្នកក្រីក្រ និងរបស់អ្នកធ្វើដំណើរ[នៅលើផ្លូវអល់ឡោះប៉ា] ។ នេះដើម្បីនឹងកុំឲ្យអ្វីដែលយកបាន*

*មកនោះបានទៅលើបណ្តាអ្នកមានក្នុងចំណោមពួកអ្នក ។ ចូរពួកអ្នកទទួលយកនូវអ្វីមួយដែលព្រះសាស្តាឲ្យពួកអ្នក ចូរពួកអ្នកចៀសអ្វីដែលគេហាមពួកអ្នក ។ ចូរពួកអ្នកខ្លាចអល់ឡោះហ្ទ៍ ពិតណាស់អល់ឡោះហ្ទ៍តឹងរ៉ឹងក្នុងការធ្វើទោស ។*

ដូច្នេះ ដីធ្លីហ្វាដាក់ទៅជាកម្មសិទ្ធិរបស់ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلم ហើយពេលអល់ឡោះហ្ទ៍عز وجلបានបើកឲ្យដឹងអាយ៉ាស់ 26 ក្នុងស៊ូរ៉ោះត៍ បានី អ៊ីសរ៉ាអ៊ីល (17:26) គឺ៖

وَءَاتِ ذَا ٱلْقُرْبَىٰ حَقَّهُۥ وَٱلْمِسْكِينَ وَٱبْنَ ٱلسَّبِيلِ وَلَا تُبَذِّرْ تَبْذِيرًا ﴿٢٦﴾

*26. ចូរអ្នកប្រគល់ឲ្យទៅបណ្តាសាច់ញាតិជិតស្និទ្ធអ្នក នូវអ្វីដែលពួកគេត្រូវបាន ព្រមទាំងអ្នកក្រខ្សត់និងអ្នកដំណើរ [លើមាគ៌ាអល់ឡោះហ្ទ៍] ចូរអ្នកកុំចាយវាយខ្ជះខ្ជាយ ។*

ព្រះអង្គصلى الله عليه وآله وسلمក៏បានប្រគល់ហ្វាដាក់ឲ្យទៅព្រះនាងហ្វាទីម៉ាស់سلام الله عليها ព្រះរាជបុត្រីជាទីស្រឡាញ់របស់ព្រះអង្គصلى الله عليه وآله وسلم ។



ព្រះអង្គصلى الله عليه وآله وسلمបានធ្វើបែបនេះដោយមានមូលហេតុច្រើន ។ ដំបូង ពីព្រោះគេបានដាក់ព្រះរាជបញ្ជាឲ្យព្រះអង្គصلى الله عليه وآله وسلم ប្រគល់ឲ្យទៅសាច់ញាតិជិតស្និទ្ធិរបស់អង្គصلى الله عليه وآله وسلم នូវអ្វីដែលសាច់ញាតិជិតស្និទ្ធនោះត្រូវបាន ។ ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمនិងមុស្លីមទាំងអស់ជំពាក់គុណព្រះនាងខ៌ឌីយ៉ាស់سلام الله عليهاច្រើនណាស់ ព្រោះព្រះនាងسلام الله عليهاបានលះបង់ទ្រព្យសម្បត្តិទាំងអស់របស់ខ្លួនسلام الله عليهاដើម្បីពួកមុស្លីមមុនៗ ។ ប្រាក់របស់ព្រះនាងسلام الله عليهاត្រូវបានប្រើប្រាស់សម្រាប់ផ្សព្វផ្សាយអ៊ីស្លាម សម្រាប់ដោះបណ្តាមុស្លីមដែលជាទាសៈទាសីបម្រើគេឲ្យមានសេរីភាព និងសម្រាប់គាំទ្រពួកគេក្នុងកាលៈទេសៈលំបាកដូចជាក្នុងអំឡុងពេល ៣ ឆ្នាំដែលពួកគេរងពិហិការ (គឺត្រូវគេសង្កត់សង្កិនផ្នែកសេដ្ឋកិច្ច) នៅម៉ាក់កាស់នោះជាដើម ។

ពេលនេះ ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمអាចសងគុណព្រះនាងខ៌ឌីយ៉ាស់سلام الله عليهاវិញ

ដោយបានឲ្យដីហ្វាដាក់ដ៏សម្បូរជីវជាតិទៅព្រះរាជបុត្រី سلام الله عليها របស់ព្រះនាង سلام الله عليها ជាអំណោយ ។ ព្រះអង្គ صلى الله عليه وآله وسلم ដឹងដែរថាអ៊ីម៉ាំអាលី صلوات الله عليه والسلام នឹងត្រូវការហ្វាដាក់ជាប្រភពនៃប្រាក់ចំណូលដើម្បីរក្សាតំណែងខ៊ិលិហ្វរបស់ព្រះអង្គ صلوات الله عليه والسلام ។

មូលហេតុចុងក្រោយ គឺព្រះអង្គ صلى الله عليه وآله وسلم មានបំណងទុកនូវបេបនីយភណ្ឌ (ទ្រព្យតម្កល់ទុក) ឲ្យព្រះរាជបុត្រី سلام الله عليها និងព្រះរាជនត្តា عليهم السلام របស់ព្រះអង្គ صلى الله عليه وآله وسلم ដើម្បីនឹងអាចរស់នៅបានដោយថ្លៃថ្នូរបន្ទាប់ពីព្រះអង្គ صلى الله عليه وآله وسلم សោយទិវង្គត ។

តែពេលព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم សោយទិវង្គត អាប៊ូ បាការ ដែលបានប្លន់យកខ៊ិលីហ្វាស់របស់អ៊ីម៉ាំអាលី صلوات الله عليه والسلام នោះ បានដណ្ដើមយកហ្វាដាក់ពីព្រះនាងហ្វាទីម៉ាស់ ។ គាត់បានធ្វើបែបនេះដើម្បីនឹងកុំឲ្យអ៊ីម៉ាំអាលី صلوات الله عليه والسلام អាចមានមធ្យោបាយទាមទារសិទ្ធិព្រះអង្គ صلوات الله عليه والسلام វិញបាន ។

ពេលភ្នាក់ងាររបស់ព្រះនាង سلام الله عليها បានប្រាប់ព្រះនាង سلام الله عليها ថា ពួកគេត្រូវគេផ្លាស់ដោយមនុស្សរបស់ខ៊ិលិហ្វថ្មី ព្រះនាងហ្វាទីម៉ាស់ سلام الله عليها បានតវ៉ាដោយប្រើមធ្យោបាយស្របច្បាប់ ។

អាប៊ូ បាការ មិនចង់ស្ដាប់មូលហេតុព្រះនាង سلام الله عليها ទេ ហើយបានឲ្យព្រះនាង سلام الله عليها នាំសាក្សីមកបង្ហាញគាត់ ។ ទោះបីព្រះនាង سلام الله عليها ជាម្ចាស់ហ្វាដាក់ស្រេចហើយក៏ដោយ ទោះបីពុំមានការសង្ស័យសោះថាហ្វាដាក់ពុំមែនជាកម្មសិទ្ធរបស់ព្រះនាង سلام الله عليها ក៏ដោយ តែព្រះនាង سلام الله عليها បាននាំសាក្សីពីរនាក់មកបង្ហាញគាត់ ។ សាក្សីពីរនាក់នោះគឺអ៊ីម៉ាំអាលី صلوات الله عليه والسلام និងស្ត្រីម្នាក់ឈ្មោះ អ៊ុម អៃម៉ាន (أم أيمن) ដែលព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានធានារួចមកហើយថាស្ត្រីរូបនេះនឹងបានចូលឋានសួគ៌ ។

ទោះបីព្រះនាងហ្វាទីម៉ាស់ سلام الله عليها បានបង្ហាញសាក្សីទាំងនេះក៏ដោយ ក៏ អាប៊ូ បាការ នៅតែបដិសេធដែរ ដោយសំអាងលើសម្ដីចចាមអារ៉ាមមួយថា៖ "ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ ‘យើង ព្រះសាស្តា មិនទទួលកេរមរតកទេ មិនបន្សល់ទុកនូវកេរមតកទេ ។ អ្វីដែលសល់ពីយើងជាសទ្ធាទាន’ ។"

នេះគឺសម្ដីភូតភរពិតប្រាកដ ពុំមានអ្នកណាក្រៅពី អាប៊ូ បាការ ថាខ្លួនធ្លាប់បានឮសម្ដីនេះទេ ។

ព្រះនាងហ្វាទីម៉ាស់ سلام الله عليها បានថ្លែងសុន្ទរកថាមួយ ប្រកបដោយវោហារកោសល្យ ដោយចាប់ផ្ដើមដោយអធិប្បាយបំភ្លឺអំពីការមានអល់ឡោះហ៍ عز وجل ជាព្រះតែមួយគត់និងអំពីខ្លឹមសាររបស់បេសកកម្មរបស់ព្រះបិតា صلى الله عليه وآله وسلم ព្រះនាង سلام الله عليها ។ បន្ទាប់

មក ព្រះនាងسلام الله عليهاបានបង្ហាញភ័ស្តុតាងដែលបញ្ជាក់ថា អាប៊ូ បាការ និយាយកុហក ដោយលើកឡើងនូវ អាយ៉ាស់ 16 ក្នុងស៊ូរ៉េះត៍ អាន់-ណាំល៍ (27:16) គឺ៖

وَوَرِثَ سُلَيْمَـٰنُ دَاوُۥدَ ۖ وَقَالَ يَـٰٓأَيُّهَا ٱلنَّاسُ عُلِّمْنَا مَنطِقَ ٱلطَّيْرِ وَأُوتِينَا مِن كُلِّ شَىْءٍ ۖ إِنَّ هَـٰذَا لَهُوَ ٱلْفَضْلُ ٱلْمُبِينُ ﴿١٦﴾

*16. ស៊ូឡៃម៉ានបានទទួលកេរមរតកពីដាវូដ ហើយគេបានថា៖ "ប្រជារាស្ត្រអើយ គេបានបង្ហាត់យើងឲ្យចេះភាសាសត្វស្លាប ហើយគេបានប្រទានឲ្យយើងនូវសព្វសារពើ ។ នេះគឺព្រះគុណូបការៈ[របស់អល់ឡោះម្ចាស់]ដ៏ជាក់ច្បាស់ ។"*

ទោះបី អាប៊ូ បាការ ខ្មាសខ្លួនឯងដែលបានប្រព្រឹត្តបែបនេះ ហើយបានប្រគល់ហ្វាដាក់ឲ្យព្រះនាងسلام الله عليهاវិញក៏ដោយ ក៏ព្រះនាងហ្វាទីម៉ាស់سلام الله عليهاមិនលើកទោសឲ្យគាត់ជាដាច់ខាតមួយជីវិត ។ ៦ ខែក្រោយព្រះបិតាصلى الله عليه وآله وسلمព្រះនាងسلام الله عليهاបានសោយទិវង្គត ពេលបញ្ចុះព្រះរាជសពព្រះនាងسلام الله عليها គេមិនអនុញ្ញាតឲ្យ អាប៊ូ បាការ ចូលរួមផងទេដោយធ្វើតាមបណ្តាំព្រះនាងسلام الله عليها ។

ទីបំផុត អាប៊ូ បាការ បានសរសេរសារលិខិតបញ្ជាក់ថាហ្វាដាក់ជាកម្មសិទ្ធិរបស់ព្រះនាងហ្វាទីម៉ាស់سلام الله عليهاដាច់មុខ ហើយបានប្រគល់ដីធ្លីឲ្យព្រះនាងسلام الله عليهاវិញ ។ តែពេលត្រឡប់ទៅផ្ទះវិញ អ៊ូម៉ារ បានជួបព្រះនាងسلام الله عليهاដោយចៃដន់ ហើយបានដឹងអំពីខ្លឹមសារក្នុងសារលិខិត ។ គាត់ក៏បានកញ្ឆក់យកសារលិខិតនេះទៅជួប អាប៊ូ បាការ ដោយថា៖ "អាលីصلوات الله عليه والسلامជាអ្នកមានឈ្មោះទទួលមរតកនេះ ការធ្វើសាក្សីរបស់គេصلوات الله عليه والسلامទុកជាមោឃៈ ។ ចំណែកឯ អ៊ូម អៃម៉ាន វិញ គាត់ជាស្ត្រីហើយការធ្វើសាក្សីរបស់គាត់ក៏ទុកជាមោឃៈដែរ ។"

ពេលថា គាត់បានហែកសារលិខិតចោលនៅពីមុខ អាប៊ូ បាការ ។ ទង្វើនេះធ្វើឲ្យព្រះនាងហ្វាទីម៉ាស់سلام الله عليهاឈឺចាប់ណាស់ ព្រះនាងسلام الله عليهاបានដាក់បណ្តាសា អ៊ូម៉ារ ថា៖ "សូមឲ្យអល់ឡោះម្ចាស់عزّ وجلّធ្វើឲ្យពោះអ្នកឯងរហែកខ្ទេចខ្ទីដូចនេះដែរ ។"

បណ្តាសានេះបានទៅជាពិត ពីព្រោះក្នុងឆ្នាំទី ២៤ សករាជហ៊ីជ្រ៉េះត៍ អ៊ូម៉ារ ត្រូវ អាប៊ូ លុអ៊្លូអាស់ (أَبِي لُؤْلُؤَة) ឃាតករគាត់ ចាក់សម្លាប់ចំពោះបីកាំបិត ។

ចាប់ពីពេលនោះតរៀងមក ហ្វាដាក់នៅក្នុងកណ្តាប់ដៃអ្នកដឹកនាំបន្តបន្ទាប់គ្នារហូតមកដល់សម័យស្តេចខ៊លិហ្វត្រកូលអ៊ូម៉ៃយ៉ាស់ឈ្មោះ អ៊ូម៉ារ ប៊ិន អាប់ឌុល-អាស៊ីស (عمر بن عبد العزيز) ។ ស្តេចខ៊លិហ្វ អ៊ូម៉ារ ប៊ិន អាប់ឌុល-អាស៊ីស រូបនេះបាន

ប្រគល់ហ្វាដាក់ឲ្យទៅអ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام វិញ ។ តែស្ដេចខ្ញុំលិហ្វ បន្ទាប់បានរឹបអូសយកហ្វាដាក់វិញ ហើយបាននៅជាកម្មសិទ្ធិរបស់ពួកស្ដេចខ្ញុំលិហ្វ ត្រកូល បានី អ៊ូម៉ៃយ៉ាស់ ទាល់តែរជ្ជកាលត្រកូលនេះបានចប់ ។ ក្នុងរជ្ជកាលរបស់ ត្រកូល បានី អាប់បាស់ ហ្វាដាក់ត្រូវគេប្រគល់ឲ្យវិញមួយរយៈពេលខ្លី តែត្រូវគេរឹប អូសយកវិញរហូតមក ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ច្បាប់អ៊ីស្លាមចែងថាអ្វីអំពីដីធ្លីដែលវាយយកបានដោយកម្លាំង និងដោយវាយយកបានដោយមិនប្រើកម្លាំង ? ចូរលើកភ័ស្តុតាងនៅក្នុងគួរអាន ?

២. ហេតុអ្វីព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ បានប្រគល់ហ្វាដាក់ ឲ្យទៅព្រះនាងហ្វាទីម៉ាស្ស عليها سلام الله ?

៣. អ្នកណារឹបអូសយកហ្វាដាក់ពីព្រះនាងហ្វាទីម៉ាស្ស عليها سلام الله ? ហេតុអ្វី ?

៤. អាប៊ូ បាការ បានលើកយកសម្តីចចាមអារ៉ាមអ្វីអំពីព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ ? ព្រះនាងហ្វាទីម៉ាស្ស عليها سلام الله បានតបវិញថាអ្វី ?

៥. អ៊ុម៉ារ បានហែកចោលសារលិខិតបញ្ជាក់ថា ហ្វាដាក់ជាកម្មសិទ្ធិរបស់ព្រះនាងហ្វាទីម៉ាស្ស عليها سلام الله ដោយផ្អែកលើហេតុផលអ្វី ? ព្រះនាងហ្វាទីម៉ាស្ស عليها سلام الله មានប្រតិកម្មអ្វី ?

## មេរៀនទី ១៥

# អ៊ុមរ៉ោះត៏កន្លង

លក្ខខណ្ឌមួយក្នុងកិច្ចព្រមព្រៀងសន្តិភាពហ៊ូដៃប៊ីយ៉ាស្ទ័ចែងថា បក្សមុស្លីមត្រូវអនុញ្ញាតឲ្យមកកាន់ម៉ាក់កាស្ទ័ក្នុងឆ្នាំបន្ទាប់ ។ ពួកមុស្លីមអាចស្នាក់នៅឯម៉ាក់កាស្ទ័បីថ្ងៃដើម្បីបំពេញកាតព្វកិច្ចសាសនា ។

បន្ទាប់ពីមួយឆ្នាំបានកន្លងផុតទៅ ព្រះសាស្ដាមូហ៊ាំម៉ាដ្ទ័صلى الله عليه وآله وسلمបានប្រកាសឲ្យមុស្លីមត្រៀមខ្លួនធ្វើអ៊ុមរ៉ោះត៏ (عُمْرَة) គឺពិធីហាច្ចុ័តូច ។ សេចក្ដីប្រកាសបានទទួលស្វាគមន៍អំពីសំណាក់មុស្លីម ជាពិសេសពីសំណាក់មូហាជីរីនដែលពុំបានឃើញស្រុកកំណើតនិងគ្រួសារខ្លួនអស់រយៈពេល ៧ ប្រាំឆ្នាំហើយ ។ មុស្លីម ២០០០ នាក់រៀបចំខ្លួនចេញដំណើរ ។

ព្រះសាស្ដាមូហ៊ាំម៉ាដ្ទ័صلى الله عليه وآله وسلمគ្រងអ៊ិះហ្រ៉ាំម (إحرام) នៅក្នុងម៉ាស់ឃ្ជិដ្ទ មុស្លីមឯទៀតធ្វើតាមព្រះអង្គصلى الله عليه وآله وسلم ។ បន្ទាប់មក ក្រុមមុស្លីមបានចេញដំណើរទៅកាន់ម៉ាក់កាស្ទ័ដោយសូត្រតាល់ប៊ីយ៉ាស្ទ័ (اَلتَّلْبِيَة - لَبَّيْكَ اَللّٰهُمَّ لَبَّيْكَ - ឡាប់បៃក៏ អល់ឡ៉ហ៊ុំម៉ាឡាប់បៃក៏ - ទូលព្រះបង្គំមកហើយ អល់ឡោះហ្ទ័عز وجلអឺយ ទូលព្រះបង្គំមកហើយ) ។ ពួកគេនាំអូដ្ឋសម្រាប់ពលិការចំនួន ៨០ ក្បាល ។ គំហើញក្បួនទូរចរដែលធំសម្បើមនិងប្រកបដោយសេចក្ដីថ្លៃថ្នូរ បណ្ដាលឲ្យពួកធ្វើសក្ការៈរូបព្រះទន់ទេរចិត្តទៅរកអ៊ីស្លាម ។ លទ្ធផលចុងក្រោយគឺ ភាគច្រើនបានទៅជាមុស្លីម ។

លក្ខខណ្ឌមួយក្នុងកិច្ចព្រមព្រៀងសន្តិភាព តម្រូវឲ្យពួកមុស្លីមទម្លាក់អាវុធទាំងអស់លើកលែងតែដាវសម្រាប់អ្នកដំណើរ ពេលពួកគេចូលទៅក្នុងនគរម៉ាក់កាស្ទ័ ។ ព្រះសាស្ដាមូហ៊ាំម៉ាដ្ទ័صلى الله عليه وآله وسلمដឹងច្បាស់ថាប្រការនេះធ្វើឲ្យសំណាក់មុស្លីមនៅក្នុងស្ថានការណ៍ពិបាកការពារខ្លួនពេលត្រូវពួកគូរ៉យ់ស្ទ័វាយប្រហារ គឺពួកគូរ៉យ់ស្ទ័ដែលព្រះអង្គصلى الله عليه وآله وسلمមិនទុកចិត្តនោះ ។ ហេតុដូច្នេះឯងបានជាព្រះអង្គصلى الله عليه وآله وسلمបានចាត់ឲ្យកងកម្លាំងប្រដាប់អាវុធចំនួន ២០០ នាក់ទៅលាក់ខ្លួននៅឯច្រកមួយក្បែរម៉ាក់កាស្ទ័ រង់ចាំព្រះអង្គصلى الله عليه وآله وسلمមកដល់នៅទីនោះ ។

ពេលពួកគូរ៉យស្ទ៍បានទទួលដំណឹងសកម្មភាពនេះ របស់ព្រះសាស្តាមូហាំម៉ាដ្ទ ﷺ ពួកគេក៏ដឹងថាធ្វើផែនការណ៍វាយឆ្មក់ក្រុមមុស្លីមពុំមានប្រយោជន៍ទេ ។ ដូច្នេះ ពួកគេបានបើកទ្វារនគរម៉ាក់កាស្ទ ចាកចេញពីស្រុកទៅកាន់ភ្នំនិងច្រកភ្នំនៅក្បែរៗនោះ ។ ពួកគេអាចឃ្លាំមើលសកម្មភាពរបស់ពួកមុស្លីមបានពីទីនោះក្នុងអំឡុងពេលដែលពួកគេស្នាក់នៅ ៣ ថ្ងៃនោះ ។

ព្រះសាស្តាមូហាំម៉ាដ្ទ ﷺ បានចូលទៅក្នុងនគរម៉ាក់កាស្ទ អមដោយក្រុមមុស្លីម សម្លេង "ឡាប់បៃក៍" បានលាន់ឮរន្ទឺពេញស្រុក បណ្តាលឲ្យពួកអ្នកស្រុកម៉ាក់កាស្ទកោតក្រែងដោយសេចក្តីគោរព ។ ព្រះអង្គ ﷺ បានតាវ៉ាហ្វ (ឆ្វេល) ជុំវិញព្រះមហាគ្រឹះកាក់បាស្ទដោយជិះអូដ្ឋ ។

ដល់ដំណាក់ការនេះ ព្រះសាស្តាមូហាំម៉ាដ្ទ ﷺ បានបញ្ជាឲ្យក្រុមមុស្លីមចូលរួមជាមួយព្រះអង្គ ﷺ ដោយថា៖ "ពុំមានព្រះទេក្រៅពីអល់ឡោះហ្ទ៍ ﷻ ។ ព្រះអង្គ ﷻ ឯកឯង ពុំមានអ្វីប្រៀបផ្ទឹមបាន ។ ព្រះអង្គ ﷻ បានធ្វើតាមពាក្យសន្យា (អល់ឡោះហ្ទ៍ ﷻ បានសន្យាថាពួកមុស្លីមជិតបានទៅកាន់ព្រះមហាគ្រឹះកាក់បាស្ទ) ។ ព្រះអង្គ ﷻ បានជួយបាវបម្រើព្រះអង្គ ﷻ ។ ព្រះអង្គ ﷻ លើកស្ទួយកងទ័ពរបស់ព្រះឯកអង្គ ﷻ ដល់ថ្នាក់កំពូល ព្រះអង្គ ﷻ ដាក់ទោសកងទ័ពពួកធ្វើសក្ការៈរូបព្រះឲ្យនៅឯកោ ។"

ថ្ងៃនោះ មណ្ឌលធម្មយាត្រានិងកន្លែងបំពេញពិធីអ៊ុមរ៉ោះត៍ទាំងអស់ រាប់បញ្ចូលម៉ាស់យ៉ីឌុល-ហ្ការ៉ម ព្រះមហាគ្រឹះកាក់បាស្ទ និងភ្នំស្វ៍ហ្វានិងម៉ារវ៉ាស្ទ ត្រូវពួកមុស្លីមគ្រប់គ្រង ។

គំហើញបក្សមុស្លីមបំពេញបូជនីយពិធីនៅឯស្ថានទីនេះ បានជះឥទ្ធិពលដ៏ខ្លាំងទៅលើពួកមេដឹកនាំគូរ៉យស្ទ៍ ពេលនេះពួកគេជឿជាក់ថាពុំមានអ្វីអាចរារាំងសាសនានេះនិងមេសាសនានេះបានទេ ។

ដល់ម៉ោងស្វ៍ឡាត្ទ៍ពាក់កណ្តាលថ្ងៃ ។ ព្រះសាស្តាមូហាំម៉ាដ្ទ ﷺ ឲ្យប៊ីឡាល់សូត្រអាស្ហាន ។ ប៊ីឡាល់បានឡើងទៅលើដំបូលព្រះបូជនីយកាក់បាស្ទ ប្រកាសហៅធ្វើសក្ការៈដោយសម្លេងខ្លាំងៗ ។ រាល់ពាក្យពេជន៍ប្រៀបបាននឹងគ្រាប់ព្រួញបាញ់ទៅក្នុងបេះដូងពួកគូរ៉យស្ទ៍ ។ គូរ៉យស្ទ៍ម្នាក់គ្របមុខដោយកន្សែងដៃពេលឮប៊ីឡាល់សូត្រ ។ គាត់មិនអាចអត់ទ្រាំឮគេប្រកាសខ្លាំងៗបានទេថាអល់ឡោះហ្ទ៍ ﷻ ជាព្រះតែមួយគត់ មូហាំម៉ាដ្ទ ﷻ ជាព្រះសាសនៈទូតរបស់អល់ឡោះហ្ទ៍ ﷻ នោះ ទង្វើនេះ កាលពីមុន ត្រូវពួកគូរ៉យស្ទ៍ទមិឡឥតសាសនាធ្លាប់បានចាត់ទុកជាបទឧក្រិដ្ឋធំ

បំផុត ។

ក្រោយមកបន្តិច ព្រះសាស្តាមូហាំម៉ាដ់ﷺបាននាំក្រុមមុស្លីមបំពេញពីធីសាអ៊ី (السعي) រវាងភ្នំស្វហ្វានិងម៉ារវ៉ាស់ ។ ពួកមានពុតត្បុតនិងពួកធ្វើសក្ការៈរូបព្រះបានផ្សាយពាក្យចចាមអារ៉ាមថាក្រុមមុស្លីមអន់ខ្សោយកម្លាំង ដោយសារធាតុអាកាសមិនល្អនៅម៉ាឌីណាស់ ។ ដើម្បីសម្តែងឲ្យពួកគេឃើញផ្ទុយ ព្រះសាស្តាមូហាំម៉ាដ់ﷺបានធ្វើ "ហារ៉ាវ៉ាឡាស់ (هَرْوَلَة)" នៅក្នុងប៉ែកមួយនៃពិធីសាអ៊ី ពួកមុស្លីមក៏បានធ្វើតាមព្រះអង្គﷺ ។ ហារ៉ាវ៉ាឡាស់គឺការដើរលឿនស្រដៀងរត់ ។ បន្ទាប់មក ពួកមុស្លីមបានបូជាអូដ្ឋ បានចេញពីដំណាក់ការគ្រងអ៊ិះហ្រ៉ម ហើយបានកាត់សក់ ។ រួចហើយ ព្រះសាស្តាមូហាំម៉ាដ់ﷺបានឲ្យមុស្លីម ២០០ នាក់ទៅឯច្រកដែលយុទ្ធជនមុស្លីមបោះជំរំ ឲ្យផ្លាស់ពួកគេដើម្បីនឹងឲ្យពួកគេមកបំពេញពិធីអ៊ុមរ៉ោះត៏ម្តង ។

បែបបទនិងពិធីអ៊ុមរ៉ោះត៏ទាំងអស់បានចប់សព្វគ្រប់ ។ ពួកមូហាជីរីនបានទៅជួបសាច់ញាតិនិងគ្រួសារឯលំនៅខ្លួន ។ ពួកគេបានអញ្ជើញពួកអាន់ស្វារ៍ខ្លះមកលេងផ្ទះខ្លួនដែរដើម្បីតបស្នងពួកអាន់ស្វារ៍វិញ ដែលបានផ្តល់សំណាក់អាស្រ័យឲ្យខ្លួនកាលខ្លួនបានទៅដល់ម៉ាឌីណាស់ ។

លុះបានចប់បីថ្ងៃ ព្រះសាស្តាមូហាំម៉ាដ់ﷺបានឲ្យបក្សមុស្លីមចាកចេញពីម៉ាក់កាស់ទៅកាន់ម៉ាឌីណាស់ ។ មុននឹងចាកចេញ ព្រះអង្គصلوات الله عليه والسلامបានទទួលការស្នើសូមរៀបអាពាហ៍ពិពាហ៍ពីស្ត្រីគួរ៉យ៉ស្វម្នាក់ឈ្មោះ ម៉ៃមូណាស់ (مَيْمُونَة) អតីតបងថ្លៃស្រី (ឬប្អូនថ្លៃស្រី) របស់ អ៊ុប់បាស់ ឪពុកធំរបស់ព្រះសាស្តាមូហាំម៉ាដ់ﷺ ។ ព្រះអង្គﷺយល់ព្រម ហើយក៏បានអភិសេកជាមួយ ម៉ៃមូនណាស់ នៅម៉ាក់កាស់ ។

ទស្សនកិច្ចដ៏ខ្លីរបស់ក្រុមមុស្លីមនិងសេចក្តីល្បីខ្ទរខ្ទាយរបស់អ៊ីស្លាម បានជិតដាមជាប់ក្នុងអារម្មណ៍ពួកអ្នកស្រុកម៉ាក់កាស់ ។ ពួកគេភាគច្រើនចង់ដឹងក្រៃលជាងនេះណាស់អំពីសាសនានេះ ។ ទង្វើរបស់បក្សមុស្លីមទទួលបាននូវជ័យជំនះមួយដែលធំជាងជ័យជំនះក្នុងសង្គ្រាមណាមួយទៅទៀត ។

ព្រះមហាគម្ពីរគួរអាន (ស៊ូរ៉ោះត៏ អាល់-ហ្វាត់ហ្វ៍, 48:27) ចែងថា៖

لَّقَدْ صَدَقَ ٱللَّهُ رَسُولَهُ ٱلرُّءْيَا بِٱلْحَقِّ ۖ لَتَدْخُلُنَّ ٱلْمَسْجِدَ ٱلْحَرَامَ إِن شَآءَ ٱللَّهُ ءَامِنِينَ مُحَلِّقِينَ رُءُوسَكُمْ وَمُقَصِّرِينَ لَا تَخَافُونَ ۖ فَعَلِمَ مَا لَمْ تَعْلَمُوا۟ فَجَعَلَ مِن دُونِ ذَٰلِكَ فَتْحًا قَرِيبًا ﴿٢٧﴾

*27. ពិតណាស់ អល់ឡោះហ្ជ៍បានធ្វើឲ្យការមើលឃើញរបស់សានៈទូតព្រះអង្គទៅជាពិត ។ បើអល់ឡោះហ្វ៍មានព្រះបំណង ពួកអ្នកនឹងបានចូលទៅក្នុងបូជនីយវិហារ*

*ដោយសុវត្ថិភាព ដោយកោរក្បាលនិងដោយកាត់[សក់]ឲ្យខ្លី ពួកអ្នកនឹងមិនភ័យខ្លាចទេ ។ ព្រះអង្គទ្រង់ញាណអ្វីដែលពួកអ្នកមិនដឹង ។ ព្រះអង្គប្រទានឲ្យនូវជ័យជំនះជិតមួយមុននេះ ។*

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ក្រោយពីបានចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀងសន្តិសុខហ៊្វូដៃប៊ីយ៉ាស្ហ៊ តើព្រះសាស្តាមូហាំម៉ាដ្ហ៊ﷺបានរង់ចាំយូរប៉ុណ្ណាមុននឹងបានទៅម៉ាក់កាស្ហ៊ ដើម្បីធ្វើពិធីហាជ្ជ៉ ? ហេតុអ្វី ?

២. អ្វីទៅដែលហៅថា តាល់ប៊ីយ៉ាស្ហ៊ ? តាល់ប៊ីយ៉ាស្ហ៊មានន័យថាអ្វី គេសូត្រតាល់ប៊ីយ៉ាស្ហ៊ពេលណា ?

៣. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ្ហ៊ﷺបានដាក់កងទ័ពប្រដាប់អាវុធ ២០០ នាក់នៅក្បែរម៉ាក់កាស្ហ ?

៤. អ្វីទៅដែលហៅថា ហ្វារ៉ាទ្បាស្ហ៊ ? គេធ្វើហ្វារ៉ាទ្បាស្ហ៊ពេលណា ហេតុអ្វីគេធ្វើហ្វារ៉ាទ្បាស្ហ៊ ?

៥. បក្សមុស្លីមទទួលបានជ័យជំនះដូចម្តេច គឺជ័យជំនះដែលធំជាងក្នុងពេលធ្វើសង្គ្រាមផ្សេងៗនោះ ?

## មេរៀនទី ១៦

# សមរភូមិ មុតាស់

(غَزْوَةُ مُؤْتَةَ)

ក្នុងឆ្នាំទី ៨ សករាជហ៊ីជ្រោះត៍ ដែនដីអារ៉ាប៊ីស្ទើរតែទាំងអស់មានសន្តិសុខ ការប្រកាសសាសនាអ៊ីស្លាមបានលេចឮទៅដល់ទីកន្លែងច្រើន ។ ពួកយ៉ាហ៊ូឌីនៅខាងជើង ពួកគូរ៉យស្ទ៍នៅខាងត្បូង បានដកថយដោយសារបក្សមុស្លីមមានជ័យជំនះក្នុងសមរភូមិ ដូច្នេះក្រុមទាំងពីរនេះលែងជាគ្រោះថ្នាក់តទៅទៀត ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានចាត់បញ្ជូនបេសកជន ទៅអញ្ជើញប្រទេសជិតខាងឲ្យមកចូលអ៊ីស្លាម ។ បេសកជនខ្លះបានទទួលស្វាគមន៍ បេសកជនខ្លះទៀតត្រូវគេធ្វើបាប ឬត្រូវគេសម្លាប់ ។ ដូច្នេះ ប្រតិភូម្នាក់ឈ្មោះ ហារីស្ទ ប៊ិន អ៊ុម៉ៃរ៍ អាល់-អាស្ស៊ឌី (الحارث بن عمير الأزدي) ត្រូវចាត់បញ្ជូនជាមួយព្រះរាជសារមួយច្បាប់ទៅជួបអគ្គប្រមុខនៃប្រទេសស៊ីរី ។ តែមុនទៅដល់គោលដៅ លោកត្រូវ ស្ហ៊ូរ៉ោះហ៊្ប៊ីល (شُرَحبيل) អភិបាលភ្នាក់ងាររបស់អគ្គប្រមុខនៃប្រទេសស៊ីរី ចាប់ខ្លួននៅឯមុតាស់ស្រុកព្រំប្រទល់ ។ ល្មើសច្បាប់សាកលការពារសន្តិសុខបេសកជន ស្ហ៊ូរ៉ោះហ៊្ប៊ីល បានសម្លាប់ ហារីស្ទ ។ នៅក្នុងឧប្បត្តិហេតុមួយទៀត បេសកជន ១៥ នាក់ត្រូវចាត់បញ្ជូនទៅរកប្រជារាស្ត្រស៊ីរី ត្រូវសម្លាប់ដែរ ។

ពេលព្រះសាស្តាមូហាំម៉ាដ់ﷺបានទទួលដំណឹង មរណៈភាពដ៏អាណោចអាធ័ម ព្រះអង្គﷺឈឺចាប់អនេក ហើយបានសម្រេចធ្វើទណ្ឌកម្ម ស្ហ៊ូរ៉ោះហ៊្ប៊ីល និងបណ្តាអ្នកដែលជាឧបសគ្គប្រឆាំងការវាតសន្ធឹងរបស់អ៊ីស្លាម ។ ព្រះអង្គﷺបានប្រកាសយ៉ីហាដ់ មនុស្សចំនួន ៣០០០ នាក់បានប្រជុំគ្នានៅឯយ៉ូរហ្វ៍ ដំណាក់សឹកម៉ាឌីណាស់ ។ កងទ័ពបានទទួលបញ្ជាឲ្យទៅកាន់មុតាស់ ឲ្យចាប់ផ្តើមដោយស្នើឲ្យប្រជារាស្ត្រទៅជាមុស្លីម ។ បើពួកគេយល់ព្រម ឃាតកម្មរបស់ប្រតិភូនឹងមិនត្រូវសងសឹកទេ តែបើពួកគេប្រឆាំង ក្រុមមុស្លីមនឹងប្រយុទ្ធនឹងពួកគេក្នុងព្រះនាមអល់ឡោះហ៍ﷻ ។

យ៉ាក់ហ្វារ ប៊ិន អាប៊ូ ត៉លិប ត្រូវតែងតាំងជាមេបញ្ជាការទ័ព ព្រះសាសា

មូហ៊ាំម៉ាដ្ឋ ﷺ មានព្រះវចនៈថាបើ យ៉ាក់ហ្វារ ស្លាប់ ស៊ែដ្ឋ ប៊ិន ហារីស្សាស់ ជាអ្នកដឹកនាំពួកគេ ។ បើ ស៊ែដ្ឋ ស្លាប់ អាប់ឌុលឡោះហ៍ ប៊ិន រ៉ាវ៉ាហាស់ (عبد الله بن رواحة) ជាអ្នកកាន់បញ្ជាការ ។ បើលោកស្លាប់ដែរ ក្រុមមុស្លីមត្រូវជ្រើសរើសមេបញ្ជាការម្នាក់ក្នុងចំណោមពួកគេ ។ មុននឹងឲ្យពួកគេចេញទៅប្រយុទ្ធ ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ បានផ្តាំពួកគេឲ្យគោរពវិន័យដូចតទៅ គឺ៖

១. ចូរកុំជ្រៀតជ្រែកទៅក្នុងចំណោមពួកអ្នកបួសប្រុសស្រី នៅក្នុងវិហារពួកគេ ។

២. ចូរកុំវាយស្ត្រី ក្មេងៗនិងមនុស្សចាស់ ។

៣. ចូរកុំកាប់ដើមឈើនិងកុំបំផ្លិចបំផ្លាញសំណង់អគារ ។

បណ្តាំទាំងនេះឆ្លុះបញ្ចាំងឲ្យឃើញ ទស្សនៈរបស់ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ និងការខិតខំប្រឹងប្រែងរបស់ព្រះអង្គ ﷺ ដើម្បីធ្វើការផ្លាស់ប្តូរ និងកែតម្រង់គ្រប់វិស័យនៃជីវិតរស់នៅ ក្នុងសម័យដែលទ្វីបអារ៉ាប៊ីប្រព្រឹត្តដោយឥតនឹកក្រែងរអែង ជាពិសេសក្នុងសឹកសង្គ្រាម ។

ដើម្បីធ្វើប្រតិកម្មទល់នឹងដំណឹងចលនាទ័ពមុស្លីម ហេរ៉ៀគ្លូល ព្រះចៅអធិរាជរ៉ូមនិងប្រមុខរដ្ឋស៊ីរីបានចាត់បញ្ជូនកងពលខ្លាំងៗទៅកាន់ព្រំប្រទល់ ស្ហ៊ើរ៉ោះហ៍ប៊ីលប្រមូលបានរេហ៍ពល ១០០ ០០០ នាក់ ។ បក្សមុស្លីមមិនត្រឹមតែមានចំនួនតិចទេ ថែមទាំងត្រូវប្រយុទ្ធទល់នឹងកងទ័ពអាជីពទៀតផង ។ ដោយសារតែពួកគេធ្វើសង្គ្រាមជាប់ទល់នឹងអ៊ីរ៉ង់ ពួករ៉ូមបានក្លាយទៅជាអ្នកជំនាញខាងយុទ្ធសាស្ត្រនិងខាងស្ទៀតប្រយុទ្ធ ។ ពួកគេប្រដាប់អាវុធនិងមានយានជំនិះជឿនលឿនជាងក្រុមមុស្លីមដែរ ។ ម្យ៉ាងទៀត ពួករ៉ូមប្រយុទ្ធនៅក្នុងទឹកដីខ្លួន ចំណែកឯក្រុមមុស្លីមនៅក្នុងកន្លែងដែលខ្លួនមិនដែលស្គាល់ ។

ទោះបីពួកគេមានស្ថានភាពជំហរមិនសូវល្អក៏ដោយ តែក្រុមមុស្លីមសម្តែងឲ្យឃើញវីរៈភាពនៃសេចក្តីអង់អាចក្លាហាន ។ យ៉ាក់ហ្វារបានបែងចែករេហ៍ពលជា ៣ កងពល ទ័ពទាំងពីរបានជួបគ្នានៅឯស្ហារ៉ហ្ស ក្បែរមុតាស់ ។ សមរភូមិបានចាប់ផ្តើមដោយការប្រយុទ្ធសាមញ្ញ តែបានក្លាយទៅជាសង្គ្រាមធំយ៉ាងរហ័ស ។ ក្រុមមុស្លីមប្រយុទ្ធយ៉ាងក្លាហាន តែចំនួនច្រើនមានប្រៀបលើចំនួនតិចយ៉ាងឆាប់ៗ ។ យ៉ាក់ហ្វារ ត្រូវឡោមព័ទ្ធ បានដាច់ដៃម្ខាង ហើយម្ខាងទៀត ។ ទីបំផុត លោកបាន

ស្លាប់ដោយត្រូវគេវាយចំក្បាល ។ បន្ទាប់ពី យ៉ាក្កុំហ្វារ ស៊ៃដ្ធ៍ និង អាប់ឌុលឡោះហ្វ៍ ក៏បានបូជាជីវិតដែរ ។

នៅចុងក្រោយថ្ងៃដំបូង ទ័ពមុស្លីមច្របូកច្របល់ មានរបេហ៍ពលកាន់តែតិចចុះ ។ ក្រុមមុស្លីមបានជ្រើសរើស ខ៉ លីដ្ធ ប៊ិន វ៉ាលីដ្ធ ជាមេបញ្ជាការ ។

ពេលយប់ ខ៉ លីដ្ធ ឲ្យកងពលនៃទ័ពមុស្លីមដែលនៅសល់នោះប្តូរកន្លែងគ្នា ។ សម្លេងចលនាទៅមករបស់មនុស្សច្រើននាក់ ធ្វើឲ្យសត្រូវជឿជាក់ថាក្រុមមុស្លីមបានទទួលជំនួយ ។

ថ្ងៃបន្ទាប់ ខ៉ លីដ្ធ បានរៀបចំទ័ពមុស្លីមដើម្បីធ្វើឲ្យគេឃើញថាទ័ពថ្មីៗបានមកចូលរួមជាមួយពួកគេ ។ ល្បិចយុទ្ធសាស្ត្រនេះបានធ្វើឲ្យក្រុមសត្រូវស្ទាក់ស្ទើរ ខ៉ លីដ្ធ ឆ្លៀតយកឱកាសនេះដកទ័ពមុស្លីមថយ ហើយត្រឡប់ទៅម៉ាឌីណាស្ហ៍វិញ ។

អ្នកម៉ាឌីណាស្ហ៍ខ្លះយល់ឃើញថាការដកថយរបស់ក្រុមមុស្លីមមិនល្អទេ ថាពួកគេគួរតែប្រយុទ្ធលុះចប់ ។ តែ ដោយបានពិនិត្យកាលៈទេសៈ ខ៉ លីដ្ធបានប្រព្រឹត្តត្រឹមត្រូវដែលបាននាំទ័ពមកម៉ាឌីណាស្ហ៍វិញ ព្រោះវាជាការឥតប្រយោជន៍ដែលបូជាជីវិតពួកមុស្លីមលើសពីនេះ ។

ព្រះសាស្តាមូហាំម៉ាដ្ធ៍صلى الله عليه وآله وسلمឈឺចាប់ណាស់ ដោយសារការបាត់បង់ជីវិតរបស់ពួកមុស្លីម ជាពិសេសដោយសារការស្លាប់របស់ យ៉ាក្កុំហ្វារ បងប្អូនជីតាមួយរបស់ព្រះអង្គصلى الله عليه وآله وسلم ។ ព្រះអង្គصلى الله عليه وآله وسلمបានយល់សប្តិឃើញយ៉ាក្កុំហ្វារមានស្លាបពីរដូចទេវតានៅក្នុងឋានសួគ៌ ចាប់ពីកាលនោះមកគេហៅយ៉ាក្កុំហ្វារថា តួយ៉យ៉ារ (الطيار) មានន័យថា បុរសហោះ ។

មុនសោយទិវង្គត ព្រះសាស្តាមូហាំម៉ាដ្ធ៍صلى الله عليه وآله وسلمបានរៀបចំទ័ពដ៏ខ្លាំង ក្រោមបញ្ជាការរបស់ អ៊ូសាម៉ាស្ហ៍ ប៊ិន ស៊ៃដ្ធ៍ (أُسَامَةَ بْنَ زَيْدٍ) ដើម្បីត្រឡប់ទៅមុតាស្ហ៍វិញ ។ តែសមរភូមិនេះមិនបានប្រព្រឹត្តឡើងទេ ដោយសារព្រះសាស្តាមូហាំម៉ាដ្ធ៍صلى الله عليه وآله وسلمមានជម្ងឺ ។ ទោះបី អ៊ូសាម៉ាស្ហ៍ ត្រៀមខ្លួនចេញទៅប្រយុទ្ធស្រេចបាច់ហើយក៏ដោយ តែមុស្លីមខ្លះ ជាពិសេស អាប៊ូ បាការ និង អ៊ុម៉ារ បារម្ភខ្លាចមិនបាននៅឯម៉ាឌីណាស្ហ៍ពេលព្រះសាស្តាមូហាំម៉ាដ្ធ៍صلى الله عليه وآله وسلمសោយទិវង្គត ។ គាត់ទាំងពីរចង់នៅម៉ាឌីណាស្ហ៍ដើម្បីរារាំងអ៊ីម៉ាំអាលីصلوات الله عليه والسلامកុំឲ្យទៅជាអ្នកស្នងព្រះសាស្តាមូហាំម៉ាដ្ធ៍صلى الله عليه وآله وسلم និងដើម្បីចុះដៃធ្វើផែនការខ្លួន ។ តែពីរឆ្នាំក្រោយមក ទ័ពដ៏ខ្លាំងមួយបានវិលត្រឡប់ទៅស៊ីរីវិញ ហើយបានវាយឈ្នះពួករ៉ូមក្នុងសមរភូមិ យ៉ារមុក (مَعْرَكَة اليرموك) បណ្តាលឲ្យ

ទឹកដីស៊ីរីមួយប៉ែកធំចូលអ៊ីស្លាម ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីសមរភូមិមុតាស់បានកើតឡើង ?

២. ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺបានផ្តាំថាអ្វីខ្លះ ? បណ្តាទាំងនេះសឲ្យឃើញអ្វីអំពីទស្សនៈរបស់ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺ ?

៣. អ្នកណាត្រូវតែងតាំងជាមេបញ្ជាការ អ្នកនោះមានទំនាក់ទំនងអ្វីជាមួយព្រះសាស្តាមូហ៊ាំម៉ាដ់ﷺ ?

៤. អ្វីបានកើតឡើងចំពោះមេបញ្ជាការទីមួយរបស់ទ័ព ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺបានយល់សប្តិឃើញអ្វីពាក់ព័ន្ធនឹងមេបញ្ជាការទីមួយនេះ ?

៥. ខ៉ូលីដ្ធបានប្រើល្បិចយុទ្ធសាស្ត្រអ្វី លោកធ្វើត្រូវទេដែលបានប្រើល្បិចយុទ្ធសាស្ត្របែបនេះ ?

## មេរៀនទី ១៧

# សមរភូមិ ស៊ាត់ អាល់-សាឡាស៊ីល

(معركة ذات السلاسل)

ចាប់តាំងពីព្រះសាស្ដាមូហាំម៉ាដ់ﷺបានចូលទៅក្នុងនគរម៉ាឌីណាស់ បានធ្វើឲ្យម៉ាឌីណាស់ក្លាយទៅជារដ្ឋធានីរបស់មុស្លីម ព្រះអង្គﷺបានចាត់ចែងនិងរៀបចំឲ្យមានបណ្ដាញអ្នកស៊ើបអង្កេតការណ៍និងអ្នកឃ្លាំមើល ពេញដែនដីអារ៉ាប៊ី ។ បុគ្គលទាំងនេះរាយការណ៍ប្រាប់ព្រះអង្គﷺអំពីផែនការណ៍របស់សត្រូវ ដូច្នេះព្រះអង្គﷺអាចចាត់វិធានការទប់ទល់បានជាមុន ។ ក្នុងសមរភូមិអ៊ូហ៊ូដនិងសមរភូមិអាស៊ុស៊ាប់ អ្នកស៊ើបអង្កេតការណ៍ទាំងនេះសំខាន់ណាស់សម្រាប់ព្រះសាស្ដាមូហាំម៉ាដ់ﷺ ។

ឆ្នាំទី ៨ សករាជហ៊ិជរ៉ះត៍ បណ្ដាញស៊ើបការណ៍របស់ព្រះសាស្ដាមូហាំម៉ាដ់ﷺបានរាយការណ៍ប្រាប់ព្រះអង្គﷺ ថាមានមនុស្សរាប់ពាន់នាក់ប្រជុំគ្នានៅច្រកភ្នំយ៉ាប៊ីសដើម្បីចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀងគ្នាទាំងសងខាង ក្នុងបំណងធ្វើការវាយលុកយ៉ាងធំទៅលើនគរម៉ាឌីណាស់ ។ ពួកគេបានប្ដេជ្ញាចិត្តលះបង់ជីវិតដើម្បីបំផ្លាញអ៊ីស្លាម គោលដៅចម្បងរបស់ពួកគេគឺសម្លាប់ព្រះសាស្ដាមូហាំម៉ាដ់ﷺឬអ៊ីម៉ាំអ៊ាលីصلوات الله عليه والسلام សេនាក្លាហានរបស់ព្រះអង្គﷺ ។

ពេលបានទទួលដំណឹង ព្រះសាស្ដាមូហាំម៉ាដ់ﷺបានប្រជុំមុស្លីមនៅឯម៉ាស់ឃ៊ិដ ប្រាប់ពួកគេឲ្យជ្រាបអំពីគ្រោះថ្នាក់ ។ មនុស្សមួយក្រុមត្រូវចាត់ឲ្យទប់ទល់គ្រោះថ្នាក់ អាប៊ូ បាការ ត្រូវតែងតាំងជាមេបញ្ជាការ ។ កងពលតូចនេះបានចាកចេញពីម៉ាឌីណាស់ទៅកាន់យ៉ាប៊ីស ។ លុះបានទៅដល់ច្រកថ្មភ្នំយ៉ាប៊ីស ពួកប្រជាជាតិ បានី សាលីម មួយក្រុមបានឃាត់ផ្លូវ ។

ពួកមេដឹកនាំប្រជាជាតិនេះសួរ អាប៊ូ បាការ ថា៖ "ការប្រយុទ្ធនេះមានគោលបំណងអ្វី ?" អាប៊ូ បាការ តបថា៖ "ព្រះសាស្ដារបស់អល់ឡោះហ៍عزّ وجلّបានចាត់ខ្ញុំឲ្យមកស្នើឲ្យអស់លោកចូលអ៊ីស្លាម និងឲ្យប្រយុទ្ធនឹងអស់លោកបើអស់លោកបដិសេធ ។"

ពេលនោះ ពួកមេដឹកនាំប្រជាជាតិនេះបានបង្ហាញឲ្យឃើញទ័ពរបស់ពួកគេដ៏សម្បើមដែលមានរេហ៍ពលច្រើន ។ គំហើញទ័ពនេះបានធ្វើឲ្យ អាប៊ូ បាការ ខ្លបខ្លាច បាត់បង់សេចក្តីក្លាហាន ។ គាត់បានបញ្ជាឲ្យពួកមុស្លីមដកថយទៅម៉ាឌីណាស្ងំវិញទោះបីពួកគេត្រៀមខ្លួនប្រយុទ្ធស្រេចហើយក៏ដោយ ។

ការវិលត្រឡប់មកវិញរបស់ទ័ព បានធ្វើឲ្យព្រះសាស្តាមូហាំម៉ាដ្ទﷺស្រងាកចិត្ត ។ លើកនេះព្រះអង្គﷺបានប្រគល់ទ័ពឲ្យទៅ អ៊ូម៉ារ ដឹកនាំ ។

លើកនេះពួកសត្រូវប្រុងប្រយ័តខ្លួនស្រេច ពួកគេពួននៅពីក្រោយថ្មភ្នំនិងដើមឈើនៅមាត់ផ្លូវចូលទៅក្នុងច្រកភ្នំ ។ ពេលក្រុមមុស្លីមមកដល់ ពួកសត្រូវបានចេញមកស្ទាក់ផ្លូវ អ៊ូម៉ារ បានបញ្ជាឲ្យដកថយ ។

អាំរ៉ូ អាល់-អាស្វ (عَمْرُو بْنُ الْعَاصِ) អ្នកឈ្លាសវៃខាងនយោបាយដែលទើបតែនឹងបានចូលសាសនាអ៊ីស្លាម បានមកជួបព្រះសាស្តាមូហាំម៉ាដ្ទﷺ ទូលព្រះអង្គﷺថា៖ "សង្គ្រាមគឺការបញ្ឆោត ។" គាត់ចង់និយាយថាជ័យជំនះក្នុងសង្គ្រាមមិននៅលើកម្លាំងនិងសេចក្តីក្លាហានតែម្យ៉ាងទេ តែអាចមានជ័យជំនះបានដោយមានផែនការណ៍ប៉ិនប្រសប់និងដោយបោកបញ្ឆោតសត្រូវ ។ គាត់បាននិយាយបន្ថែមទៀតថា៖ "បើព្រះអង្គﷺទុកឲ្យទូលបង្គំដឹកនាំយុទ្ធជន ទូលបង្គំនឹងនាំពួកគេទៅរកជ័យជំនះ ។"

ព្រះសាស្តាមូហាំម៉ាដ្ទﷺព្រមទទួលសំណូមពររបស់ អាំរ៉ូ ។ ទោះបី អាំរ៉ូ មានសេចក្តីជឿជាក់ខ្លាំងក៏ដោយ គាត់ក៏ពុំបានជោគជ័យជាងមេបញ្ជាការមុនៗពីរនាក់នោះទេដែរ ។

បរាជ័យជាបន្តបន្ទាប់ធ្វើឲ្យក្រុមមុស្លីមបាក់ទឹកចិត្ត ។ លើកនេះ ព្រះសាស្តាមូហាំម៉ាដ្ទﷺបានរៀបចំទ័ពថ្មីមួយតែលើកនេះដឹកនាំដោយអ៊ីម៉ាំអាលីصلوات الله عليه والسلام ព្រមទាំងប្រគល់ទង់សង្គ្រាមឲ្យព្រះអង្គصلوات الله عليه والسلامកាន់ ។ អ៊ីម៉ាំអាលីصلوات الله عليه والسلامបានចេញដំណើរ នាំមុខក្រុមមុស្លីម ដោយកាន់លំពែង ។ ពេលព្រះអង្គﷺមើលអ៊ីម៉ាំអាលីصلوات الله عليه والسلامជិះសេះចាកចេញទៅឆ្ងាយ ព្រះសាស្តាមូហាំម៉ាដ្ទﷺមានព្រះវចនៈថា៖ "គេصلوات الله عليه والسلامជាវរសេនីយ៍មិនរួញរាប្រយុទ្ធ មិនរត់ចោលលានប្រយុទ្ធជាដាច់ខាត ។"

ពាក្យពេជន៍នេះសឲ្យឃើញនូវគំនិតរបស់ព្រះសាស្តាមូហាំម៉ាដ្ទﷺ អំពីពួកមេបញ្ជាការទាបថោកអាម៉ាស់មុខមុនៗ ។

អ៊ីម៉ាំអាលីصلوات الله عليه والسلامបានទៅកាន់យ៉ាប៊ីសតាមផ្លូវផ្សេងពីផ្លូវមុនៗ ដើម្បីនឹងកុំឲ្យ

ពួក បានី សាលិម ឃើញ ។ ព្រះអង្គصلوات الله عليه والسلامធ្វើដំណើរពេលយប់ ឲ្យបក្សពួកព្រះអង្គصلوات الله عليه والسلامលាក់ខ្លួនពេលថ្ងៃ ។ ពេលជិតដល់ច្រកភ្នំយ៉ាប៊ីស ព្រះអង្គصلوات الله عليه والسلامឲ្យបក្សពួកសម្រាកយកកម្លាំង ។

ថ្ងៃបន្ទាប់ បន្ទាប់ពីបានស្វ៊ូឡាត់ពេលព្រឹករួច ព្រះអង្គصلوات الله عليه والسلامនាំបក្សពួកទៅលើភ្នំពីក្រោយច្រកភ្នំ ។ ពីទីនោះ ទ័ពបានចុះទៅក្នុងច្រកភ្នំ ។

មានទំនុកចិត្តដោយសារវត្តមានអ៊ីម៉ាំអាលីصلوات الله عليه والسلام ក្រុមមុស្លីមសម្រុកចូលដូចទឹកជំនោរដ៏ធំ ។ ពួកគេប្រាកដខ្លួនចំពោះសត្រូវដោយមិនឲ្យដឹងខ្លួន បណ្ដាលឲ្យពួកវាជ្រួលច្របល់ ។ មុនបច្ចាមិត្តត្រៀមខ្លួនទាន់ ពួកវាត្រូវអ៊ីម៉ាំអាលីصلوات الله عليه والسلامវាយប្រហារដូចព្យុះ ព្រះអង្គصلوات الله عليه والسلامវាយសង្គ្រុបពួកវាដោយសម្លាប់អស់ប្រាំពីរនាក់យ៉ាងទាន់ហន់ ។ ច្រើននាក់ទៀតត្រូវសម្លាប់ ខ្លះទៀតរត់ប្រាសអាយុ បោះបង់ចោលរបស់របរច្រើន ។

វរសេនីយ៍ក្លាហាននិងវិជយសង្គ្រាមصلوات الله عليه والسلامបានត្រឡប់មកម៉ាឌីណាស្ញវិញ ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋصلى الله عليه وآله وسلمបានចេញមកទទួលព្រះអង្គصلوات الله عليه والسلام ។

ពេលឃើញព្រះសាស្ដាមូហ៊ាំម៉ាដ្ឋصلى الله عليه وآله وسلم អ៊ីម៉ាំអាលីصلوات الله عليه والسلامគោរពព្រះអង្គصلى الله عليه وآله وسلمដោយចុះពីលើសេះភ្លាម ។ ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋصلى الله عليه وآله وسلمទះខ្នងអ៊ីម៉ាំអាលីصلوات الله عليه والسلام ហើយប្រាប់ព្រះអង្គصلوات الله عليه والسلامថា៖ "អាលីصلوات الله عليه والسلامអើយ ចូរអ្នកصلوات الله عليه والسلامឡើងជិះសេះ អល់ឡោះហ៍عز وجلនិងព្រះសាស្ដាព្រះអង្គعز وجلសព្វព្រះហឫទ័យអ្នកصلوات الله عليه والسلام ។"

ពេលនោះ ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋصلى الله عليه وآله وسلمបានថ្លែងពាក្យពេជន៍មួយឃ្លាដ៏ល្បីល្បាញថា៖ "អាលីصلوات الله عليه والسلامអើយ បើខ្ញុំصلى الله عليه وآله وسلمមិនខ្លាចបណ្ដាអ្នកតាមខ្ញុំصلى الله عليه وآله وسلمនិយាយអំពីអ្នកصلوات الله عليه والسلامដូចពួកគ្រិស្ដសាសនិកនិយាយអំពីព្រះសាស្ដាអ៊ីសាعَلَيْهِ السَّلَامُនោះទេ ខ្ញុំصلى الله عليه وآله وسلمប្រាកដជានឹងនិយាយអំពីអ្នកصلوات الله عليه والسلامនូវរឿងមួយ ដែលនឹងធ្វើឲ្យមនុស្សម្នាកើបដីក្រោមជើងអ្នកصلوات الله عليه والسلامទុកជាវត្ថុសក្ដិសិទ្ធិប្រកបដោយពរជ័យសិរីសួស្ដី ។"

សេចក្ដីក្លាហាននិងទង្វើរបស់អ៊ីម៉ាំអាលីصلوات الله عليه والسلامអស្ចារ្យពេកណាស់ បានជាអល់ឡោះហ៍عز وجلបើកឲ្យដឹងស៊ូរ៉ោះត៏ អាល់-អាឌីយ៉ាត់ ដែលថែងអំពីព្រឹត្តិការណ៍នោះ ។ ស៊ូរ៉ោះត៏នេះមាននូវសម្បថគួរឲ្យរំភើបនិងប្រកបដោយឥទ្ធិពល ជាការកោតសរសើរស្មារតីសឹករបស់យុទ្ធជនដែលបានចូលរួមក្នុងសមរភូមិ ។ ព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត៏ អាល់-អាឌីយ៉ាត់, 100:1-5) ថែងថា៖

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

وَٱلۡعَٰدِيَٰتِ ضَبۡحٗا ١ فَٱلۡمُورِيَٰتِ قَدۡحٗا ٢ فَٱلۡمُغِيرَٰتِ صُبۡحٗا ٣ فَأَثَرۡنَ بِهِۦ نَقۡعٗا ٤ فَوَسَطۡنَ بِهِۦ جَمۡعًا ٥

*ដោយនូវព្រះនាមអល់ឡោះហ្ទ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*1. [អញស្បថស្បថ]នឹងអាជានេយ្យដង្ហក់ 2. ដែលធ្វើឲ្យបែកផ្កាភ្លើងព្រោងព្រាត 3. ដែលផ្អក់ចូលលុកនាពេលព្រលឹម 4. ដែលធ្វើឲ្យធូលីហុយទ្រលោម 5. ដែលសម្រុកចូលទៅក្នុងប្រជុំជន ។*

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ព្រះសាស្តាមូហាំម៉ាដ់ﷺអាចដឹងថា គេប្រជុំគ្នានៅឯច្រកយ៉ាប៊ីសបានដូចម្តេច ? ការប្រជុំគ្នានោះមានគោលដៅអ្វី ?

២. អ្នកណាត្រូវព្រះសាស្តាមូហាំម៉ាដ់ﷺតែងតាំង ជាមេបញ្ជាការមុនគេ បន្ទាប់មកជាមេបញ្ជាការទីពីរ ហើយបានលទ្ធអ្វី ?

៣. អ្នកណាថាៈ "សង្គ្រាមគឺការបញ្ឆោត" ? តើគាត់ចង់ថាអ្វី ? តើមានអ្វីកើតឡើងចំពោះគាត់ ?

៤. តើព្រះសាស្តាមូហាំម៉ាដ់ﷺផ្តោតទៅលើអ្នកណា កាលព្រះអង្គﷺមានព្រះវចនៈថាៈ "គេ صلوات الله عليه والسلام ជាវរសេនីយ៍មិនរួញរាប្រយុទ្ធ មិនរត់ចោលលានប្រយុទ្ធជាដាច់ខាត ។" មួយឃ្លានេះចង់បង្ហាញអ្វីពាក់ព័ន្ធនឹងមេបញ្ជាការមុនៗ ?

៥. អ៊ីមុាំអាលី صلوات الله عليه والسلام បានប្រើយុទ្ធសាស្ត្រអ្វី ? តើយុទ្ធសាស្ត្រនេះមានប្រសិទ្ធភាពយ៉ាងណា ? ព្រះសាស្តាមូហាំម៉ាដ់ﷺមានប្រតិកម្មអ្វី ?

## មេរៀនទី ១៨

# ព្រះសាស្តា សាការីយ៉ា﵇ និងព្រះសាស្តា យ៉ាស៊ុយ៉ា﵇

ព្រះសាស្តាសាការីយ៉ា﵇ត្រូវអល់ឡោះហ៍្វ﷿ចាត់បញ្ជូន ទៅរកប្រជាជាតិបានី អ៊ីសរ៉អ៊ីល ។ ព្រះអង្គ﵇ជាកូនចៅរបស់ព្រះសាស្តាយ៉ាក់គូប﵇ ។ ប្រជារាស្ត្រព្រះអង្គ﵇ស្រឡាញ់និងគោរពព្រះអង្គ﵇ ព្រោះព្រះអង្គ﵇មានចរិយាមារយាទល្អប្រពៃ ។ ព្រះអង្គ﵇ទទួលបន្ទុកមើលថែរក្សាម៉ាស់យ៉ីដ្ បៃទុល-ម៉ាក់ឌីស (بَيْتُ الْمَقْدِسِ) នៅយេរូសាឡេម ព្រះអង្គ﵇ផ្សាយព្រះសាសនារបស់អល់ឡោះហ៍្វ﷿នៅទីនេះ ។ ព្រះអង្គ﵇ណែនាំមនុស្សតាមច្បាប់ដែលចារនៅក្នុងព្រះគម្ពីរតៅរ៉ត្តរបស់ព្រះសាស្តាមូសា﵇ ព្រះសាសនៈទូតចុងក្រោយ (ព្រះសាស្តាដែលអល់ឡោះហ៍្វ﷿បានព្រះរាជទានឲ្យនូវព្រះគម្ពីរ) មុនព្រះអង្គ﵇ ។

ព្រះសាស្តាសាការីយ៉ា﵇មានបន្ទុកមើលថែរក្សាព្រះនាងមារីយ៉ាំ(سلام الله عليها) ព្រះមាតារបស់ព្រះសាស្តាអ៊ីសា﵇ដែរ ។ ព្រះអង្គ﵇បានរៀបចំបន្ទប់ពិសេសមួយសម្រាប់ព្រះនាង(سلام الله عليها)នៅឯបៃតុល-ម៉ាក់ឌីស ។ ទោះបីព្រះនាងម៉ារីយ៉ាំ(سلام الله عليها)មិនចាកចេញពីក្នុងបន្ទប់ រវល់តែធ្វើសក្ការៈអល់ឡោះហ៍្វ﷿ក៏ដោយ ព្រះសាស្តាសាការីយ៉ា﵇ឃើញព្រះនាង(سلام الله عليها)មានផ្លែឈើស្រស់ៗជានិច្ចនៅក្នុងបន្ទប់ ។ ព្រោះតែដឹងថាព្រះនាង(سلام الله عليها)មិនមានទំនាក់ទំនងជាមួយអ្នកណាទេ បានជាព្រះអង្គ﵇ឆ្ងល់ថាតើចំណីទាំងនោះមកពីណា ។ ព្រះនាងម៉ារីយ៉ាំ(سلام الله عليها)បានប្រាប់ព្រះអង្គ﵇ថាអល់ឡោះហ៍្វ﷿បញ្ជូនផ្លែឈើទាំងនេះមកឲ្យព្រះនាង(سلام الله عليها)រាល់ព្រឹកនិងរាល់ល្ងាច ជាសញ្ញានៃព្រះគុណូបការៈរបស់ព្រះអង្គ﷿ ។ ដូច្នេះ ព្រះសាស្តាសាការីយ៉ា﵇ដឹងថាព្រះអង្គ﵇ជាអ្នកថែរក្សាមហានារីវិសេសវិសាល ដែលអល់ឡោះហ៍្វ﷿លើកតម្កើងជាពិសេស ។

ព្រះសាស្តាសាការីយា﵇មានព្រះជន្ម ៩០ ឆ្នាំ ទោះបីព្រះអង្គ﵇ជាមនុស្សរីករាយនិងមិនតឹងតែងក៏ដោយ តែព្រះអង្គ﵇ពិបាកចិត្តព្រោះព្រះអង្គ﵇មិនមានកូនជាអ្នកស្នងព្រះអង្គ﵇ ។ បន្ទាប់ពីបានឮសម្តីព្រះនាងម៉ារីយ៉ាំ(سلام الله عليها) ព្រះអង្គ﵇គិតដល់ព្រះគុណឥតព្រំដែន ដែលអល់ឡោះហ៍្វ﷿ប្រទានឲ្យបាវបម្រើព្រះអង្គ

ﷻ ព្រះអង្គﷺគិតថាតើអាចមានកូនបានឬទេថ្វីបើព្រះអង្គﷺចាស់ហើយនោះ ។ យប់នោះ ព្រះអង្គﷺបានទៅធ្វើសក្ការៈនៅក្រោមខ្លោងទ្វារព្រះមហាគ្រឹះ នៅក្នុងបៃទុល-ម៉ាក់ឌីស កន្លែងពិសេសសម្រាប់បួងសួងអល់ឡោះហ៍ﷻ ។ ការបួងសួងរបស់ព្រះអង្គﷺមានចែងនៅក្នុងព្រះគម្ពីរគួរអាន ក្នុងស៊ូរ៉ោះត៍ ម៉ារយ៉ាំ, 19:2-6 ថា៖

ذِكۡرُ رَحۡمَتِ رَبِّكَ عَبۡدَهُۥ زَكَرِيَّآ ۝٢ إِذۡ نَادَىٰ رَبَّهُۥ نِدَآءً خَفِيّٗا ۝٣ قَالَ رَبِّ إِنِّي وَهَنَ ٱلۡعَظۡمُ مِنِّي وَٱشۡتَعَلَ ٱلرَّأۡسُ شَيۡبٗا وَلَمۡ أَكُنۢ بِدُعَآئِكَ رَبِّ شَقِيّٗا ۝٤ وَإِنِّي خِفۡتُ ٱلۡمَوَٰلِيَ مِن وَرَآءِي وَكَانَتِ ٱمۡرَأَتِي عَاقِرٗا فَهَبۡ لِي مِن لَّدُنكَ وَلِيّٗا ۝٥ يَرِثُنِي وَيَرِثُ مِنۡ ءَالِ يَعۡقُوبَۖ وَٱجۡعَلۡهُ رَبِّ رَضِيّٗا ۝٦

*2. [នេះគឺ]ការថ្លែងអំពីព្រះមេត្តាធម៌របស់ព្រះម្ចាស់អ្នក [ដែលព្រះអង្គព្រះរាជទាន] មកលើបាវរបស់ព្រះអង្គ ស្សាការីយ៉ា ។ 3. កាលគេបានបួងសួងព្រះម្ចាស់គេដោយការបួងសួងសម្ងាត់[និងស្មោះអស់ពីចិត្ត] ។ 4. គេបានទូលថា៖ "ព្រះម្ចាស់អើយ ឆ្អឹងឆ្អែងទូលព្រះបង្គំជាខ្ញុំទន់ខ្សោយទៅហើយ (កម្លាំងទូលព្រះបង្គំជាខ្ញុំអន់ថយ) ក្បាលទូលព្រះបង្គំជាខ្ញុំក៏សក្បុស (សក់ទូលព្រះបង្គំជាខ្ញុំស្កូវអស់ហើយ) ។ ព្រះម្ចាស់អើយ ទូលព្រះបង្គំជាខ្ញុំមិនដែលខុសបំណងម្តងណាឡើយ ពេលទូលព្រះបង្គំជាខ្ញុំបន់ស្រន់ព្រះអង្គ ។ 5. ទូលព្រះបង្គំជាខ្ញុំព្រួយបារម្ភអំពីអ្នកស្នងទូលព្រះបង្គំជាខ្ញុំ អត់ពីទូលព្រះបង្គំជាខ្ញុំទៅ ។ រីឯភរិយាទូលព្រះបង្គំជាខ្ញុំក៏ជាស្ត្រីអារ ។ ដូច្នេះសូមព្រះអង្គព្រះមេត្តាព្រះរាជទានអ្នកស្នងឲ្យទូលព្រះបង្គំជាខ្ញុំ ក្នុងព្រះនាមព្រះអង្គផង 6. ដែលនឹងទទួលកេរដំណែលពីទូលព្រះបង្គំជាខ្ញុំ និងទទួលកេរដំណែលពីពូជពង្សរបស់យ៉ាក់គូប សូមព្រះអង្គឲ្យគេទៅជាបុគ្គលដែលសក្តិសម[នឹងព្រះហឫទ័យព្រះអង្គ] ឱព្រះម្ចាស់អើយ ។"*

នៅក្នុងស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ន, 3:38-39 ថា៖

هُنَالِكَ دَعَا زَكَرِيَّا رَبَّهُۥۖ قَالَ رَبِّ هَبۡ لِي مِن لَّدُنكَ ذُرِّيَّةٗ طَيِّبَةًۖ إِنَّكَ سَمِيعُ ٱلدُّعَآءِ ۝٣٨ فَنَادَتۡهُ ٱلۡمَلَٰٓئِكَةُ وَهُوَ قَآئِمٞ يُصَلِّي فِي ٱلۡمِحۡرَابِ أَنَّ ٱللَّهَ يُبَشِّرُكَ بِيَحۡيَىٰ مُصَدِّقَۢا بِكَلِمَةٖ مِّنَ ٱللَّهِ وَسَيِّدٗا وَحَصُورٗا وَنَبِيّٗا مِّنَ ٱلصَّٰلِحِينَ ۝٣٩

*38. កាលនោះស្សាការីយ៉ាបានបួងសួងព្រះម្ចាស់គេដោយទូលថា៖ "ព្រះម្ចាស់អើយ សូមព្រះមេត្តាព្រះរាជទាន មកពីព្រះអង្គ ឲ្យទូលព្រះបង្គំជាខ្ញុំនូវបណ្ដាកូនចៅល្អ ។*

*ព្រះអង្គទ្រង់សវនាការការបួងសួង ។" 39. បណ្តាទេវតាបានហៅគេ ខណៈដែលគេកំពុងឈរបំពេញនមស្ការ[បូជាអល់ឡោះហ្ទ៍]នាទីសក្ការៈពិសិដ្ឋ ថា៖ "អល់ឡោះហ្ទ៍ប្រាប់ដំណឹង[ល្អអំពីការចាប់កំណើតរបស់]យ៉ាស្ហ៊យ៉ាដល់អ្នក គេជាអ្នកអះអាងបញ្ជាក់ព្រះបន្ទូលអល់ឡោះហ្ទ៍ គេនឹងទៅជាអ្នកដឹកនាំថ្លៃថ្នូរ ជាបុរសបរិសុទ្ធ ជាព្រះសាស្តាម្នាក់ក្នុងចំណោមជនដែលប្រកបដោយព្រហ្មចរិយធម៌ (គឺអ្នកប្រព្រឹត្តិធម៌ដ៏ប្រសើរ) ។"*

ពាក្យបួងសួងរបស់ព្រះសាស្តាស្ហាការីយ៉ា ﷺ បានសម្រេចដូចបំណង ព្រះអង្គ ﷺ បានកូនប្រុសស្អាតនិងប្រកបដោយសីលធម៌ម្នាក់ឈ្មោះ យ៉ាស្ហ៊យ៉ា ﷺ ។ អល់ឡោះហ្ទ៍ ﷻ បានឲ្យកូនប្រុសនេះមានប្រាជ្ញាញាណនិងអភិញ្ញា ហើយបានតែងតាំងព្រះអង្គ ﷺ ជាព្រះសាស្តានិងជាព្រះសាសនៈទូតរបស់អល់ឡោះហ្ទ៍ ﷻ ។

តាំងពីក្មេងវ័យមកម្ល៉េះ ព្រះសាស្តាយ៉ាស្ហ៊យ៉ា ﷺ ស្រឡាញ់និងធ្វើសក្ការៈអល់ឡោះហ្ទ៍ ﷻ ។ ព្រះគម្ពីរគួរអានចែងអំពីគុណសម្បត្តិព្រះអង្គ ﷺ ថា ព្រះអង្គ ﷺ ធ្វើល្អចំពោះឪពុកម្តាយជានិច្ច មិនដែលនិយាយអាក្រក់ដាក់មាតាបិតាឡើយ ។ គម្ពីររបស់គ្រិស្តសាសនិកហៅឈ្មោះព្រះអង្គ ﷺ ថា យ៉ូហាន (មើលគម្ពីរបរិសុទ្ធសញ្ញាថ្មី, ទំព័រ ១៣១៥, ដំណឹងល្អតាមលោក លូកា ១:៦៣) ។

អាយ៉ាស្ហ៍ច្រើនចែងអំពីព្រះសាស្តាយ៉ាស្ហ៊យ៉ា ﷺ នៅក្នុងព្រះបន្ទូលរបស់អល់ឡោះហ្ទ៍ ﷻ និងនៅក្នុងព្រះគម្ពីរតៅរ៉ត្ហ៍ដែរ ។ ព្រះអង្គ ﷺ តែងតែបង្ហាត់បង្រៀនមនុស្សឲ្យចេះដឹងគោលសាសនា និងញ៉ាំងមនុស្សឲ្យចៀសឆ្ងាយពីបាប ។ ព្រះអង្គ ﷺ បំពេញភារកិច្ចសាស្តាដោយយកចិត្តទុកដាក់ជាទីបំផុត ព្រះអង្គ ﷺ មិនរួញរានិយាយការពិតទេកាលណាព្រះអង្គ ﷺ គិតថាគេបានប្រព្រឹត្តខុស ។

ថ្ងៃមួយ ព្រះសាស្តាយ៉ាស្ហ៊យ៉ា ﷺ បានដឹងថាព្រះចៅអធិរាជនៃដែនដីប៉ាលេស្ទីនឈ្មោះ ហ្ទីរ៉ូឌុត ឬ ហ្ទីរ៉ូឌូទុស(هيرودوت أو هيرودوتس Herodotus) ចង់រៀបការជាមួយក្មួយស្រីខ្លួនឯងឈ្មោះ ហ្ទីរ៉ូឌីយ៉ា (هيروديا Herodya) ។ ព្រះចៅអធិរាជទើសចិត្តណាស់ព្រោះអាពាហ៍ពិពាហ៍បែបនេះខុសច្បាប់សាសនា និងត្រូវហាមនៅក្នុងព្រះគម្ពីរតៅរ៉ត្ហ៍ ។ គោលបំណងរបស់ព្រះអង្គរឿងអាពាហ៍ពិពាហ៍នេះដែលមិនអាចធ្វើទៅបាននោះចាប់ផ្តើមលេចឮពេញនគរ ប្រជារាស្ត្រក៏ចាប់ផ្តើមខ្សឹបខ្សៀវគ្នាពី

ទាំនាក់ទំនងខុសច្បាប់រវាងស្តេចនិងក្មួយស្រីបង្កើត ។

ហ៊្វីរ៉ូឌ្វីយ៉ាចង់រៀបការជាមួយស្តេច ព្រោះតែចង់ក្លាយទៅជាស្តេចស្រីរបស់ដែនដីប៉ាលេស្ទីន ។ ពេលដឹងថាព្រះសាស្តាយ៉ាស៊្យយ៉ាﷺជំទាស់អាពាហ៍ពិពាហ៍នេះ នាងបានក្លាយទៅជាសត្រូវស្លាប់រស់របស់ព្រះអង្គﷺ ។

គ្រាមួយ ពេលស្តេចបណ្តោយខ្លួនដោយផឹកស្រា ស្តាប់តន្ត្រី ហ៊្វីរ៉ូឌ្វីយ៉ាបានបង្ហាញខ្លួនដោយគ្មានអៀនខ្មាស ។ ស្តេចកាន់តែងប់ស្រឡាញ់នាងលើសមុន ហើយបានសន្យាថានឹងឲ្យនាងអ្វីក៏ដោយស្រេចតែព្រះនាងចង់បាន ។ នាងក៏បានសូមឲ្យសម្លាប់ព្រះសាស្តាយ៉ាស៊្យយ៉ាﷺយ៉ាងលឿនបំផុត ។ ស្តេច ព្រោះតែងប់ស្រឡាញ់ក្មួយស្រីខ្លួនឯង លែងគ្រប់គ្រងខ្លួនឯងបានក៏ដាក់បញ្ជាឲ្យសម្លាប់ព្រះសាស្តាយ៉ាស៊្យយ៉ាﷺ ។

ក្រោយពីនោះភ្លាម ពួកចៃវាំងអែបអបស្តេចបាននាំខ្លួនព្រះសាស្តាយ៉ាស៊្យយ៉ាﷺមកស្លាម់យ៉ាងសាហាវ ។ តែឈាមពិសិដ្ឋរបស់ព្រះសាស្តាដ៏ថ្លៃថ្នូររបស់អល់ឡោះហ៊្វ ُپុះកញ្ជ្រោលគ្រប់ទីកន្លែងដែលវាហូរទៅដល់ ។ គេបានលុបឈាមដោយពំនូកខ្សាច់ តែវានៅតែពុះកញ្ជ្រោល ។ ទីបំផុត កូនភ្នំមួយត្រូវបានកើតឡើងពីលើឈាម តែឈាមនោះនៅតែហូរ ។

អព្ភូតហេតុអស្ចារ្យនេះបានឈប់ពេល បាក់ទុន-ណាស្សរ (بُخْتُ النَّصَّرِ) វាយយកបានដែនដីប៉ាលេស្ទីន បានសងសឹកសងឈាមឥតកំហុសរបស់ព្រះសាស្តាយ៉ាស៊្យយ៉ាﷺដោយសម្លាប់ពួក បានី អ៊ីសរ៉ាអ៊ីល ១៧០០០ នាក់នៅលើកូនភ្នំនេះ ។

ក្នុងមួយជីវិតដ៏ខ្លីរបស់ព្រះអង្គﷺ ព្រះសាស្តាយ៉ាស៊្យយ៉ាﷺបានបន្សល់ទុកឲ្យយើងនូវមេរៀនសីលធម៌ដ៏មានតម្លៃ ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ព្រះសាស្ដាស្ការីយ៉ា﵇ ជាអាណាព្យាបាលរបស់មហានារីវិសេសវិសាលមួយអង្គ ។ មហាស្ត្រីអង្គនេះជាអ្នកណា ? ព្រះនាងជាព្រះមាតារបស់អ្នកណា ?

២. ព្រះសាស្ដាស្ការីយ៉ា﵇បានបួងសួងសូមអ្វី ? តើការបួងសួងរបស់ព្រះអង្គ﵇បានសម្រេចទេ ?

៣. ព្រះរាជបុត្ររបស់ព្រះសាស្ដាស្ការីយ៉ា﵇មានព្រះនាមអ្វី ? គម្ពីររបស់គ្រិស្តសាសនិកហៅព្រះនាមព្រះអង្គ﵇ថាអ្វី ?

៤. ហ្វីរ្ហូនជាអ្នកណា ? ហេតុអ្វីហ្វីរ្ហូនស្អប់ព្រះសាស្ដាយ៉ាស៊ុយ៉ា﵇ ?

៥. អ្នកណាបានសម្លាប់ព្រះសាស្ដាយ៉ាស៊ុយ៉ា﵇ ? ហេតុអ្វី ?

# មេរៀនទី ១៩

## ព្រះសាស្តា ដាវុដﷺ

ប្រជាជាតិ បានី អ៊ីសរ៉អ៊ីល ដែលបានភៀសខ្លួនពីប្រទេសអេស៊ីបត៍ជាមួយព្រះសាស្តាមូសាﷺនោះ បានតាំងលំនៅនៅឯដែនដីប៉ាលេស្ទីន ។ តែពួកគេធ្វើសង្គ្រាមទល់នឹងពួកហ្វីលីស្ទីនជាប់ ទីបំផុតពួកហ្វីលីស្ទីនបានដេញពួកគេចេញពីលំនៅ ។

នៅក្នុងសមរភូមិចុងក្រោយបង្អស់ ហឹបស័ក្តិសិទ្ធិដែលទុកនូវបន្ទះព្រះគម្ពីរតៅរ៉តួដើមបានបាត់ នាំឲ្យប្រជាជាតិ បានី អ៊ីសរ៉អ៊ីល បាក់ទឹកចិត្តអនេក ។ ពួកគេបានរស់នៅក្នុងនិរទេសអស់ច្រើនឆ្នាំដោយអស់សង្ឃឹម មុននឹងបានជួបព្រះសាស្តាស្វ៊ុមូអ៊ីលﷺ (صموئيل) សូមឲ្យព្រះអង្គﷺជ្រើសរើសស្តេចខ្លាំងពូកែមួយឲ្យពួកគេដើម្បីពួកគេនឹងអាចយកបានទឹកដីខ្លួនវិញ ។

ព្រះសាស្តាស្វ៊ុមូអ៊ីលﷺបានជ្រើសរើសត៊ុ្មលូត (طالوت) ជាស្តេចពួកគេ តាមព្រះរាជបញ្ជារបស់អល់ឡោះហ្វ៍ ។ ប្រជាជាតិ បានី អ៊ីសរ៉អ៊ីល បានប្រកែកតវ៉ាជម្រើសនេះដោយអះអាងត៊ុ្មលូតជាអ្នកក្រគ្មានកេរ្តិ៍ឈ្មោះ ។ តែព្រះសាស្តាស្វ៊ុមូអ៊ីលﷺបានប្រាប់ពួកគេថាត៊ុ្មលូតត្រូវជ្រើសរើសព្រោះត៊ុ្មលូតមានអភិញ្ញា មានប្រាជ្ញាញាណនិងមានកម្លាំងខ្លាំងក្លា ថាត៊ុ្មលូតនឹងដឹកនាំពួកគេទៅរកជ័យជំនះ ។

ត៊ុ្មលូតបានចំណាយពេល ២០ ឆ្នាំដើម្បីស្វែងរកហឹបស័ក្តិសិទ្ធិ លុះហឹបនោះបានមកប្រជារាស្ត្រវិញ ពួកគេបានលើកទ័ពទៅវាយយកដែនដីប៉ាលេស្ទីន ។ ពួកហ្វីលីស្ទីនដឹកនាំដោយមេដឹកនាំម្នាក់គួរឲ្យខ្លាច បុរសខ្ពស់ក្រអាញដូចយក្សឈ្មោះយ៉ាលូត (جالوت) ។ ពេលបានឃើញយ៉ាលូត ពួកបានី អ៊ីសរ៉អ៊ីល ភ័យបាក់ស្បាតលែងហ៊ានប្រយុទ្ធនឹងយ៉ាលូត ។

ព្រះសាស្តាដាវុដﷺជាវរេហ៍ពលម្នាក់នៃកងទ័ពរបស់ត៊ុ្មលូត ។ សម័យនោះព្រះអង្គﷺនៅក្មេង ព្រះអង្គﷺមកទីនេះមិនមែនដើម្បីប្រយុទ្ធទេ ព្រះអង្គﷺជាជំនួយការរបស់បងប្រុស ៣ នាក់ដែលជាយោធា និងជាអ្នកនាំដំណឹងសមរភូមិមកទៅឪពុក ។ ពេលត៊ុ្មលូតឃើញថាទ័ពព្រះអង្គខ្លាចយ៉ាលូត ព្រះអង្គកម្លាចិត្តយុទ្ធជន

ដោយសន្យាប្រទានរង្វាន់ដ៏ធំឲ្យអ្នកណាដែលប្រយុទ្ធនឹងយ៉ាលូត ។ ព្រះអង្គបានសន្យារៀបការបុត្រីឲ្យអ្នកណាដែលអាចសម្លាប់យ៉ាលូតបាន ។

ចង់ឃើញសកម្មភាពនៅក្នុងលានប្រយុទ្ធ ព្រះសាស្តាដាវុដ ﷺ បានចាកចោលទីតាំងដើម្បីចង់ដឹងព្រឹត្តិការណ៍ ។ ព្រះអង្គ ﷺ មិនដែលប្រយុទ្ធតតួទេ តែពេលឃើញឆាកប្រយុទ្ធ ព្រះអង្គ ﷺ ចូលទៅជិតត៉្លលូត ប្រាប់ត៉្លលូតថាៈ "ទូលបង្គំនឹងប្រយុទ្ធតទល់នឹងបុរសបិសាចនេះ ព្រោះទូលបង្គំធ្លាប់សម្លាប់ខ្លានិងខ្លាឃ្មុំដែលបានស៊ីចៀមឪពុកទូលបង្គំ ។"

សេចក្តីក្លាហានរបស់ព្រះសាស្តាដាវុដ ﷺ បានធ្វើឲ្យស្តេចត៉្លលូតរំភើបចិត្ត ។ ត៉្លលូតក៏បានប្រដាប់គ្រោះឲ្យព្រះសាស្តាដាវុដ ﷺ ហើយតឿនព្រះអង្គ ﷺ ឲ្យប្រុងប្រយ័តខ្លួន ។

មុនទៅរកយ៉ាលូត ព្រះសាស្តាដាវុដ ﷺ ដោះអាវគ្រោះធ្ងន់ចេញព្រោះវាធ្វើឲ្យព្រះអង្គ ﷺ ពិបាកកម្រើកខ្លួន ។ ព្រះអង្គ ﷺ ប្រយុទ្ធនឹងសត្រូវដោយមានតែដង្ហក់មួយនិងឧបករណ៍សម្រាប់ឃ្វាលចៀមប៉ុណ្ណោះជាអាវុធ ។



មុនយ៉ាលូតត្រៀមខ្លួនប្រយុទ្ធទាន់ ព្រះសាស្តាដាវុដ ﷺ បានគ្រវែងដុំថ្មដោយដង្ហក់សំដៅយ៉ាលូត ។ ដុំថ្មទៅប៉ះកណ្តាលថ្ងាសយ៉ាលូតជាដំណំ បណ្តាលឲ្យដួលលើដីល្វីល្វើភាំងស្មារតី ។ ព្រះសាស្តាដាវុដ ﷺ បានរើសយកដាវដ៏ធ្ងន់របស់យ៉ាលូត ហើយក៏បានកាត់ក្បាលយ៉ាលូត ។ គំហើញវីរៈបុរសជើងឯករបស់ខ្លួនស្លាប់ បានធ្វើឲ្យពួកហ្វីលីស្ទីនភ័យរត់ចោលលានប្រយុទ្ធទាំងស្លន់ស្លោ ។ ព្រោះតែកោតសរសើរសេចក្តីក្លាហានមហិមារបស់ព្រះសាស្តាដាវុដ ﷺ ស្តេចត៉្លលូតក៏បានអភិសេករាជបុត្រីឈ្មោះមីកាល់ ឲ្យព្រះសាស្តាដាវុដ ﷺ ។ ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៏ អាល់-បាក៏រ៉ោះត៏ អាយ៉ាស់ 251 (2:251) ចែងថាៈ

فَهَزَمُوهُم بِإِذْنِ ٱللَّهِ وَقَتَلَ دَاوُۥدُ جَالُوتَ وَءَاتَىٰهُ ٱللَّهُ ٱلْمُلْكَ وَٱلْحِكْمَةَ وَعَلَّمَهُۥ مِمَّا يَشَآءُ ۗ وَلَوْلَا دَفْعُ ٱللَّهِ ٱلنَّاسَ بَعْضَهُم بِبَعْضٍ لَّفَسَدَتِ ٱلْأَرْضُ وَلَٰكِنَّ ٱللَّهَ ذُو فَضْلٍ عَلَى ٱلْعَٰلَمِينَ ﴿٢٥١﴾

*251. ពួកគេបានវាយបាក់ទ័ពពួកនោះ អាស្រ័យការអនុញ្ញាតរបស់អល់ឡោះហ្ ។*

*ដាវូដបានសម្លាប់យ៉ាលូត ។ អល់ឡោះហ៍បានប្រទានអំណាចគ្រងរាជ្យនិងប្រាជ្ញាញាណឲ្យគេ ព្រះអង្គបានបង្រៀនគេនូវអ្វីដែលព្រះអង្គមានព្រះបំណង ។ បើអល់ឡោះហ៍មិនរុញច្រានមនុស្សមួយពួកដោយមនុស្សមួយពួកទៀតទេ ផែនដីច្បាស់ជាវិនាសហិនហោច ។ តែអល់ឡោះហ៍ទ្រង់ប្រកបដោយព្រះករុណាប្រណីដល់លោកទាំងពួង ។*

ព្រះសាស្តាដាវូដ﵇បានក្លាយទៅជាមេដឹកនាំទ័ពរបស់ត៍លូត ហើយមិត្តភាពរវាងព្រះអង្គ﵇និងកូនប្រុសរបស់ត៍លូតឈ្មោះ យូណាស្សាន់ (يوناثان) បានធ្វើឲ្យព្រះអង្គ﵇មានអំណាចនិងល្បីឈ្មោះពេញដែនដី ។ បន្ទាប់ពីត៍លូតចូលទិវង្គត ព្រះសាស្តាដាវូដ﵇បានទៅជាស្តេច ។ អល់ឡោះហ៍﷿បានព្រះរាជទានញាណប្រាជ្ញានិងព្រះគម្ពីរស្សាប៊ូរ (زبور) ឲ្យព្រះអង្គ﵇ ។ ព្រះអង្គ﵇តែងតែសូត្រព្រះគម្ពីរនេះដោយសម្លេងពីរោះ ដើម្បីទាក់ទាញមនុស្សឲ្យមករកព្រះបន្ទូលអល់ឡោះហ៍﷿ ។

អល់ឡោះហ៍﷿បានប្រោសប្រណីព្រះសាស្តាដាវូដ﵇ច្រើនណាស់ ។ ពេលព្រះអង្គ﵇ធ្វើសក្ការៈអល់ឡោះហ៍﷿ ភ្នំនិងសត្វស្លាបចូលរួមធ្វើសក្ការៈជាមួយព្រះអង្គ﵇ដែរ ។ នៅក្នុងដៃព្រះអង្គ﵇ ដែកប្រៀបបាននឹងក្រមួន ព្រះអង្គ﵇សូនវាធ្វើប្រដាប់ក្រោះពិសេស និងប្រដាប់ក្រោះសង្គ្រាមស្រាលៗធ្វើអំពីកងដែកតូចៗតជាប់គ្នា ។

ព្រះសាស្តាដាវូដ﵇ប្រកបមុខរបរ លក់ប្រដាប់ក្រោះទាំងនេះឲ្យកងទ័ព ។ ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ សាបាអ៍ អាយ៉ាស្ទ៍ 10 (34:10) ចែងថា៖

۞وَلَقَدْ ءَاتَيْنَا دَاوُۥدَ مِنَّا فَضْلًا ۖ يَٰجِبَالُ أَوِّبِى مَعَهُۥ وَٱلطَّيْرَ ۖ وَأَلَنَّا لَهُ ٱلْحَدِيدَ ﴿١٠﴾

*10. យើងមានឧបការគុណចំពោះដាវូដ [ដោយមានតម្រាស់ថា៖] "ភ្នំនិងសត្វស្លាបទាំងឡាយអើយ ចូរពួកអ្នកសូត្រសេចក្តីសរសើរស្រុះគ្នាជាមួយគេទៅ ។" ហើយយើងបានធ្វើឲ្យដែកទៅជាទន់សម្រាប់គេ ។*

ព្រះសាស្តាដាវូដ﵇ធ្លាប់តែបែងចែកកិច្ចការផ្សេងៗ សម្រាប់ថ្ងៃនីមួយៗ ។ ដូច្នេះ ព្រះអង្គ﵇ទុកពេលមួយថ្ងៃសម្រាប់ធ្វើសក្ការៈអល់ឡោះហ៍﷿ មួយថ្ងៃសម្រាប់ទទួលពាក្យបណ្តឹងរបស់ប្រជារាស្ត្រ មួយថ្ងៃសម្រាប់ដាស់តឿនមនុស្ស

មួយថ្ងៃសម្រាប់សម្រាក ។ល ។ ក្នុងថ្ងៃសម្រាក ឆ្មាំការពារព្រះសាស្តាដាវូដ (عليه السلام) មិនឲ្យអ្នកណាចូលជួបព្រះអង្គ (عليه السلام) ទេ ។ ថ្ងៃសម្រាកមួយ ទេវតាពីរអង្គកាឡៃខ្លួនជាមនុស្សបានចូលក្នុងដំណាក់ព្រះសាស្តាដាវូដ (عليه السلام) តាមដំបូល ធ្វើឲ្យព្រះអង្គ (عليه السلام) ខ្លាច ។ ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ ស្វដ្ទ អាយ៉ាស់ 22-23 (38:22-23) ចែងថា៖

إِذۡ دَخَلُواْ عَلَىٰ دَاوُۥدَ فَفَزِعَ مِنۡهُمۡۖ قَالُواْ لَا تَخَفۡۖ خَصۡمَانِ بَغَىٰ بَعۡضُنَا عَلَىٰ بَعۡضٖ فَٱحۡكُم بَيۡنَنَا بِٱلۡحَقِّ وَلَا تُشۡطِطۡ وَٱهۡدِنَآ إِلَىٰ سَوَآءِ ٱلصِّرَٰطِ ٢٢ إِنَّ هَٰذَآ أَخِي لَهُۥ تِسۡعٞ وَتِسۡعُونَ نَعۡجَةٗ وَلِيَ نَعۡجَةٞ وَٰحِدَةٞ فَقَالَ أَكۡفِلۡنِيهَا وَعَزَّنِي فِي ٱلۡخِطَابِ ٢٣

*22. ពេលពួកគេបានចូលដល់ដាវូដ គេបានខ្លាចពួកគេ ពួកគេបានថា៖ "សូមលោកកុំខ្លាច យើងទាំងពីរជាគូក្តីដែលឈ្លោះគ្នា ។ ម្នាក់នៃយើងទាំងពីរបានធ្វើខុសទៅលើម្នាក់ទៀត ។ សូមលោកវិនិច្ឆ័យឲ្យយើងទាំងពីរឲ្យសមតាមការពិត ។ សូមលោកកុំអយុត្តិធម៌ និងសូមជួយដឹកនាំយើងទាំងពីរនៅលើមាគ៌ាត្រឹមត្រូវផង ។ 23. គេម្នាក់នេះជាបងប្អូនខ្ញុំ គេមានសត្វចៀមកៅសិបប្រាំបួនក្បាល ចំណែកខ្ញុំមានតែមួយក្បាលប៉ុណ្ណោះ ។ គេបានប្រាប់ខ្ញុំថា៖ "ចូរអ្នកផ្ញើវានៅនឹងខ្ញុំនេះហើយ ។" គេបានជជែកឈ្នះខ្ញុំ[ដោយសង្កត់ខ្ញុំ តែខ្ញុំមិនចង់ឲ្យវាទៅគេទេ] ។"*

ព្រះសាស្តាដាវូដ (عليه السلام) បានស្តាប់ពាក្យបណ្តឹង ហើយមានវចនៈភ្លាមថាបុរសដែលសូមចៀមដែលបងប្អូនខ្លួនមានតែមួយគត់នោះជាអ្នកធ្វើខុស ។ ខណៈនោះព្រះសាស្តាដាវូដ (عليه السلام) ដឹងខ្លួនថាអល់ឡោះហ្ (عز وجل) សាកល្បងព្រះអង្គ (عليه السلام) ព្រះអង្គ (عليه السلام) ស្តាយក្រោយដែលបានវិនិច្ឆ័យប្រញាប់ប្រញាល់ពេក ដោយពុំបានសួររកភ័ស្តុតាងពីអ្នកប្តឹង និងដោយពុំបានស្តាប់គូក្តីក្តាំម្នាក់ទៀត ។ ព្រះអង្គ (عليه السلام) ដឹងខ្លួនថាក្នុងនាមជាចៅក្រមរបស់ប្រជានុរាស្ត្រ ព្រះអង្គ (عليه السلام) មិនត្រូវអារកាត់លឿនពេកទេ ព្រះអង្គ (عليه السلام) បែរទៅរកអល់ឡោះហ្ (عز وجل) សូមខមាទោសព្រះអង្គ (عز وجل) ដែលបានធ្វើខុស ។

ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ ស្វដ្ទ អាយ៉ាស់ 25 (38:25) ចែងថា៖

فَغَفَرۡنَا لَهُۥ ذَٰلِكَۖ وَإِنَّ لَهُۥ عِندَنَا لَزُلۡفَىٰ وَحُسۡنَ مَـَٔابٖ ٢٥

*25. យើងបានលើកលែងទោសនោះឲ្យគេ ។ គេមានឋានៈអែបជិតនឹងយើង និងមានទីវិលត្រឡប់ល្អ ។*

ព្រះសាស្តាដាវូដ (عليه السلام) បានសោយរាជ្យដោយសីលធម៌ អស់រយៈពេលច្រើនឆ្នាំ បន្ទាប់មកព្រះរាជបុត្រពៅគេរបស់ព្រះអង្គ (عليه السلام) ព្រះសាស្តាស៊ូឡៃម៉ាន (عليه السلام) បានសោយរាជ្យជួសព្រះអង្គ (عليه السلام) ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីប្រជាជាតិ បានី អ៊ីសរ៉អ៊ីល បាក់ទិកចិត្ត ?

២. ពួក បានី អ៊ីសរ៉អ៊ីល បានសូមអ្វីពីព្រះសាស្តាស្ហ៊ិមូអ៊ីលﷺ ? ព្រះអង្គﷺ បានជ្រើសរើសអ្នកណា ?

៣. ហេតុអ្វីពុំមានអ្នកណាហ៊ានប្រយុទ្ធនឹងយ៉ាលូត ? អ្នកណាស្ម័គ្រចិត្ត ប្រយុទ្ធនឹងយ៉ាលូត អ្នកនោះឈ្មោះសមរភូមិដូចម្តេច ?

៤. អល់ឡោះហ្វ៎ﷻមានព្រះគុណដល់ព្រះសាស្តាដាវូដﷺដូចម្តេចខ្លះ ?

៥. ព្រះសាស្តាដាវូដﷺប្រញាប់កាត់ក្តីថាអ្វី ? ព្រះអង្គﷺធ្វើខុសប្រការណា ?

# មេរៀនទី ២០

## ព្រះសាស្ដា ស៊ូឡៃម៉ាន﵇

ព្រះសាស្ដាស៊ូឡៃម៉ាន﵇ ជាព្រះរាជបុត្រពៅគេរបស់ព្រះសាស្ដាដាវូដ﵇ ជាអ្នកស្នងព្រះសាស្ដាដាវូដ﵇ ។ អល់ឡោះហ្ទ៊ូ﷿បានព្រះរាជទានរាជាណាចក្រដ៏ធំបំផុតឲ្យព្រះអង្គ﵇ ពុំដែលមានស្ដេចណាធ្លាប់គ្រប់គ្រងអាណាចក្រសម្បើមដូចនេះឡើយ ។ ព្រះអង្គ﵇អាចបញ្ជាខ្យល់ អាចប្រើខ្យល់សម្រាប់ដឹកព្រះរាជបល្ល័ង្កព្រះអង្គ﵇តាមផ្លូវអាកាសបាន ។ មនុស្សនិងយ៉ិនស្មោះស្ម័គ្រចំពោះព្រះអង្គ﵇ ព្រះអង្គ﵇អាចបញ្ជាឲ្យពួកសត្វស្លាបធ្វើតាមបញ្ជាព្រះអង្គ﵇បាន ដោយនិយាយភាសាវា ។ អាស្រ័យព្រះគុណូបការៈទាំងនេះឯងបានជារាជាណាចក្ររបស់ព្រះសាស្ដាស៊ូឡៃម៉ាន﵇មានអំណាចក្រៃលែង ច្រើនប្រទេសនៅក្រោមការគ្រប់គ្រងរបស់អាណាចក្រព្រះអង្គ﵇ ។ ពេលព្រះសាស្ដាស៊ូឡៃម៉ាន﵇លើកទ័ពទៅទីណា គេខ្លាចទ័ពនោះ ។ ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាន់-ណាំល៍ អាយ៉ាស់ 17-18 (27:17-18) ចែងអំពីរឿងនេះថា៖

وَحُشِرَ لِسُلَيْمَٰنَ جُنُودُهُۥ مِنَ ٱلْجِنِّ وَٱلْإِنسِ وَٱلطَّيْرِ فَهُمْ يُوزَعُونَ ﴿١٧﴾ حَتَّىٰٓ إِذَآ أَتَوْا۟ عَلَىٰ وَادِ ٱلنَّمْلِ قَالَتْ نَمْلَةٌ يَٰٓأَيُّهَا ٱلنَّمْلُ ٱدْخُلُوا۟ مَسَٰكِنَكُمْ لَا يَحْطِمَنَّكُمْ سُلَيْمَٰنُ وَجُنُودُهُۥ وَهُمْ لَا يَشْعُرُونَ ﴿١٨﴾



*17. កងទ័ពទាំងឡាយរបស់ស៊ូឡៃម៉ាន ដែលមានដោយយ៉ិន (បិសាច) មនុស្សនិងសត្វស្លាបត្រូវប្រជុំគ្នាជាជួរ ។ 18. ពេលពួកគេបានមកដល់ជ្រលងស្រមោច ស្រមោចមួយបានថា៖ "ហៃស្រមោចទាំងឡាយចូរចូលក្នុងលំនៅដ្ឋានអស់លោក ដើម្បីកុំឲ្យស៊ូឡៃម៉ាននិងកងទ័ពទាំងឡាយរបស់គេដើរជាន់អស់លោកដោយមិនដឹងខ្លួន ។"*

ព្រះសាស្ដាស៊ូឡៃម៉ាន﵇បានឮមេដឹកនាំរបស់ស្រមោច ប្រកាសឲ្យពួកស្រមោចប្រយ័តខ្លួន ព្រះអង្គ﵇ឲ្យស្រមោចចូលមកក្បែរព្រះអង្គ﵇ សួរវាថា៖ "អ្នកគិតព្រះសាស្ដារបស់អល់ឡោះហ្ទ៊ូ﷿ អាចធ្វើអាក្រក់ចំពោះសត្វលោកណាមួយរបស់ព្រះអង្គ﷿ឬ ?"



ស្រមោចបានតបថា៖ "ទេ មិនមែនដូច្នេះទេ តែទូលបង្គំខ្លាចថា ពេលបក្សពួកទូលបង្គំឃើញទ័ពដ៏សម្បើមរបស់ព្រះអង្គﷺ ពួកគេនឹងគិតថាព្រះគុណអល់ឡោះហ្ ﷻមកលើពួកគេនោះមានតម្លៃទាប ហើយខ្លាចពួកគេនឹងរមិលគុណអល់ឡោះហ្ﷻ ។ ដូច្នេះឯងបានជាទូលបង្គំឲ្យពួកគេពួន ។"



ថ្ងៃមួយ ព្រះសាស្តាស៊ូឡៃម៉ានﷺមិនឃើញសត្វស្លាប ហ៊ូដហ៊ូដ (الْهُدْهُد សត្វត្រសេះ) អ្នកនាំសាររបស់ព្រះអង្គﷺ ។ ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាន់-ណាំល៍ អាយ៉ាស៍ 20-21 (27:20-21) ចែងថា៖

وَتَفَقَّدَ ٱلطَّيْرَ فَقَالَ مَا لِيَ لَآ أَرَى ٱلْهُدْهُدَ أَمْ كَانَ مِنَ ٱلْغَآئِبِينَ ۝٢٠
لَأُعَذِّبَنَّهُۥ عَذَابًا شَدِيدًا أَوْ لَأَاْذْبَحَنَّهُۥٓ أَوْ لَيَأْتِيَنِّي بِسُلْطَٰنٍ مُّبِينٍ ۝٢١

*20. គេបានដើរត្រួតពលបក្សីទាំងឡាយ ហើយបានថា៖ "ហេតុអ្វីខ្ញុំមិនឃើញសត្វត្រសេះ ? វាមិននៅទេឬ ? 21. ខ្ញុំនឹងដាក់ទោសវាយ៉ាងតឹងរ៉ឹង ឬខ្ញុំនឹងសំឡេះវា បើវាមិននាំហេតុផលជាក់ច្បាស់មកឲ្យខ្ញុំទេ ។"*

មិនយូរប៉ុន្មានហ៊ូដហ៊ូដមកដល់ ហើយទូលថា៖ "ទូលបង្គំបានទៅដល់ស្រុកមួយ ព្រះអង្គﷺអាចមិនស្គាល់ស្រុកនោះទេ ។ ស្រុកនោះគឺសាបាអ៊ (سبأ) សោយរាជ្យដោយស្ត្រីម្នាក់ដែលគ្រប់គ្រងប្រជារាស្ត្រទាំងអស់ ។ បល្ល័ង្កព្រះនាងធំណាស់ តែពួកគេយកថ្ងៃធ្វើជាព្រះ ចោលអល់ឡោះហ្ﷻ ។"

ព្រះសាស្តាស៊ូឡៃម៉ានﷺបានផ្ញើសំបុត្រទៅប៊ីលគីស (بِلْقِيس) ស្តេចស្រីនៃនគរសាបាអ៊ ថា៖ "ក្នុងព្រះនាមអល់ឡោះហ្ﷻ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។ ចូរកុំប្រឆាំងខ្ញុំ ចូរមករកខ្ញុំដោយចុះចូលចំពោះអល់ឡោះហ្ﷻ ។"

ពេលបានទទួលសំបុត្រ ប៊ីលគីសសួរយោបល់មន្ត្រីអំពីរឿងនេះ ។ ពួកមន្ត្រីតបថាពួកគេមានកងទ័ពខ្លាំងពូកែ មិនខ្លាចធ្វើសង្គ្រាមទេ តែការសម្រេចនៅលើព្រះនាង ។

ប៊ីលគ្វីសចង់ដោះស្រាយបញ្ហាដោយសន្តិវិធី ដូច្នេះព្រះនាងបានចាត់បញ្ជូនគណៈប្រតិភូជាមួយអំណោយថ្លៃៗទៅជួបព្រះសាស្តាស៊ូឡៃម៉ានﷇ ហើយរង់ចាំមើលប្រតិកម្មពីព្រះអង្គﷇ ។ លុះគណៈប្រតិភូនៃនគរសាបាអ៊ុំបានទៅដល់អាណាចក្រព្រះសាស្តាស៊ូឡៃម៉ានﷇ ពួកគេស្ញើចសម្រស់សំណង់នានានិងរាជវាំង ។

ព្រះសាស្តាស៊ូឡៃម៉ានﷇស្វាគមន៍គណៈប្រតិភូ ហើយបានសូមចម្លើយសំបុត្រព្រះអង្គﷇ ។ ពេលគេថ្វាយព្រះអង្គﷇនូវស្បួយសារអាករ ព្រះអង្គﷇទុកវាមួយអន្លើ ហើយថា៖ "ទ្រព្យទាំងនេះមានន័យថាអ្វី ? អល់ឡោះហ្ញ៉ូﷻប្រទានឲ្យខ្ញុំច្រើនណាស់ ពុំមានអ្នកណាមានស្មើខ្ញុំទេ ។ ចូរត្រឡប់ទៅនគរអស់លោកវិញប្រាប់ស្តេចស្រីអស់លោកថាខ្ញុំនឹងបញ្ជូនទ័ពដ៏ធំទៅកាន់នគរសាបាអ៊ុំ ពុំមានអ្នកណាប្រយុទ្ធឈ្នះទ័ពនោះទេ ។"

ពេលបានទទួលសារនិងបានស្តាប់សេចក្តីរាយការណ៍ពីគណៈប្រតិភូ អំពីព្រះសាស្តាស៊ូឡៃម៉ានﷇ ប៊ីលគ្វីសបានសម្រេចចិត្តចុះចាញ់ព្រះអង្គﷇ ព្រមចូលអ៊ីស្លាមតាមការស្នើ ។ ព្រះសាស្តាស៊ូឡៃម៉ានﷇបានដឹងថាព្រះនាងមកកាន់នគរព្រះអង្គﷇ ព្រះអង្គﷇបានប្រាប់ប្រជារាស្ត្រថា៖ "អ្នកណាអាចនាំយកបល្ល័ង្ករបស់ស្តេចស្រីនគរសាបាអ៊ុំមកឲ្យខ្ញុំបាន មុនព្រះនាងមកដល់ទីនេះ ?

យ៉ិនមួយបានទូលថា៖ "ទូលបង្គំនឹងនាំយកបល្ល័ង្កនោះមកថ្វាយព្រះអង្គ មុនព្រះអង្គងើបពីកន្លែង ។"

តែ អាស៊ីហ្វ ប៊ិន បារឃ៊ីយ៉ា (عاصف بن برخيا) ដែលព្រះសាស្តាស៊ូឡៃម៉ានﷇបានប្រាប់ឲ្យស្គាល់ព្រះនាមពិសេសរបស់អល់ឡោះហ្ញ៉ូﷻនោះ បានទូល យោលតាមព្រះគម្ពីរគួរអាន ស៊ូរ៉ោះត្ទ័ អាន់-ណាំល៍ អាយ៉ាស្ហ 40 (27:40) ថា៖

قَالَ ٱلَّذِى عِندَهُۥ عِلْمٌ مِّنَ ٱلْكِتَٰبِ أَنَا۠ ءَاتِيكَ بِهِۦ قَبْلَ أَن يَرْتَدَّ إِلَيْكَ طَرْفُكَ ۚ فَلَمَّا رَءَاهُ مُسْتَقِرًّا عِندَهُۥ قَالَ هَٰذَا مِن فَضْلِ رَبِّى لِيَبْلُوَنِىٓ ءَأَشْكُرُ أَمْ أَكْفُرُ ۖ وَمَن شَكَرَ فَإِنَّمَا يَشْكُرُ لِنَفْسِهِۦ ۖ وَمَن كَفَرَ فَإِنَّ رَبِّى غَنِىٌّ كَرِيمٌ ٤٠

*40. ម្នាក់ដែលចេះដឹងព្រះគម្ពីរបានថា៖ "ទូលបង្គំនឹងនាំយកវាមកឲ្យព្រះអង្គមុនព្រះអង្គប៉ប្រិចភ្នែក ។" លុះគេបានឃើញបល្ល័ង្កនៅចំពោះមុខគេ គេបានថា៖ "នេះគឺព្រះគុណរបស់ព្រះម្ចាស់ខ្ញុំ ដើម្បីល្បងពិសោធខ្ញុំថាតើខ្ញុំដឹងគុណឬនិរគុណ ។ អ្នកណាដឹងគុណ អ្នកនោះដឹងគុណសម្រាប់ខ្លួនឯង ។ អ្នកណានិរគុណ ព្រះម្ចាស់ខ្ញុំទ្រង់គ្រប់គ្រាន់សម្រាប់ព្រះអង្គឯងណាស់ (ព្រះអង្គមិនត្រូវការអ្វីឡើយ ។ ព្រះអង្គ*

*ទេជាអ្នកធ្វើឲ្យសព្វសារពើមានបាន) ព្រះអង្គទ្រង់មហាថ្កុំថ្កើង ។"*

ដើម្បីរៀបចំទទួលព្រះនាងប៊ីលគ៏ីស ព្រះសាស្តាស៊ូឡៃម៉ានعليه السلامឲ្យគេសាងសង់ប្រាសាទកែវមួយ ។ នៅពីក្រោមជាន់នានាធ្វើអំពីកែវ មានអាងទឹកមានត្រីច្រើនប្រភេទហែល ។ លុះព្រះនាងប៊ីលគ៏ីសមកដល់ ព្រះអង្គعليه السلامនាំព្រះនាងទៅឯប្រាសាទ ។ ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៏ អាន់-ណាំល៏ អាយ៉ាស៊ុំ 44 (27:44) ថែងថា៖

قِيلَ لَهَا ٱدْخُلِى ٱلصَّرْحَ ۖ فَلَمَّا رَأَتْهُ حَسِبَتْهُ لُجَّةً وَكَشَفَتْ عَن سَاقَيْهَا ۚ قَالَ إِنَّهُۥ صَرْحٌ مُّمَرَّدٌ مِّن قَوَارِيرَ ۗ قَالَتْ رَبِّ إِنِّى ظَلَمْتُ نَفْسِى وَأَسْلَمْتُ مَعَ سُلَيْمَٰنَ لِلَّهِ رَبِّ ٱلْعَٰلَمِينَ ﴿٤٤﴾

*44. មានគេបានប្រាប់នាងថា៖ "សូមព្រះនាងយាងចូលទៅក្នុងរាជវាំង ។" លុះបានឃើញវាំងនោះ នាងស្មានថាវាជាផ្ទៃទឹក នាងក៏បានបញ្ចេញឲ្យឃើញជើងនាង ។ គេបានប្រាប់ថា៖ "នេះគឺវាំងដែលធ្វើអំពីកែវផលិក (កែវថ្លេក) ។" នាងបានពោល [ចំពោះអល់ឡោះហ្ទ៍]ថា៖ "ព្រះម្ចាស់អឺយ ខ្ញុំម្ចាស់បានប្រព្រឹត្តិដោយអយុត្តិធម៌លើខ្លួនឯង ។ ខ្ញុំម្ចាស់សូមចុះចូលជាមួយស៊ូឡៃម៉ាន ចំពោះអល់ឡោះហ្ទ៍ ព្រះម្ចាស់ពិភពទាំងពួងហើយ ។"*

ប៊ីលគ៏ីសភាន់ស្មារតីដោយសារអាការក្រៅរបស់ទឹក ព្រះនាងបានលើកសំពត់ឡើងដល់ជង្គង់ដើម្បីកុំឲ្យវាទទឹក ។ ពេលដឹងខ្លួនថាខុស ព្រះនាងយល់ន័យភ្លាមថាហេតុអ្វីព្រះសាស្តាស៊ូឡៃម៉ានعليه السلامធ្វើបែបនេះចំពោះខ្លួន ។ ព្រះអង្គعليه السلامបានបង្ហាញព្រះនាងថាវត្ថុមិនដូចអាការក្រៅរបស់វាទេ ទោះបីថ្ងៃដែលព្រះនាងធ្វើសក្ការៈជាព្រះនោះ ហាក់ដូចជាកម្លាំងមួយដែលខ្លាំងបំផុតសម្រាប់ព្រះនាងក៏ដោយ តែនៅមានកម្លាំងមួយទៀតដែលមានឥទ្ធិពលខ្លាំងជាងវាទៅទៀត ។

ស្ត្រីឈ្លាសវៃយល់អត្ថន័យ ហើយបានបែរទៅរកអល់ឡោះហ្ទ៍عز وجلដោយសារភាពកំហុសនិងមានសទ្ធា ។ ព្រះសាស្តាស៊ូឡៃម៉ានعليه السلامបានឲ្យព្រះនាងត្រឡប់ទៅនគរសាបាអ៊ ុំវិញ ឲ្យព្រះនាងសោយរាជ្យក្នុងព្រះនាមព្រះអង្គعليه السلام ។

ព្រះសាស្តាស៊ូឡៃម៉ានعليه السلامបានសោយរាជ្យ លើប្រជារាស្ត្រព្រះអង្គعليه السلامដោយយុត្តិធម៌អស់រយៈពេលដ៏យូរ ។ អំណាចព្រះអង្គعليه السلامបានវាតសន្ធឹងទៅដល់ស្រុកទេសភាគច្រើនដែលគេស្គាល់ ។ ព្រះគុណឯកនេះជាចម្លើយតបការបួងសួងរបស់ព្រះអង្គعليه السلامដែលមានចារនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៏ ស្វាដ៍ អាយ៉ាស៊ុំ 35 (38:35) ថា៖

قَالَ رَبِّ ٱغْفِرْ لِى وَهَبْ لِى مُلْكًا لَّا يَنۢبَغِى لِأَحَدٍ مِّنۢ بَعْدِىٓ ۖ إِنَّكَ أَنتَ ٱلْوَهَّابُ ﴿٣٥﴾

*35. គេបានទូលថា៖ "ព្រះម្ចាស់អើយ សូមព្រះមេត្តាលើកទោសឲ្យទូលព្រះបង្គំជាខ្ញុំផង ហើយសូមព្រះអង្គប្រទានឲ្យទូលព្រះបង្គំជាខ្ញុំនូវអាណាចក្រមួយដែលមិនមានអ្នកណាមានទេក្រោយពីទូលព្រះបង្គំជាខ្ញុំ ។ ព្រះអង្គជាអ្នកប្រទានអំណោយដ៏ប្រសើរបំផុត ។"*

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. ព្រះសាស្តាស៊ូឡៃម៉ានﷺជាអ្នកណា ? ហេតុអ្វីព្រះរាជាណាចក្ររបស់ព្រះអង្គﷺល្បីថាធំជាងអស់អាណាចក្រឯទៀត ?

២. មេស្រមោចបានដាស់តឿនស្រមោចឯទៀតថាអ្វី ? ហេតុអ្វី ?

៣. ហ៊ូដហ៊ូដ សត្វស្លាបអ្នកនាំសាររបស់ព្រះសាស្តាស៊ូឡៃម៉ានﷺបានទៅដល់កន្លែងណា ? វាបានឃើញអ្វី ?

៤. ប៊ីលគីសមានប្រតិកម្មអ្វី ពេលបានទទួលសំបុត្រពីព្រះសាស្តាស៊ូឡៃម៉ានﷺ ? ព្រះសាស្តាស៊ូឡៃម៉ានﷺមានប្រតិកម្មអ្វីពេលបានទទួលចម្លើយពីប៊ីលគីស ?

៥. ព្រះសាស្តាស៊ូឡៃម៉ានﷺចង់ឲ្យប៊ីលគីសយល់អត្ថន័យអ្វី ? ព្រះអង្គﷺបានប្រើមធ្យោបាយអ្វី ?

*sources:*
www.saba-igc.org
shia974.fr
www.madressa.net

អ៊ីម៉ាំមេម៉ាស្ហាប់ទាំង ៤ ។

| ឈ្មោះអ៊ីម៉ាំមេម៉ាស្ហាប់ | ម៉ាស្ហាប់ | ថ្ងៃកំណើត/ថ្ងៃស្លាប់ សករាជហ៊ិជ្រ៉ោះត៍ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ្រិស្តសករាជ |
|---|---|---|---|
| អាប៊ូ ហ៊ានីហ្វាស់ | ហ៊ាណាហ្វី | 80-150 ស.ហ. | 699-767 គ.ស. |
| ម៉ាលិក | ម៉ាលីគី | 93-179 ស.ហ | 711-795 គ.ស. |
| អាស្ស-ស្វាហ្វីអ៊ី | ស្វាហ្វីអ៊ី | 150-204 ស.ហ | 767-820 គ.ស. |
| អាស់ម៉ាដ់ ហ៊ាន់បាល់ | ហ៊ាន់បាលី | 164-241 ស.ហ. | 780-855 គ.ស. |

ព្រះសាសា មូហ៊ាំម៉ាដ់ ប្រសូត/ចូលព្រះទិវង្គត ឆ្នាំ 570-632 គ.ស.

អ៊ីម៉ាំអ្នកស្នងព្រះសាស្តាមូហ៊ាំម៉ាដ់ﷺទាំង ១២ ។

| លំដាប់ | ឈ្មោះ | ឈ្មោះក្រៅ | ហាននូរស័ក្តិ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ.ស./ស.ហ. |
|---|---|---|---|---|
| 1 | អ៊ុលី | អាប៊ូ អាល់-ហ៊ាសាន់ | អាមីរុល-មុមីនីន | 600-661/23 មុន ស.ហ.-40 |
| 2 | ហ៊ាសាន់ | អាប៊ូ មូហ៊ាំម៉ាដ់ | អាល់-មុច្ចតាបា | 625-670/3-50 |
| 3 | ហ៊ូសៃន៍ | អាប៊ូ អ៊ុប់ឌុលឡោះហ្ | សៃយីដុ អាស្ស-ស្វហ្វាដាអ៊ុ | 626-680/4-61 |
| 4 | អ៊ុលី ប៊ិន ហ៊ូសៃន៍ | អាប៊ូ មូហ៊ាំម៉ាដ់ | អាស់-សាច់យ៉ាដ់ ស្សែនុល-អាប៊ីឌីន | 659-713/38-95 |
| 5 | មូហ៊ាំម៉ាដ់ អាល់-បាគៀរ | អាប៊ូ យ៉ាក់ហ្វារ | បាគៀរ អាល់-អ៊ុលូម | 676-733/57-114 |
| 6 | យ៉ាក់ហ្វារ | អាប៊ូ អ៊ុប់ឌុលឡោះហ្ | អាស្ស-ស្វឌិក្ក | 702-765/83-148 |
| 7 | មូសា ប៊ិន យ៉ាក់ហ្វារ | អាប៊ូ អាល់-ហ៊ាសាន់ | អាល់-កាស្ហ៊ីម | 745-799/128-183 |
| 8 | អ៊ុលី ប៊ិន មូសា | អាប៊ូ អាល់-ហ៊ាសាន់ | អារ-រីដ្ឋ | 765-819/148-203 |
| 9 | មូហ៊ាំម៉ាដ់ ប៊ិន អ៊ុលី | អាប៊ូ យ៉ាក់ហ្វារ | អាត់-តាគី អាល់-យ៉ាវ៉ាដ់ | 811-835/195-220 |
| 10 | អ៊ុលី ប៊ិន មូហ៊ាំម៉ាដ់ | អាប៊ូ អាល់-ហ៊ាសាន់ | អាល់-ហ៊ាឌី អាន់-ណាគី | 828-868/212-254 |
| 11 | ហ៊ាសាន់ ប៊ិន អ៊ុលី | អាប៊ូ មូហ៊ាំម៉ាដ់ | អាល់-អ៊ុស់ការី | 846-874/232-260 |
| 12 | មូហ៊ាំម៉ាដ់ ប៊ិន ហ៊ាសាន់ | អាប៊ូ ក៏ស៊ីម | អាល់-ម៉ាស្ហ៊ឌី អាល់-ហ៊ុច្ចយ៉ាស់ ស្វ៉ហ៊ីប អាល់-ស្វាម៉ាន អាល់-ក៏អ៊ីម | 869/255 |